ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លីនៅក្នុង ឃុំព្រទិល

## ឆ្នាំ ២០០៩-២០២២

## ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់





**រៀបចំដោយ:** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំព្រងិល

**គាំទ្រដោយ:** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុកភ្នំក្រវាញ



ខែ កញ្ញា ឆ្នាំ ២០០៩

# មាតិកា


**អារម្ភកថា** ៤

**សេចក្តីផ្តើម** ៥

**ជំពូក១:  ព័ត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ៧

**១.១ ស្ថានភាពទូទៅ** ៧

១.១.១ ទីតាំងរដ្ឋបាល ៧

១.១.២ ប្រជាសាស្ត្រ ៨

១.១.៣ ភាពគ្មានដីធ្លី ៩

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ១០

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ១១

១.១.៦ ស្ថានភាពសុខាភិបាល ១២

១.១.៦.១ ផ្នែកសុខាភិបាល ១២

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ១៣

**១.២ ស្ថានភាពភូមិសាស្ត្រ** ១៤

១.២.១ ទីតាំងភូមិសាស្ត្រ ១៤

១.២.២ អាកាសធាតុ ១៥

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ១៥

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ១៦

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ១៦

១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី ១៨

១.៣.៣ ផលិតកម្មកសិកម្ម ១៨

១.៣.៤ ធនធានធម្មជាតិ ២២

១.៣.៤.១ ធនធានព្រៃឈើ ២២

១.៣.៤.២ ធនធានជលផល ២២

**១.៤ ទីផ្សារ និង ខ្សែសង្វាក់ផលិតផល** ២៣

១.៤.១ ទីផ្សារ និង តម្លៃកសិផល ផល និង អនុផលព្រៃឈើ និងផលនេសាទ ២៣

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ២៤

១.៤.៣ ឱកាស ឧបសគ្គ ២៤
**ជំពូក២: ការវិភាគពី ឧបសគ្គ តម្រូវការសំរាប់អនាគត និង សក្តានុពល** ២៦
**២.១ តំបន់រសើប** ២៦
**២.២ ការប្រឈម/ឧបស័គ្គ** ២៦
**២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍ និងគោលដៅយុទ្ធសាស្រ្តឃុំព្រងិល** ២៧
**២.៤ តម្រូវការសំរាប់អនាគត** ២៧
២.៤.១ ប្រជាសាស្រ្ត ២៨
២.៤.១.១ អត្រាកំណើន ២៨
២.៤.១.២ ការធ្វើចំណោលប្រជាសាស្រ្ត ៣០
២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន ៣០
២.៤.៣ តម្រូវការដីកសិកម្ម ៣១
២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ៣១
២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម ៣២
២.៤.៥.១ តម្រូវការដីសាលារៀន ៣៥
២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ៣២
២.៣.៥.៣ ផ្នែកវប្បធម៌ និងសាសនា ៣៣
២.៣.៥.៤ ហេដ្ឋារចនាសម្ពន្ធ័គមនាគមន៍ និងប្រពន្ធ័ស្រោចស្រព ៣៣
**ជំពូក៣: ផែនការប្រើប្រាស់ដីអនាគត** ៣៨
**៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី** ៣៨
៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ៣៨
៣.១.២ តម្រូវការដីតាមប្រភេទ ៣៨
**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់** ៣៩
៣.២.១ ការវិភាគអន្តរៈអំពើ ៣៩
៣.២.២ ផែនទីប្រើប្រាស់ដីអនាគត ៤១
៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ៤១
៣.២.៣.១ ដីលំនៅដ្ឋាន ៤១
៣.២.៣.២ ដីស្រែជាមួយភូមិ ៤១
៣.២.៣.៣ ការប្រើប្រាស់ដីក្នុងកិច្ចការពាធនធានធម្មជាតិ និងបរិស្ថាន ៤១

៣.២.៣.៤ ការប្រើប្រាស់ប្រពន្ធ័ស្រោចស្រព......................................................................................................៤១
៣.២.៣.៥ ការសាងសង់ និងការប្រើប្រាស់ផ្លូវថ្នល់......................................................................................................៤១

ឧបសម្ពន្ធ័១ : ការពិពណ៌នាអំពី ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន
ឧបសម្ពន្ធ័២ : ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន
ឧបសម្ពន្ធ័៣ : បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី
ឧបសម្ពន្ធ័៤ : ក្រុមខណ្ឌអភិវឌ្ឍន៍
ឧបសម្ពន្ធ័៥ : បញ្ជីគម្រោង
ឧបសម្ពន្ធ័៦ : ផែនទីប្រើប្រាស់ដីលំអិតនៅក្នុងឃុំ
ឧបសម្ពន្ធ័៧ : ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំ
ឧបសម្ពន្ធ័៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគតនៅក្នុងឃុំឆ្នាំ ២០០៩-២០០២

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំព្រងិល ជាផែនការអភិវឌ្ឍមួយដែលបានរៀបចំឡើងដោយមានការចូលរួមយ៉ាងពេញលេញពីក្រុមប្រឹក្សាឃុំ គណៈកម្មាធិការផែនការ និងថវិកាឃុំប្រជាពលរដ្ឋនៅក្នុងឃុំទាំងមូលអ្នកពាក់ពន្ធ័ទាំងអស់នៅក្នុងឃុំព្រងិល ដោយបានការជួយគាំទ្រផ្នែកបច្ចេកទេសពីក្រុមសប្រមសម្រួលការងាររៀបចំផែនការប្រើប្រាស់ដីថ្នាក់ស្រុករបស់ស្រុកភ្នំក្រវ៉ាញ (D-LUP) ដោយសហការជិតស្និទ្ធជាមួយអ្នកសម្របសម្រួលថ្នាក់ស្រុក (DFT) ប្រចាំស្រុកភ្នំក្រវ៉ាញ និងមានកាចូលរួមគាំទ្រសម្របសម្រួលបច្ចេកទេសពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត (P_LUP) របស់ខេត្តពោធិ៍សាត់ និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី (LMC) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពី អង្គការ DANIDA/DFID-NZAid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា។

ការរៀបចំផែនការប្រើប្រាស់ដីនេះឡើង ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាឃុំ និង គណៈកម្មាធិការផែនការ និង ថវិកា ដើម្បីរៀបចំផែនការអភិវឌ្ឍអោយចំទិសដៅ និងមានតម្លាភាពដោយបំផុសអោយមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ពន្ធ័ទាំងអស់នៅក្នុងឃុំ។ ម្យ៉ាងទៀតដើម្បីអាចគ្រប់គ្រង និង ប្រើប្រាស់ធនធានដី និង ធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងមានការចូលរួមគាំទ្រដល់ កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមអោយបានល្អប្រសើរឡើងដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងនាមយើងខ្ញុំជាក្រុមប្រឹក្សាឃុំព្រងិល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ម្ចាស់ជំនួយដូចជាប្រទេសដាណាម៉ាកញ៉ូសេឡែន និងចក្រពភអង់គ្លេស ក្រោមកិច្ចគាំទ្រដោយអង្គការDANIDA DFID NZAid ក៏ដូចជា ក្រសួងរៀបចំដែនដី នគរូបនីកម្ម និង សំណង់ សាលាខេត្ត និងស្ថាប័នពាក់ពន្ធ័នានានៅជុំវិញខេត្ត ពិសេសមន្ទីររៀបចំដែនដី នគរូបនីកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ក្រុមការងារ DFT ព្រមទាំងអាជ្ញាធរដែនដីស្រុកឃុំគ្រប់លំដាប់ថ្នាក់ដែលបានខិតខំយកចិត្តទុកដាក់ និងសម្របសម្រួលដល់ដំណើការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំយើងខ្ញុំ ។

ព្រងិល,ថ្ងៃទី......៤......ខែ....៥.......ឆ្នាំ២០០៩

មេឃុំ

អ៊ុក_រី

## សេចក្តីផ្តើម

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំព្រងិល គឺសំដៅទៅដល់ការអភិវឌ្ឍន៍មូលដ្ឋានក្នុងឃុំសង្កាត់ទាំងមូលទាំងដីរដ្ឋ និង ទាំងដីឯកជនរបស់បុគ្គលឯកជន។ ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់នេះមានគោលបំណងដូចតទៅ:

- ផ្តល់សមត្ថកិច្ចដល់ក្រុមប្រឹក្សាឃុំរៀបចំផែនការគ្រប់គ្រង និង ប្រើប្រាស់ធនធានដី និង ធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងកាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ដីទៅថ្ងៃអនាគត ។
- មានការគាំទ្រកិច្ចអភិវឌ្ឍ សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាពខ្ពស់ និង សមធម៌ល្អអោយប្រសើរឡើង
- ចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ អោយស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- ជួយសំរេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ អោយស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិនៃភពផែនដី ។
- ដើម្បីឆ្លើយតបនូវសេចក្តីត្រូវការរបស់អាជ្ញាធរនានា និង របស់ប្រជាពលរដ្ឋនៅក្នុងឃុំទាំងមូលដែលមានធនធានស្រាប់ ។
- ជួយការពារធនធានដី និង ធនធានធម្មជាតិផ្សេងៗទៀត មិនអោយបាត់បង់គុណភាព និង មិនអោយប្រើប្រាស់ខុសទិសដៅ ។
- រួមចំណែកក្នុងការកំណត់គោលដៅ និង ការគ្រប់គ្រងដីរដ្ឋ ដែលមាននៅក្នុងឃុំអោយបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរបស់រដ្ឋ និងក្រុមប្រឹក្សាឃុំ។

ឃុំព្រងិលជាឃុំមួយដែលមានទីតាំងស្ថិតនៅត្រើយខាងកើត នៃស្ទឹងពោធិ៍សាត់មានចំងាយប្រហែល ០៧ គីឡូម៉ែត្រ ពីទីរួមស្រុកភ្នំក្រវាញ ឃុំព្រងិលមានព្រំប្រទល់ជាប់នឹង :

- ខាងកើតទល់នឹងឃុំត្នោតជុំ នឹងឃុំស្វាយស ស្រុកក្រគរ
- ខាងលិចទល់នឹង ឃុំសំរោងឃុំបាក់ចិញ្ចៀនស្រុក ភ្នំក្រវាញ
- ខាងជើងទល់នឹងសង្កាត់ ចំរើនផល នឹងសង្កាត់រលាប ក្រុងពោធិ៍សាត់
- ខាងត្បូងទល់នឹងឃុំលាច នឹងឃុំ សន្ទ្រែស្រុកភ្នំក្រវាញ

បើយើងពិនិត្យអោយបានជាក់ច្បាស់ផែនការប្រើប្រាស់ដីនៅក្នុង ឃុំព្រងិលវាជាទិសដៅមួយដ៏សំខាន់បំផុតសំរាប់ធ្វើការចង្អុលបង្ហាញដល់ក្រុមប្រឹក្សាឃុំក្នុងការរួមចំណែកដល់ការគ្រប់គ្រងធនធានដី និងកាប្រើប្រាស់ធនធានធម្មជាតិប្រកប ដោយសមភាព និងសមធម៌ខ្ពស់។ ជាការពិតបញ្ហាដីធ្លីគឺជាកត្តាស្នូល នៃការអភិវឌ្ឍសេដ្ឋកិច្ចសំរាប់ជីវភាពប្រជាពលរដ្ឋក្រោយពីមានផែនការប្រើប្រាស់ដីនេះរួចអាជ្ញាធរមូលដ្ឋាន កាន់ តែមានភាពកក់ ក្តៅសំរាប់ការ

គ្រប់គ្រង អោយបានគ្រប់ជ្រុងជ្រោយក្នុងការរៀបចំបញ្ចូល ផែនការអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ច ដល់ថ្នាក់មូលដ្ឋាន ថ្នាក់មូលដ្ឋាន ដោយបានធ្វើសមាហរកម្មផែនការថ្នាក់ស្រុក និងឈានទៅអនុម័តថ្នាក់ខេត្ត តាមនិតិវិធីដូចដែលធ្លាប់អនុវត្តក្នុងការកសាង ផែនការអភិវឌ្ឍសេដ្ឋកិច្ចកន្លងមក។ ទន្ទឹមនឹងនេះដែរ ដោយសារមានការខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងកំពង់ស្វះស្វែងគៀងគរម្ចាស់ជំនួយក្នុង និង ក្រៅប្រទេសជាពិសេសគឺមានអង្គការ ឌាណើឌា, ឌធីឌ,ណណោរិដ ដែលបានជួយទ្រទ្រង់ដល់កិច្ចសហប្រតិបត្តិការណ៍ ក្នុងគម្រោងសមាសភាគរៀបចំដែនដី ដែលអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

# ជំពូក១

# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅ

បើតាមការនិយាយតៗគ្នាមកដំណាលថា កាលពីយូរលង់ណាស់មកហើយ មានព្រះរាជាមួយអង្គចេញបរបាញ់សត្វហើយព្រះអង្គក៏វង្វេងផ្លូវបានមកឈប់សំរាកនៅក្នុងភូមិមួយពេលនោះ ព្រះអង្គរៀបចំតាំងព្រះពន្លាដោយហេតុប្រជារាស្ត្រពុំសូវយកចិត្តទុកដាក់គោរព និងស្រឡាញ់ព្រះអង្គព្រះអង្គក៏បានហៅឈ្មោះអ្នកភូមិនោះថា ជាអ្នកភូមិព្រងើយ។ លុះតមកទៀតភូមិព្រងើយបានប្រែក្លាយទៅជាភូមិព្រងិលដោយភ្ជាប់ឈ្មោះពីភូមិព្រងិលមកឃុំព្រងិលវិញរហូតមកដល់សព្វថ្ងៃនេះ ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| **ខេត្ត** | ពោធិ៍សាត់ | |
| **ស្រុក/ខ័ណ្ឌ** | ភ្នំក្រវាញ | |
| **ឃុំ/សង្កាត់** | ឈ្មោះ: ព្រងិល | លេខកូដ: ១៥០៤០៤ |
| **ចំនួនភូមិ** | ០៧ភូមិ: (ភូមិអូរបាក់ត្រា, ភូមិស្វាយប៉ាក, ភូមិព្រងិល, ភូមិអូរស្រាវ, ភូមិកំពែង, ភូមិសាយ, និង ភូមិសំរោងយា) | |

ឃុំព្រងិលមានទីតាំងស្ថិតនៅចំងាយប្រមានជា ២០ គីឡូម៉ែត្រពីក្រុងពោធិ៍សាត់ខាងត្បូងផ្លូវជាតិលេខ ០៥ ចុះតាម ផ្លូវលេខ១៤៨ថ្មី ( អតីតៈផ្លូវ ៥៦ ) ឆ្ពោះទៅស្រុកភ្នំក្រវាញ និងស្រុកវាលវែង ដោយធ្វើដំណើរឆ្លងកាត់ឃុំរលាប តាមផ្លូវក្រាលកៅស៊ូ ពីផ្សាលបំបែកលាច ដែលទើបអភិវឌ្ឍបានប្រមាណ ១១គីឡូម៉ែត្រ ត្រឹមវត្តបាក់ត្រា ក្រោមបន្តទៅទៀតជាផ្លូវគ្រួសក្រហមរហូតដល់ស្រុកភ្នំក្រវាញ និងស្រុកវាលវែង។ ឃុំព្រងិលមានផ្ទៃដីសរុបចំនួន ១១៥១,៦៨ គីឡូមែត្រការ៉េ ស្មើនឹង ១១៥១៦៨.៣១ ហិកតា ឃុំនេះមានព្រំប្រទល់ : ខាងជើងទល់សង្កាត់ចំរើនផល និង សង្កាត់រលាបក្រុងពោធិ៍សាត់, ខាងត្បូងទល់ ឃុំលាច និង ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ, ខាងកើតទល់ឃុំត្នោតជុំ និង ឃុំស្វាយស ស្រុកក្រគរ, ខាងលិចទល់ឃុំសំរោង និង ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ។




ផែនទីបង្ហាញទីតាំងរដ្ឋបាលឃុំព្រងិល

### ១.១.២ ប្រជាសាស្ត្រ

ក្នុងឃុំព្រងិលមានចំនួនគ្រួសារសរុបៈ ១៣១៩ គ្រួសារ ចំនួនប្រជាជនសរុបៈ ៩២៩៨ នាក់ ក្នុងនោះស្រ្តីចំនួន ៤៨៩៤ នាក់ និង បុរសចំនួន ៤៤០៤នាក់ មានដង់ស៊ីតេស្មើនឹង ០៨ នាក់ក្នុង ១ គីឡូម៉ែត្រការ៉េ ។ របាយប្រជាជនក្នុងឃុំព្រងិល ភាគច្រើនរស់នៅប្រហាក់ប្រហែលគ្នាតាមបណ្ដោយផ្លូវនៃភូមិនីមួយៗ ដោយឡែកមានតែភូមិព្រងិល និងអូរបាក់ត្រាទេ ដែលរស់នៅតាមលក្ខណៈប្រមូលផ្ដុំដោយសារចំនួនគ្រួសារច្រើន គ្មានដីទំនេរសំរាប់ចែកអោយកូនចៅដែលមានគូរស្រករថ្មីថ្មោង ទើបតែរៀបការរួច។ ប្រជាពលរដ្ឋរស់នៅក្នុងភូមិ ទាំង ០៧ ក្នុងឃុំព្រងិលភាគច្រើនប្រជាពលរដ្ឋកាន់សាសនាព្រះពុទ្ធ ដោយឡែកមានភូមិតែមួយគឺ ភូមិស្វាយប៉ាក មានប្រជាពលរដ្ឋខ្មែរឥស្លាមកាន់សាសនា មហាម៉ាត់ ចំនួន ៥៩៥នាក់ ស្មើ៤៧% ធៀបទៅនឹងប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិស្វាយប៉ាក ចំនួន ១២៧៣ នាក់ ។

**<u>តារាងស្ថិតិប្រជាជនឃុំព្រងិល ឆ្នាំ២០០៨ តាមក្រុមអាយុ</u> :**

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ៤៥៩ | ៥៨៧ | ១០៤៦ | |
| អាយុ ០៥ឆ្នាំ | ១៨៩ | ១៨០ | ៣៦៩ | អាយុចូលរៀនសាសាមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ៦១៥ | ៦៥៩ | ១២៧៤ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៣៣២ | ៣៥៨ | ៦៩០ | អាយុចូលរៀនអនុវិទ្យាល័យ |

| | | | | |
|---|---|---|---|---|
| អាយុពី ១៥-១៧ឆ្នាំ | ៤០៤ | ៤០៣ | ៨០៧ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៤៣៨ | ៥៧០ | ១០០៨ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ១៦៧៣ | ១៧៧២ | ៣៤៤៥ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ២៩៤ | ៣៦៥ | ៦៥៩ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | ៤៤០៤ | ៤៨៩៤ | ៩២៩៨ | |
| **ចំនួនគ្រួសារសរុប** | **១៩១៣** | | | |

### ១.១.៣ ភាពគ្មានដីធ្លី

- គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន ចំនួន ២២៥គ្រួសារ បច្ចុប្បន្នប្រភេទគ្រួសារបែបនេះនៅរដូវវស្សាត្រូវបាន ប្រកបរបរដោយការស៊ីឈ្នួលដកស្ទូង។ ចំណែកនៅរដូវប្រាំងវិញអ្នកខ្លះដើរស៊ីឈ្នួលច្រូតស្រូវ និង ខ្លះទៀត ចេញទៅរកការងារធ្វើការរោងចក្រ ឬ នៅតាមព្រំដែនប្រទេសជិតខាង ដើម្បីរកកំរៃយកមកដោះស្រាយ ជីវភាពគ្រួសារភាព ជាក់ស្តែងប្រជាពលរស់នៅក្នុងតំបន់ខ្ពង់រាប បុរសភាគច្រើនទៅកាប់ឈើអារឈើនៅ ភ្នំសំរាប់លក់អោយឈ្មួញអ្នកទាំងនោះយូរទើបមកស្រុកភូមិម្តងដើម្បីទិញម្ហូបអាហាររួចក៏ត្រឡប់ទៅវិញ។
- គ្រួសារដែលមានដីស្រែតិចជាង ០១ហិកតា: ចំនួន៦៣១គ្រួសារ ទាំងនេះបានខិតខំរកប្រាក់ចំណូលបន្ថែម ទៀតក្រៅពីការងារឈ្នួល ក្នុងរង្វង់គ្រួសារពួកគាត់។ ពេលទំនេរត្រូវបង្ខំចិត្តស៊ីឈ្នួល ដក ស្ទូង និង ច្រូត កាត់យកកំរៃដើម្បី បំពេញតម្រូវការទិញអង្ក ផ្គត់ផ្គង់អោយបានគ្រប់គ្រាន់ គ្រួសារប្រភេទនេះអ្នកខ្លះមាន គោ ក្របី រទេះ ធ្វើជា មធ្យោ បាយសំរាប់ដឹកជញ្ជូនផលអនុផលមកទុកដាក់ក្រោយពីប្រមូលផលរួច ក្រៅពីនេះ នៅមានគ្រួសារខ្លះប្រកបមុខរបរ កាប់អុស ឈើ មកកែឆ្នៃទៅធ្យូង ស្តុកទុករកទីផ្សារ។
- គ្រួសារដែលមិនមានដីលំនៅដ្ឋានផ្ទាល់ខ្លួនៈ.ចំពោះគ្រួសារដែលគ្មានដីលំនៅដ្ឋានផ្ទាល់ខ្លួនចំនួន១៧២គ្រួសារ ហើយគ្រួសារប្រភេទនេះតែងតែមានដីស្រែនៅឆ្ងាយដាច់ស្រយ៉ាលភាគច្រើនផ្លូវពិបាកធ្វើដំណើរទៅមក។ ម្យ៉ាង ដីលំនៅដ្ឋានរបស់ពួកគាត់ច្រើនតែសង់នៅតាមដីចំណើផ្លូវ ឬដីមាត់ស្ទឹង និង ខ្នងប្រឡាយហើយជា ប្រភេទ ដី មានទំហំតូច ព្រមទាំងមានដំណាំបន្លែរួមផ្សំនៅជុំវិញផ្ទះទៀតផង។

**តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់ :**

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ២២៥ | ១៧.០៥% | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ៦៣១ | ៤៧.៨៣% | |
| ៣ | គ្រួសារមិនមានដីលំនៅដ្ឋានផ្ទាល់ខ្លួន | ១៧២ | ១៣% | |



## ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋនៅក្នុងឃុំព្រងិលប្រមាណជា ៨៧.៤០% មានមុខរបរធ្វើស្រែវស្សា និង ស្រែប្រាំងដោយពឹងផ្អែកទាំង ស្រុងលើទឹកភ្លៀង។ ដោយឡែកគ្រួសារមួយចំនួនក៏មានប្រកបមុខរបរដាំដំណាំផ្សេងៗជាច្រើនមុខទៀត តែដាំដំណាំនេះពុំសូវទទួលបានផលល្អប៉ុន្មានទេ ចំណែកមុខរបររួមផ្សំប្រជាពលរដ្ឋឃុំព្រងិល បានខិតខំពង្រីកនូវមុខរបរបន្ថែមដូចជាៈ ប្រមូលទិញផលស្រូវ អេតចាយក្នុងមូលដ្ឋាន និងក្រៅមូលដ្ឋានមកស្តុកទុកលក់។ ជាមួយគ្នានេះដែរ នៅមានអ្នកដើរប្រមែប្រមូលទិញ ត្រី សាច់ បន្លែគ្រប់មុខ និង មានអាហាររួមផ្សំដូចជាៈ អំពៅ ឪឡឹក ដំឡូង យកទៅ លក់ខាងក្រៅមូលដ្ឋាន ខ្លះទៀត ធ្វើជាងផ្ទះ ជាង តុ ទូ សង្ហារឹម ជាងប៉ះកង់ ជាងជួសជុលម៉ូតូ ម៉ាញ៉ៃ និងទូរទស្សន៏.... ។ល ។

**<u>តារាងមុខរបបរសំខាន់ៗរបស់ប្រជាជនឃុំព្រងិល</u> :**

| ល.រ | ប្រភេទមុខរបបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ(%) | |
| ១ | មុរបរកសិកម្ម | ២២៦.៦៧២ | ៩៩.១៥ | |
| | ធ្វើស្រែជាចំបង | ១.៦៧២គ្រួសារ | ៨៧.៤០% | ស្រែវស្សានិងប្រាំង |
| | ដាំដំណាំរយៈពេលវែងជាចំបង | ១០២គ្រួសារ | ៥.៣៣% | ស្វាយ . ដូង . ខ្នុរ......... |
| | ដាំដំណាំរយៈពេលខ្លីជាចំបង | ៦គ្រួសារ | ០.៣១% | ដំឡូង.ពោត.សណ្តែក.ឪឡឹក |

| | | | | |
|---|---|---|---|---|
| | ដាំដំណាំបន្លែជាចំបង | ៨៥គ្រួសារ | ៤.៤៤% | ត្រសក់.ត្រប់.ស្ពៃ.ខាត់ណា |
| | មុខរបរចិញ្ចឹមសត្វជាចំបង | ៣២គ្រួសារ | ១.៦៧% | ជ្រូក.មាន់.ទា |
| ២ | មុខរបរធ្វើសិប្បកម្មជាចំបង | ២គ្រួសារ | 0.១០% | ឡាំង ប៉ោតទឹក, ជាងដែក |
| | សិប្បកម្មផលិតសង្ហារឹមឈើផ្ដៅឬស្សី | ២គ្រួសារ | 0.១០% | ជាងតុ ទូរ ចំលាក់ថ្មកែវ..... |
| | មុខរបរសេវាកម្មជាចំបង | ១០គ្រួសារ | 0.៥២% | រថយន្ត រត់តាក់ស៊ី. |
| | មុខរបរជំនួញ | ៦គ្រួសារ | 0.៣១% | ទិញស្រូវ.អំពៅ.សណ្ដែក... |
| | មុខរបរជាង | ១គ្រួសារ | 0.0៥% | ជាងផ្ទះ |
| | មុរបរដឹកជញ្ជូន | ៣គ្រួសារ | 0.១៦% | រយន្តស៊ីឈ្នួលដឹកជញ្ជូន..... |
| ៣ | មុខរបរផ្សេងៗ (ក្រៅពីខាងលើ) | 0៤គ្រួសារ | 0.២១% | លក់ដូរបន្តិបន្តួចតាមភូមិ..... |

ប្រភព: របាយការណ៍ ស្ដីពីស្ថានភាពឃុំព្រងិល ឆ្នាំ ២00៨

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំព្រងិលមានកំរិតសិក្សាពីបឋមរហូតដល់ថ្នាក់អនុវិទ្យាល័យ មានសាលាសរុបចំនួន 0៦ និងបន្ទប់សិក្សាចំនួន៣៤ ថ្នាក់៤៤ សិស្សានុសិស្សសរុប ១៧៤៩ នាក់ ក្នុងនោះសិស្សប្រុស១១៣៥នាក់ និងសិស្សស្រី៦១៤នាក់ (ត្រូវជា ៣៥% នៃសិស្សស្រី)។ កុមារគ្រប់អាយុដែលត្រូវចូលរៀនសរុបមាន ចំនួន ៣៧៨នាក់ អត្រាកុមារគ្រប់អាយុដែលមិនបានចូលរៀនមានចំនួន ៥0នាក់ ជាក់ស្តែងក្នុងឃុំនេះមិនទាន់ខ្វះខាតថ្នាក់រៀនទេ។ ប៉ុន្តែអត្រាសិស្សមិនបានចូលរៀនកើនឡើងខ្ពស់បណ្ដាលមកពីៈ បញ្ហាខ្វះគ្រូបង្រៀនពិសេសនៅកំរិតអនុវិទ្យាល័យ ព្រោះនៅក្នុងឃុំនេះមានកំរិតសិក្សាពីបឋមដល់អនុវិទ្យាល័យដាច់ដោយឡែកពីគ្នា។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននៅមិនទាន់បានផ្តល់លទ្ធភាពគ្រប់គ្រាន់អោយកុមារអាយុ 0៥ឆ្នាំ ចូលសិក្សា ១00% នៅឡើយទេ។ ព្រោះអាណាព្យាបាលរបស់សិស្សយល់ឃើញថា កូនគាត់នៅតូចពេកពុំទាន់ដឹងអី គ្មានអ្នកណាជូនទៅរៀន និងជូនមកវិញទេ ដោយក្រុមគ្រួសារជាប់រវល់បង្ករបង្កើតផល ។

ចំពោះសិស្សដែលបានរៀនចប់ ពីសាលាអនុវិទ្យាល័យក្នុងឃុំត្រូវជួបបញ្ហាក្នុងការសិក្សាបន្តនៅសាលាវិទ្យាល័យស្រុកភ្នំក្រវាញដែលមានចំងាយប្រមាណជា0៩គ.ម ហេតុដូច្នេះ ហើយចំពោះសិស្សដែលគ្មានធន់ធានគ្រប់គ្រាន់ត្រូវបោះបង់ចោលការសិក្សាទាំងស្រុង។ សូមបញ្ជាក់ថាសាលារៀនឃុំព្រងិលពីមុនជាសាលាបឋមសិស្សាធ្វើពីឈើតែបច្ចុប្បន្នបានប្តូរមកជាអាគារធ្វើពីថ្មវិញរួមទាំងសាលាអនុវិទ្យាល័យកំពែងផង ។

**តារាង ស្ថិតិសាលា និងចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨ :**

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារ | សិស្ស | សិស្សស្រី | |
| ថ្នាក់មត្តេយសិក្សា | 0 | 0 | 0 | ៣៦៩ | 0 | 0 | ១00% |
| ថ្នាក់បឋមសិក្សា | ០៥ | ៣៤ | ៤៤ | ១២៧៤ | ១១៣៥ | ៦១៤ | ១១% |
| ថ្នាក់អនុវិទ្យាល័យ | ០១ | ០៦ | ០៦ | ៩៤៦ | ៦០៧ | ៣៣៩ | ១២% |
| ថ្នាក់វិទ្យាល័យ | 0 | 0 | 0 | ៨០៧ | ៥៩៦ | ៣១៦ | ២៦% |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំព្រងិល ឆ្នាំ ២០០៨




## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

សេវាសុខភាពនៅឃុំព្រងិល បច្ចុប្បន្នពុំទាន់បានបំពេញតាមតម្រូវការរបស់ប្រជាពលរដ្ឋទូរទាំងឃុំបាន នៅឡើយទេ។ ព្រោះភូមិមួយចំនួននៅឆ្ងាយពីមណ្ឌលសុខភាព ហើយមិនអាចធ្វើដំណើរបានលឿនដោយសារផ្លូវពិបាក ដូចជាភូមិសាយដាច់ស្រយាលជាងគេ។ ស្ថិតក្នុងស្ថានភាពបែបនេះឃុំព្រងិលពុំទាន់មានប៉ុស្តិ៍សុខភាពតាមភូមិនៅឡើយទេ សំរាប់ជួយសំរួលដល់ទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋបន្ថែមទៀត។ ចំងាយជាមធ្យមពីភូមិទៅ

មណ្ឌលសុខភាពពី ០៤ គ.ម ទៅ ០៥ គ.ម។ យោងតាមស្ថានភាពភូមិសាស្ត្រនៃឃុំព្រងិលដែលមានប្រជាពលរដ្ឋរស់នៅក្នុងភូមិសាយដាច់ដោយឡែកពីគេ និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំបណ្ដាលអោយមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្ដល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។

**<u>តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ</u> :**

| ល.រ | មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០១ | ០៣ | ០៨ | ០៣ | ០ |
| ២ | ប៉ុស្តិសុខភាពភូមិ | ០ | ០ | ០ | ០ | ២២ |




## ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ប្រភពនៃការផ្ដល់សេវាកម្មទឹកស្អាត ពុំទាន់បានគ្រប់គ្រាន់តាមសេចក្ដីតម្រូវការរបស់ប្រជាពលរដ្ឋដើម្បីប្រើប្រាស់នៅក្នុងឃុំព្រងិលបានឡើយ ថ្វីត្បិតតែមានស្ទឹងក៏គ្មានដំណោះស្រាយសំរាប់នាំប្រភពទឹកពីស្ទឹងបានដែរ។ ព្រោះស្ទឹងនៅឆ្ងាយពីភូមិ ដូច្នេះហើយប្រជាពលរដ្ឋមួយចំនួនធំ នៅតែមានការខ្វះខាតនូវទឹកស្អាតប្រើប្រាស់ដដែល មានតែប្រជាពលរដ្ឋភាគតិចប៉ុណ្ណោះ ដែលរស់នៅតាមដងស្ទឹងអាចមានលទ្ធភាពបង្ករបង្កើនផលជាលក្ខណៈគ្រួសារ និងប្រើប្រាស់ទឹកយកពីស្ទឹង។

ចំណែកឯ បឹងកំពែងវិញ មានប្រភពទឹកគ្រប់គ្រាន់តែខ្វះភាពអនាម័យតាមបរិវេណមាត់បឹងដូចជា មានមនុស្ស ចុះងូតទឹកក្នុងបឹង អោយគោ ក្របី ចុះផឹកទឹក និងដេកមិនតែប៉ុណ្ណោះ ថែមទាំងយកទីធ្លាមាត់បឹងធ្វើជាក្រោលគោ ក្របី និងទ្រុងជ្រូកទៀតផង ។ល ។ ម្យ៉ាងវិញទៀតអណ្តូងទឹកស្រះទឹករបស់ប្រជាពលរដ្ឋដែលនៅឆ្ងាយពីប្រភពទឹក មិនអាចរក្សាទឹកទុកប្រើប្រាស់បានយូរទេ ។ ចំពោះអណ្តូងស្នប់ដែលខូចទុកចោលយូរមិនបានជួសជុលរហូតមកដល់ពេលនេះ នៅតែពុំអាចជួសជុលបាន ។ ដោយឡែកអណ្តូងលូ និងអណ្តូងដៃមួយចំនួនគ្មានទឹក តែបើមានទឹក ក៏ទឹកនោះមិនអាចប្រើប្រាស់បានដែរ ព្រោះមានការបាក់ដីស្រុតលូដូច្នេះត្រូវស្តារឡើងវិញទាំងស្រុង ។

**តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំព្រងិល :**

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ | ១១៣ | ៥២ | ៤២ | គ្មានទឹកនៅរដូវប្រាំង ៦០ |
| ២ | អណ្តូងលូ | ៩១ | ៤២ | ៥៤ | គ្មានទឹកនៅរដូវប្រាំង ៤៩ |
| ៣ | អណ្តូងដៃមិនដាក់លូ | ២០ | ១៤ | ០ | គ្មានទឹកនៅរដូវប្រាំង ០៦ |
| ៤ | ត្រពាំង/ស្រះ | ៤៣ | ១០ | ២៣ | គ្មានទឹកនៅរដូវប្រាំង ៣៣ |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំ ព្រងិល ឆ្នាំ ២០០៨





## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំព្រងិលជាឃុំមួយស្ថិតនៅជាប់ផ្លូវលេខ ១៤៨ ថ្មី ( អតីតផ្លូវ ៥៦) មួយភាគធំជាវាលខ្ពង់រាបជើងភ្នំ ដែលជាព្រៃស្រោងក្រាស់ផ្នែកខាងត្បូង ខាងជើង និង ខាងលិចជាដីស្រែវស្សាលាយផ្ទះ មួយភាគខាងកើតសំបូរទៅដោយ ដីព្រៃហ៊ុំពាត់ដោយភ្នំ ។

ឃុំព្រងិលស្ថិតក្នុងរយៈកំពស់ ប្រែប្រួលពីៈ

- រយៈកំពស់ពី ១២ ទៅ ២៦ ស្ថិតនៅទិសខាងជើងតាមបណ្ដោយព្រំប្រទល់ជាមួយសង្កាត់ចំរើនផលឈៀងខាងលិច ។
- រយៈកំពស់ពី ២៦ ទៅ ៤៧ ស្ថិតនៅទិសខាងជើងតាមបណ្ដោយព្រំប្រទល់សង្កាត់រលាបឈៀងខាងត្បូង ។
- រយៈកំពស់ពី ៤៧ ទៅ ៦៥ ស្ថិតនៅទិសខាងជើងតាមបណ្ដោយព្រំប្រទល់ឃុំបាក់ចិញ្ចៀនឈៀងខាងលិច
- រយៈកំពស់ពី ៤០២ ទៅ ១៧៥៦ ស្ថិតនៅតាមបណ្ដោយព្រំប្រទល់ទិសខាងកើត ឈៀងខាងត្បូងបណ្ដោយព្រំឈៀងខាងលិច ។




ផែនទីរយៈកំពស់ ឃុំព្រងិល

### ១.២.២ អាកាសធាតុ

- កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ : ១២០០-១៤០០ ម.ម ទិន្នន័យនេះជាទិន្នន័យរួមសំរាប់ខេត្តពោធិ៍សាត់ ហើយបច្ចុប្បន្នមិនទាន់មានទិន្នន័យដោយឡែកសំរាប់ឃុំនៅឡើយ ។
- រយៈពេលនៃរដូវប្រាំង ០៦ខែ ចាប់ពី ខែមករា ដល់ ខែមិថុនា ចំពោះការប្រែប្រួលមានកើតលំអៀងតិចតួចដោយជួនកាលអាចរាំងពាក់កណ្ដាលខែតុលា ដល់ ខែធ្នូ ។

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

កំណាត់ផ្លូវគ្រួសក្រហម ពីឃុំព្រងិលដល់ព្រំប្រទល់ឃុំលាច ចំនួន០៩គីឡូម៉ែត្រ ដែលជាផ្លូវលេខ ១៤៦ ថ្មីសព្វថ្ងៃពុំទាន់ក្រាលកៅស៊ូនៅឡើយទេ អនាគតផ្លូវនេះ និង ក្រាលកៅស៊ូជាគម្រោងរបស់ខេត្ត ។

**ផ្លូវក្រាលគ្រួសក្រហម:** ផ្លូវលំក្រាលគ្រួសក្រហមនៅក្នុងឃុំព្រងិលមានចំនួន ៨ ខ្សែប្រវែងសរុប១៦.៧០០ ម៉ែត្រ ហើយត្រូវបានជួសជុល ១២.៤០០ម៉ែត្រ និងផ្លូវដែលត្រូវលើកថ្មី ១៤.២០០ម៉ែត្រ ផ្លូវនេះបានជួយលើកស្ទួយជីវភាពប្រជាជនបានធូរស្រាលមួយកំរិត និង ងាយស្រួលដឹកជញ្ជូនផលិតផលកសិកម្មមកកាន់ទីផ្សារបានយ៉ាងឆាប់រហ័ស ។

**ផ្លូវលំដីស :** ជាផ្លូវដែលបានលើកដីសរួចជាស្ថាពរ មានចំនួន០៨ ខ្សែ សរុបប្រវែង ១៤.២០០ម៉ែត្រហើយ និង បានជួសជុលចំនួន ៨.៥០០ ម៉ែត្រ ហើយត្រូវបានលើកថ្មីចំនួន១៦.០០០ម៉ែត្របន្ថែមទៀត ។

**ផ្លូវលំធម្មតា (ផ្លូវរទេះ):** ពុំទាន់លើកជាតួផ្លូវនៅឡើយទេមានចំនួន ០៤ខ្សែ ប្រវែង ១៨.៧៥០ម៉ែត្រ និងត្រូវ លើកឡើងវិញទាំងអស់។

 

## ១.៣ ស្ថានភាព នៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាព នៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងឃុំព្រងិលអាចចែកចេញជា ២ ប្រភេទ គឺប្រភេទការប្រើប្រាស់ដីសាមញ្ញ ៥ចំណាត់ថ្នាក់រួមមាន: ដីលំនៅដ្ឋានភូមិ( មានដីភូមិ ដីភូមិលាយសួនដំណាំ និងតំបន់ទីប្រជុំជន), ដីកសិកម្ម (ដីស្រែ និងចំការដំណាំគ្រប់ប្រភេទ ), ព្រៃឈើ ( មានព្រៃឈើគ្រប់ប្រភេទ), វាលស្មៅ វាលស្បូវ( វាលស្មៅដុះតាមមាត់ទឹក វាលស្មៅដុះលើចំការចាស់ និងវាលស្បូវ), ប្រភពទឹក(បឹង ស្ទឹង អូរ...), ដីគ្មានរុក្ខជាតិគ្របដណ្តប់( ខ្សាច់ ថ្ម...) និង ប្រភេទការប្រើប្រាស់ដីលំអិត ដែលមានចំនួន ២៤ ចំណាត់ថ្នាក់ ដែលមានបង្ហាញនៅក្នុងតារាងខាងក្រោម:

**<u>តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត</u> :**

| ល.រ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ ( ហត) | ចំណាត់ថ្នាក់មូលដ្ឋាន |
|---|---|---|---|
| ១ | ដីលំនៅដ្ឋាន ភូមិ | ៥៣០,៩៧ | ផ្ទះជាប់ទីសំណាប ឈើហូបផ្លែ ដូង ទៀប ខ្នុរ |

| | | | |
|---|---|---|---|
| ២ | ដីស្រែវស្សា | ៣.០០១,៦២ | ធ្វើស្រែវស្សានិង(ស្រែប្រាំងជិតប្រភពទឹក) |
| ៣ | ដីស្រែលាយភូមិ | ១.១៣១,០២ | ធ្វើស្រែខាងក្រោយផ្ទះ រឺ ខាងមុខផ្ទះ |
| ៤ | ដីចំការស្រូវ | ១.១៣១,០២ | ដាំស្រូវ និង បន្លែឆ្លាស់មុខ |
| ៥ | ដីចំការដំណាំ | ១៨៤,២១ | ដាំល្ពៅ ល្ហុង សណ្តែកត្រសក់ ឪឡឹក ស្វាយ |
| ៦ | ដីចំការដំណាំក្បែរប្រភពទឹក | ៤៩៦,៩៦ | ក្រូច អំពៅ ស្វាយ ចំការខ្នុរ ចេក |
| ៧ | ដីកសិកម្មពនេចរ | ២០,៦១ | ចំការធ្វើមួយឆ្នាំទុកចោលមួយឆ្នាំ |
| ៨ | ដីកសិកម្មពនេចរបោះបង់ចោល | ៩៤៥,៩៩ | ធ្វើមួយឆ្នាំរឺពីរឆ្នាំរួចបោះបង់ចោល |
| ៩ | ដីព្រៃស្រោងសើម | ៣៣.៦៤៦,០៨ | ព្រៃក្រាស់ដើមឈើធំៗ (ឈើចំរុះ) |
| ១០ | ដីព្រៃរបោះ | ៥៩.៧៧០,១៣ | ដើមឈើមួយៗ (ឈើចំរុះ) |
| ១១ | ដីព្រៃរបោះ(ស្តើងស្ងួត) | ៣១៧,៩៤ | ដើមឈើមួយៗ |
| ១២ | ដីព្រៃចំរុះ | ៥.៨៨៩,៤៧ | ដីព្រៃឈើគ្រប់ប្រភេទ |
| ១៣ | ព្រៃដុះតាមមាត់ទឹក | ៣.៥៩៨,៦៧ | ព្រៃដែលមានពណ៌បៃតងគ្រប់រដូវ |
| ១៤ | ព្រៃដុះឡើងវិញ | ១២០,៨១ | ព្រៃដែលលូតលាស់ក្រោយពេលកាប់ឆ្ការ |
| ១៥ | ចំការបោះបង់ចោលដុះស្មៅ | ៧១៨,៧៧ | វាលស្មៅដែលដុះលើដីចំការចាស់ |
| ១៦ | វាលស្មៅលិចទឹក | ៥៣,៣៣ | វាលស្មៅដុះតាមមាត់បឹង និងលិចទឹកជំនន់ |
| ១៧ | ព្រៃគុម្ពោធ | ៣៧០,៥៦ | ជាព្រៃស្តើងដុះជិតដុប ប្រភេទកូនឈើតូចៗ |
| ១៨ | ចំការបោះបង់ចោលដុះព្រៃគុម្ពោធ | ២២៩៧,៧១ | ព្រៃដែលដុះឡើងវិញ លើដីចំគារចាស់ |
| ១៩ | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ១២៩២,៩៧ | ប្រភេទកូនឈើតូចៗ លាយដើមឈើធំៗ |
| ២០ | បឹង | ២១,០៥ | បឹងមួយចំនួនដែលទទួលទឹកពីអូរ ស្ទឹង |
| ២១ | បឹងមានទឹកជាប្រចាំ | ១០,១៥ | បឹងនៅក្នុងឃុំ មាន បឹងកំពែង និង បឹងស្លា |
| ២២ | បឹងមានទឹកនៅរដូវវស្សា | ៣,២១ | បឹងនៅក្នុងឃុំ ដែលបានរីងរាក់នៅរដូវប្រាំង |
| ២៣ | ទន្លេ ស្ទឹង អូរ | ៥៤,០៩ | បឹង-អូរ-ស្ទឹង |
| ២៤ | ខ្សាច់ | ៣៨,៦៩ | ដីខ្សាច់ចំណីស្ទឹង |
| | **សរុប** | **១១៥.១៦៨.៣១** | |

ប្រភព : (លំអិតអំពីប្រភេទនៃការប្រើប្រាស់ដីនិមួយៗ មានពិពិណនាលំអិតនៅក្នុងឧបសម្ព័ន្ធ ១ និងមានភ្ជាប់ជា មួយនូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ ខ្នាត អា៣)

### ១.៣.២ ស្ថានភាព នៃការកាន់កាប់គ្រប់គ្រងដី

ស្ថានភាពនៃការកាន់កាប់ និងគ្រប់គ្រងដីនៅក្នុងឃុំព្រងិលក្រៅពីដីលំនៅដ្ឋានដីស្រែចំការដែលជាកម្មសិទ្ធិរបស់ឯកជន គឺសុទ្ធសឹងតែជាដីសាធារណៈរបស់រដ្ឋ និង ដីដែលប្រជាពលរដ្ឋមិនអាចប្រើប្រាស់បានដែលស្ថិតនៅក្រោមរូបភាពមួយចំនួនដូចជា:

- តំបន់ការពារ : តំបន់ជំរកសត្វព្រៃភ្នំឱរ៉ាល់
- តំបន់ដីសម្បទាន : តំបន់ដីសម្បទានសេដ្ឋកិច្ចភាភីមុិច
- តំបន់ដីមីន : ដីសង្ស័យមានមីន និងគ្រាប់មិនទាន់ផ្ទុះ
- តំបន់ទេសចរណ៍: តំបន់រមនីយដ្ឋានទេសចរណ៍ច្រកល្បៀង
- តំបន់សហគមន៍ព្រៃឈើ: កំពែង, អូរបាក់ត្រា, អូរស្រាវ, ព្រងិល, សំរោងយា១, ស្វាយប៉ាក

នៅក្នុងដំណាក់កាលបច្ចុប្បន្ន ឃុំបញ្ហាចោទលើស្ថានភាពកាន់កាប់ដីគឺ ការកាប់ទន្ទ្រានយកដីព្រៃដើម្បីលក់ដែលបានរំលោភទៅលើដីរបស់ប្រជាជនក្នុងឃុំ និង ដីសាធារណៈរបស់រដ្ឋ បង្កឱ្យមានទៅជាបញ្ហាទំនាស់ដីធ្លី រវាងប្រជាជនក្នុងឃុំ ជាមួយនឹងជនល្មើសដែលមកពីខាងក្រៅ និង អ្នកមានអំណាច មានធនធានមួយចំនួនតូច ។

**តារាងសង្ខេបស្ថានភាពនៃការ កាប់កាប់ និងគ្រប់គ្រងដី :**

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី ( ហ.ត) | ផ្សេងៗ |
|---|---|---|---|
| ១ | តំបន់ការពារ | ៥២.២២១,៧៦ | ១ កន្លែង មួយចំណែកស្ថិតនៅក្រៅឃុំ |
| ២ | តំបន់ដីសម្បទានសេដ្ឋកិច្ច | ៥៧.៤១២,១១ | ១កន្លែង មួយចំណែកស្ថិតនៅក្រៅឃុំ |
| ៣ | ដីសង្ស័យមានមីន និងគ្រាប់មិនទាន់ផ្ទុះ | ៨,៧៩ | ៣កន្លែង ស្ថិតនៅក្នុងឃុំទាំងស្រុង |
| ៤ | តំបន់ទេសចរណ៍ | ១៤៩,២២ | ១កន្លែង ស្ថិតនៅក្នុងឃុំទាំងស្រុង |
| ៥ | សហគមន៍ព្រៃឈើ | ១.៦៦៨,៨០ | ៦ កន្លែង ស្ថិតនៅក្នុងឃុំទាំងស្រុង |
| ៦ | ដីផ្សេងៗទៀត | ៣៧០៧,៦៣ | |

### ១.៣.៣ ផលិតកម្មកសិកម្ម

ប្រជាពលរដ្ឋនៅក្នុងព្រងិល ប្រមាណជា ៧៥% មានមុខរបរធ្វើកសិកម្ម ជាពិសេសដំណាំស្រូវវស្សា ដោយពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ។ នៅក្នុងការប្រើប្រាស់ធនធានទឹកដើម្បីបំរើផលប្រយោជន៍ដល់វិស័យកសិកម្ម ឃើញថាឃុំព្រងិលមានការខ្វះខាតនូវប្រព័ន្ធស្រោចស្រព្វនៅឡើយ ចំណែកប្រឡាយដែលមានស្រាប់ ០៣ខ្សែ មានប្រវែង ៥០០០ ម៉ែត្រ រឹងរាក់ត្រូវបានប្រជាពលរដ្ឋរំលោភយកធ្វើស្រែ ។ ពិតមែនតែឃុំមានភូមិសាស្ត្រជាប់នឹងស្ទឹងបឹងកំពែង ដែលជាប្រភពទឹកដ៏សំខាន់មួយសរាប់ផ្គត់ផ្គង់ទឹកដល់ការស្រោចស្រព្វក្នុងការបង្កបង្កើនផលដំណាំ តែជា

អកុសលឃុំនេះ ពុំមានលទ្ធភាពដោះស្រាយនូវទំនប់ស្ទាក់ទឹក រឺ ប្រពន្ធ័ធារាសាស្ត្រដើម្បីនាំយកប្រភពទឹកសំរាប់ស្រោចស្រព្វទៅលើផ្ទៃដីកសិកម្មដែលមាន។ ដូច្នេះផលិតកម្មកសិកម្មស្រូវក្នុងឃុំព្រងិលធ្វើបានត្រឹមតែមួយរដូវក្នុងមួយឆ្នាំតែប៉ុណ្ណោះ ក្នុងនៅរដូវវស្សា។ ឆ្នាំ២០០៨ ដីស្រែចំនួន ៣០០.១ ហិកតាធ្វើបានតែ ១៦០០ហិចតាប៉ុណ្ណោះ ហើយទិន្នផលស្រូវទទួលបាន១.៦តោនក្នុង ០១ ហិកតា ស្មើនិង ២.៥៦០ តោននៅក្នុងឆ្នាំ។

ក្នុងឆ្នាំ ២០០៨ ឃុំមានផ្ទៃ ដីចំការសំរាប់ដាំដំណាំសណ្តែកបាយ និង សណ្តែកដី ១០ ហិកតា ចែកជាពីរផ្នែកមួយផ្នែកសំរាប់ដំណាំសណ្តែកបាយ និងមួយផ្នែកទៀតសំរាប់ដំណាំសណ្តែកដី ហើយបានធ្វើការដាំដុះទៅលើផ្ទៃដីទាំងអស់ តែលទ្ធផលដែលទទួលពីដំណាំសណ្តែកបាយបាន ១០តោន ក្នុងមួយរដូវដាំដុះក្នុងឆ្នាំលើផ្ទៃដីសរុបចំនួន ០៥ហិកតា ជាទិន្នផល០២តោនក្នុងមួយហិកតា ដោយឡែកដំណាំសណ្តែកដីវិញបានដាំលើផៃដីសរុបចំនួន ០៥ ហិកតាដែល ទទួលបានផលសរុបត្រឹមតែ ២.៥០តោន មួយរដូវកាលដាំដុះក្នុងឆ្នាំគិតជាទិន្នផល ០.៥តោន ក្នុងមួយហិកតា។ ដោយប្រជាពលរដ្ឋមានការយល់ដឹងពីអត្ថប្រយោជន៍ដំណាំដំឡូងមី និង ដំឡូងជ្វាងាយស្រួលរកទីផ្សារផងនោះ ដូច្នេះពលរដ្ឋនៅក្នុងភូមិឃុំបានបង្កើននូវការដាំដុះទៅលើផ្ទៃដីសរុប ០៨ហិកតា ទទួលបានទិន្នផលសរុប ២៤ តោនមួយរដូវកាលដាំដុះក្នុងឆ្នាំជាទិន្នផល ០៣តោ នក្នុងមួយហិកតា រីឯដំណាំពោតវិញ ជាដំណាំអាហាររួមផ្សំបានដាំលើផ្ទៃដីសរុបទាំងពីរ ០២ ហិកតាទិន្នផលសរុបទទួលបាន ០៤ តោន ដោយផលក្នុងមួយហិកតា ០២តោន។

**<u>តារាងប្រភេទដំណាំកសិកម្ម សំខាន់ៗ និងទិន្នផលទទួលបាន</u> :**

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី (ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប (ហត) | ដាំបាន (ហត) | ផលសរុប (តោន) | ទិន្នផល (ត/ហត) |
| ១ | ដំណាំស្រូវវស្សា (បើគ្មាន Pheapimex) | ៣០០១ | ១៦០០ | ២៥៦០ | ១,៦ |
| | ដំណាំស្រូវវស្សា (បើមាន Pheapimex) | ២៥៦២ | ១៦០០ | ២៥៦០ | ១,៦ |
| ២ | ដំណាំសណ្តែកបាយ | ០៥ | ០៥ | ១០ | ០២ |
| ៣ | ដំណាំសណ្តែកដី | ០៥ | ០៥ | ២.៥០ | ០,៥ |
| ៤ | ដំណាំដំឡូងមី/ជ្វា | ០៨ | ០៨ | ២៤ | ០៣ |
| ៥ | ដំណាំពោត | ០២ | ០២ | ០៤ | ០២ |

<u>ប្រភព</u>: របាយការណ៍របស់ឃុំព្រងិល (ទិន្នផលស្រូវមធ្យម០១ឆ្នាំចុងក្រោយ: ២,៥ត/ហត)

ការបង្កបង្កើនផលបច្ចុប្បន្នក្នុងឃុំព្រងិល ដូចបានលើកឡើងខាងលើភាគច្រើនគឺ មានការពឹងផ្អែកទៅលើទឹកភ្លៀងទាំងស្រុងការទទួលផលពីការដាំដុះមានលក្ខណៈជាយថាផលមិនបានទិន្នផលទៀងទាត់តាមតំរូវការឡើយ ទន្ទឹមនឹងនោះ ប្រសិនបើឃុំព្រងិលមានការស្ថាបនាទំនប់ស្ទាក់ទឹកចាស់នៅទួលរវៀង និងជីកប្រឡាយ ឬស្តារបន្ថែម

ទៀតនោះ សក្កានុពលនៃការស្រោចស្រព្វក្នុងឃុំគឺ មានលក្ខណៈអំណោយផលជាច្រើន និងអាចបង្កើនការដាំដុះបាន ច្រើនរដូវ។ បច្ចុប្បន្នឃុំព្រងិល មានប្រពន្ធ័ប្រឡាយស្រោចស្រព្វចំនួន ០៣ខ្សែ ស្ថិតក្នុង ភូមិ០៤ គឺ ភូមិស្វាយប៉ាក អូរស្រាវ, ព្រងិល និង ភូមិកំពែង ដែលមានប្រវែងសរុបចំនួន ៥០០០ម៉ែត្រ មានទឹកនៅរដូវវស្សាតែប៉ុណ្ណោះ។ ប្រឡាយគ្រោងស្តារមានប្រវែង ២៤០០ម៉ែត្រ ដែលស្ថិតនៅក្នុង ភូមិព្រងិល ភូមិស្វាយប៉ាក និង ភូមិសំរោងយា គំរោងស្តារប្រឡាយនេះ អាចជួយដល់កសិករដែលមានស្រែឆ្ងាយពីប្រភពទឹក ជាការស្តារទៅលើប្រឡាយមេដែល មានស្រាប់សព្វថ្ងៃកំពុងតែរីងរាក់មិនអាចនាំប្រភពទឹកចូលទៅក្នុងស្រែបាន ទោះជាយ៉ាងណាក៏ប្រព័ន្ធស្រោចស្រព្វ ទាំងនេះនៅតែមិនអាចផ្តល់ប្រភពទឹកគ្រប់គ្រាន់បានដែរ។

**<u>តារាងក្រឡាផ្ទៃតាមផលិតភាពដី និង ការប្រើប្រាស់ និងផលិតផល</u> :**

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ ហិចតា |
|---|---|---|---|
| **១** | **ដីមានផលិតភាពខ្ពស់** | **មមោគអាចម៍កណ្តុរ(ដីកណ្តៀង)** | **១០.៨៦២.១៣** |
| | ដីស្រែវស្សា | ស្រូវសូម៉ាលី, ផ្កាម្លិះ, ផ្កាខ្ញី ផ្កាដូង........ | ១០.៧៦ |
| | ដីស្រែលាយភូមិ | ធ្វើស្រែខាងក្រោយផ្ទះ រឺ ខាងមុខផ្ទះ | ៣៩២.៣៩ |
| | ដីព្រៃរបោះ | ដើមឈើមួយៗ (ឈើចំរុះ) | ៨.២៣១.៤៨ |
| | ដីព្រៃដុះឡើងវិញ | ដីកាប់ចំការទុកចោល | ៥០០.៤៩ |
| | ចំការបោះបង់ចោលដុះស្មៅ | ដីចំការទុកចោល | ៤៤២.៩៩ |
| | ចំការបោះចោលដុះព្រៃគុម្ពោធ | ដីចំការទីទួល (ខ្ពស់រាប) | ២៩២.៧៩ |
| | ព្រៃគុម្ពោធលាយដើមឈើធំៗ | ដីក្បាលស្រែ | ៩៩១.២៣ |
| **២** | **ដីមានផលិតភាពមធ្យម** | **ដីមមោគល្បាយខ្សាច់** | **៣.១២៤.០៤** |
| | ដីលំនៅដ្ឋានភូមិ | ដីមមោគល្បាយខ្សាច់ ខ្មៅ | ១៧២.២០ |
| | ដីស្រែលាយភូមិ | ដីល្បាប់ខ្សាច់ | ២៤២.៧៨ |
| | ដីស្រែវស្សា | ដីល្បាប់ខ្សាច់ | ១.៦៥៨.៨៤ |
| | ដីចំការស្រូវ | ដាំស្រូវ ពោត និងដំណាំឆ្លាស់ | ៩៥.៦២ |
| | ដីចំការដំណាំស្រោចស្រព្វ | ចំការជិតប្រពភទឹក | ៤៩៦.៩៦ |
| | ដីព្រៃរបោះ | ដើមឈើមួយៗ (ឈើចំរុះ) | ៧១.៣៥ |
| | ដីចំការបោះបង់ចោលដុះស្មៅ | ដីចំការទុកចោលយូរ | ១២៦.៣៩ |
| | វាលស្មៅលិចទឹក | ដីវាលទំនាប | ៥៣.៣៣ |

| | | | |
|---|---|---|---|
| | ដីចំការបោះបង់ចោលដុះព្រៃគុម្ពោធ | ដីចំការទីទួល(ខ្ពស់រាប) | ៩៨.១០ |
| | ដីបឹង | ដីល្បាប់ភក់ត្រឹផ្តក់, រ៉ស់ ក្រាញ់ តាអោន.... | ២០.៧៧ |
| | ដីបឹងមានទឹកជាប្រចាំ | ដីអិដ្ឋត្រីផ្តក់ រ៉ស ក្រាញ់ អណ្តែង ឆ្តាំង..... | ៦.៧៤ |
| | ដីស្ទឹងអូរ | ល្បាប់ភក់លាយខ្សាច់ និងត្រីចំរុះ | ៤២.២៧ |
| | ដីខ្សាច់ | ល្បាយខ្សាច់សរសុទ្ធ | ៣៨.៦៩ |
| **៣** | **ដីមានផលិតភាពទាប** | **ដីល្បាយខ្សាច់** | **១០១.១៨២.១** |
| | ដីលំនៅដ្ឋានភូមិ | ល្បាយខ្សាច់ | ៣៩៨.៧៧ |
| | ដីស្រែលាយភូមិ | ខ្សាច់ចំរុះ | ៤៩៥.៨៦ |
| | ដីស្រែវស្សា | ដីល្បាយខ្សាច់ចំរុះ | ១.៣៣១.៩៧ |
| | ដីចំការដំណាំ | ដីល្បាយខ្សាច់ចេក ស្វាយ ទាប | ១៨៤.២១ |
| | ដីចំការស្រូវ | ដាំស្រូវ ពោត និងដំណាំឆ្លាស់ | ៥៩៧.៦៨ |
| | ដីចំការបោះបង់ ដុះព្រៃគុម្ពោធ | ដីចំការទីទួល (ខ្ពស់រាប) | ១.៩០៦.៨១ |
| | ដីកសិកម្មពនេចរ | ចំការធ្វើមួយឆ្នាំទុកចោលមួយឆ្នាំ | ២០.៦១ |
| | ដីកសិកម្មពនេចរបោះបង់ចោល | ធ្វើមួយឆ្នាំពីរឆ្នាំរួចបោះបង់ចោល | ៩៤៥.៩៩ |
| | ដីព្រៃស្រោងសើម | ព្រៃក្រាស់ដើមឈើធំៗ (ឈើចំរុះ) | ៣៣.៦៤៦.០៨ |
| | ដីព្រៃរបោះ | ដើមឈើមួយៗ (ឈើចំរុះ) | ៥១.៤៦៧.៣១ |
| | ដីព្រៃរបោះ (ស្តើង ស្ងួត) | ដើមឈើមួយៗ | ៣១៧.៩៤ |
| | ដីព្រៃចំរុះ (ស្រោងនិងរបោះ) | ដើមឈើចំរុះដុះមួយៗ | ៥.៨៨៩.៤៧ |
| | ដីព្រៃដុះតាមមាត់ទឹក(ស្ទឹង អូរ) | ដីអិដ្ឋល្បាយខ្សាច់ | ៣.០៩៨.១៨ |
| | ដីព្រៃដុះឡើងវិញ | ដីកាប់ចំការទុកចោល | ១២០.៨១ |
| | ដីចំការបោះបង់ចោលដុះស្មៅ | ដីចំការទុកចោលយូរ | ១៤៩.៣៨ |
| | ដីប្រៃគុម្ពោធ | ព្រៃដុះតាមភ្លឺស្រែ និងក្បាលស្រែ | ៣៧០.៥៦ |
| | ព្រៃគុម្ពោធលាយដើមឈើធំមួយៗ | ដីស្រែនៅឆ្ងាយពីភូមិ | ៣០១.៧៤ |
| | ដីបឹង | ដីល្បាប់ភក់ | ២១.០៥ |
| | ដីបឹងមានទឹកជាប្រចាំ | ដីអិដ្ឋ | ១០.១៥ |
| | ដីបឹងមានទឹកនៅរដូវវស្សា | បឹងមានទំហំតូចជារណ្តៅគ្រាប់ | ៣.២១ |
| | ដី ស្ទឹង អូរ | ល្បាប់ភក់លាយខ្សាច់ | ៥៤.០៩ |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម




រូបផែនទីផលិតភាពដី ក្នុងឃុំព្រងិល

### ១.៣.៤ ធនធានធម្មជាតិ

#### ១.៣.៤.១ ធនធានព្រៃឈើ

ផ្ទៃដីព្រៃនៅឃុំព្រងិលមានវិសាលភាពធំល្វឹងល្វើយគ្របដណ្តប់ទៅដោយ ភ្នំ វាលស្មៅ ជាប្រភពនៃប្រព័ន្ធអេកូឡូស៊ីចំរុះសំរាប់ការវិវឌ្ឍន៍នូវធនធានធម្មជាតិមានដូចជាៈ សត្វព្រៃ តូច ធំគ្រប់ប្រភេទ ដែលជាផ្នែកមួយដ៏សំខាន់សំរាប់ អភិវឌ្ឍន៍ដល់សេដ្ឋកិច្ចជាតិ ក្រៅពីនេះនៅមានធនធានព្រៃឈើជាច្រើនមុខរាប់ទាំង វល្លិ ផ្តៅដើមឈើ តូច ធំ ខ្ពស់ ទាប ជាជំរកពពួកសត្វព្រៃគ្រប់ប្រភេទ។ ម្យ៉ាងវិញទៀតព្រៃឈើមានអត្ថប្រយោជន៍យ៉ាង ច្រើន ដូចជាៈ ការពារបាននូវខ្យល់ព្យុះ គ្រោះទឹកជំនន់ កាត់បន្ថយកំដៅក្នុងបរិយាកាស និងភាព រាំង ស្ងួត។ ប្រភេទឈើមានដូចជា ឈើក្រញូង បេង នាងនួន គគី កកោះ ត្រាច ធ្នុង ធ្នឹក ទាំងអស់នេះសុទ្ធតែឈើ មានតំលៃខ្ពស់ដែលមិនអាចកាត់ថ្លៃបាន បន្ទាប់ពីនេះនៅមានឈើចំរុះជាច្រើនមុខទៀត សំរាប់ទ្រទ្រង់ជីវភាពដល់ប្រជាពលរដ្ឋដូចជាការកាប់អុស ធ្យូង និងអនុផលព្រៃឈើសំរាប់ប្រើប្រាស់ និងលក់ដូររកប្រាក់ចំណូលគ្រួសារផងដែរ ។

ការប្រើប្រាស់ព្រៃឈើបច្ចុប្បន្នមានការរុករានកាប់ឈើធ្វើអុស ធ្វើធ្យូង រឺ កាប់ធ្វើលំនៅដ្ឋាន និងលក់ដើម្បីយកថវិការមកដោះស្រាយជីវភាពគ្រួសារទទឹមនឹងនេះក៏មានការហាមឃាត់ពីរដ្ឋបាលព្រៃឈើជាមួយមន្ទីរបរិស្ថានដែលជាស្ថាប័នជំនាញទទួលខុសត្រូវនូវជីវមណ្ឌលបៃតងទូទាំងប្រទេស។

#### ១.៣.៤.២ ធនធានជលផល

នៅក្នុងឃុំព្រងិលទាំងមូល ប្រភពទឹក និង ធនធានទឹកសំខាន់ៗមាន ស្ទឹង អូរ បឹង ប្រឡាយ តែប៉ុណ្ណោះ

ដែលស្ទឹង អូរ ប្រឡាយទាំងនោះមានវិសាលភាពខ្លាំងនៅរដូវវស្សា អាចជនលិចដីស្រែមួយចំនួនទៀតផង។ មួយរយៈ ពេលនៃទឹកជំនន់នៅរដូវវស្សា បានកកើតនូវជីវចំរុះ និងចំណីអាហារយ៉ាងច្រើនសំរាប់ត្រី ជាហេតុធ្វើអោយសំបូរ ទៅដោយត្រីជាច្រើនប្រភេទដូចជាៈ រៀល, លិញ, ឆ្ពិន, អណ្តែង, កញ្ចុះ, ក្រូស, ស្លាត, ឆ្លាំង, ក្រាញ់, ឆ្ពញ, រស់...។

ចំពោះការនេសាទនៅក្នុងឃុំធ្វើឡើងដោយ ប្រើឧបករណ៍ជាលក្ខណៈគ្រួសារ ដូចជាៈ សំណាញ់ មង ទ្រូ លាន់ លប ឈ្នាងត្រាំ ...។ល។

ឃុំមានបឹងទឹកខួបដីធំមួយ គឺបឹងកំពែង ស្ថិតនៅក្នុងភូមិកំពែង ដែលមានទំហំ ២១ហិកតា មានរាងទ្រវែង លាតសន្ធឹងតាមបណ្តោយស្របជាមួយផ្លូវគ្រួសក្រហមទៅកាន់ទីប្រជុំស្រុកភ្នំក្រវាញ បឹងនេះសម្បូរទៅដោយ ជីវចំរុះរស់នៅច្រើនប្រភេទដូចជាៈ ត្រី អន្ទង់ កង្កែប ខ្យង ក្តាម អណ្តើក កន្ធាយ ពស់...។ល។ ដែលបានផ្តល់អោយប្រជាពលរដ្ឋក្នុងឃុំនូវប្រភពចំណីអាហារបានគ្រប់រដូវ ។ ក្រុមប្រឹក្សាឃុំ និងប្រជាពរដ្ឋក្នុងឃុំ មានការព្រួយបារម្ភណ៍អំពីការរីងរាក់ និងការថយចុះនូវធនធានត្រី ប្រភេទត្រី និងជីវចំរុះនៅក្នុងបឹង ទើបមានការ ផ្តួចផ្តើមស្នើសុំបង្កើតសហគមន៍នេសាទ ក្នុងគោលបំណងគ្រប់គ្រង ថែរក្សា និងអភិរក្សត្រីមេពូជ នៅខែឧសភា ឆ្នាំ ២០០៥ ដែលមានសមាជិកមកពីភូមិចំនួន ០៣ គឺភូមិ កំពែង, អូរស្រាវ និង ស្វាយប៉ាក ។




## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

- **តម្លៃស្រូវ** :.ស្រូវសុម៉ាលី និងសែនពិដោរ និងផ្កាម្លិះ ១គីឡូក្រាម ១២០០-១៥០០ រៀល

ជាតំលៃលក់អោយឈ្មួញកណ្តាលដែលទិញស្តុកទុកសំរាប់លក់ទៅប្រទេសវៀតណាម និងរោងម៉ាស៊ីនកិនស្រូវធំៗ។

- **តម្លៃត្រី** : ត្រីអណ្តែង, រ៉ស់, ១គីឡូក្រាមចន្លោះពី ១២០០០-១៥០០០រៀល, ត្រីក្រាញ់ ពី ៨០០០រៀល ទៅ១២០០០រៀល, ត្រីរៀល, លិញ ពី ៦០០០ ទៅ៩០០០រៀល, ត្រីកញ្ចុះ ឆ្លូញ ចាប់ពី ៨០០០ ទៅ ១២០០០រៀល, ត្រីឆ្លាំង កញ្ចុះ ចាប់ពី ១០០០០ រៀល ទៅ ១២៥០០រៀល។

- **តម្លៃអុស** : អុសដែលប្រជាជនបានប្រើប្រាស់ និងលក់មានប្រភេទជាអុសឈើងាប់ចាស់ និងអុសឈើក្រាក់ដែលរកមកពីភ្នំ។ ចំពោះតំលៃអុសដែលលក់ចេញមាន ប្រភេទអុសក្រាក់ ១ស្ទេពី ៣០០០០ រៀល ទៅ ៤០០០០រៀល និងអុសប្រភេទឈើ ខ្លុង ត្បែង និងត្រាច ១ស្ទេពី ១០០០០រៀល ទៅ ១៥០០០រៀល។

- **តម្លៃធ្យូង** : ការលក់ធ្យូងមានពីរប្រភេទ គឺការលក់ដោយច្រកបាវ ឬការ៉ុង និងការលក់បែបថ្លឹង ចំពោះតំលៃក្នុងការលក់បែបច្រកបាវ ឬការ៉ុងអាស្រ័យទៅលើទំហំរបស់បាវ ឬការ៉ុងនោះ ចាប់ពី ៨.០០០រៀល ដល់ ១៥.០០០រៀលក្នុង ១ការ៉ុង ចំពោះការលក់បែបថ្លឹង គឺតំលៃចាប់ពី ១០០០រៀល ទៅ ១២០០រៀល អាស្រ័យលើគុណភាពរបស់ធ្យូង ។

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- គេទិញស្រូវពីតាមបណ្តាភូមិ ក្នុងឃុំ យកមកស្តុកទុកតរួចដឹកយកទៅលក់នៅ ពោធិ៍សាត់ ភ្នំពេញ និង ប្រទេសវៀតណាម ឬប្រទេសថៃ ដោយមានតម្លៃទិញចូលក្នុងមូលដ្ឋាន ពី ១១០០៛ ទៅ ១៣០០៛ និង តម្លៃលក់ចេញពីក្នុងមូលដ្ឋាន ។

- ចំពោះចរាចរណ៏ផលនេសាទនៅក្នុងមូលដ្ឋានឃុំគឺ អ្នកនេសាទត្រីបានសំរាប់ធ្វើម្ហូបអាហារ និងសល់មួយចំណែកសំរាប់លក់នៅតាមភូមិនៅ ក្នុងឃុំតែប៉ុណ្ណោះ។ ការលក់ដូរគឺក្នុងរូបភាពជាថ្លឹងដោយប្រើជញ្ជីងដៃ ឬ ដោតជាចង្កោម ដែលគិតជាមធ្យមត្រីស្រែ ១គីឡូក្រាម តំលៃពី ១២០០០-១៥០០០រៀល។

- អុសត្រូវបានប្រជាពលរដ្ឋទៅរកនៅភ្នំ ហើយដឹកយកមករៀបចំ ជាស្ទែរ សំរាប់លក់អោយឈ្មួញដឹកយកទៅលក់នៅពោធិ៍សាត់ និងភ្នំពេញ ក្នុងតំលៃ ១ស្ទែរ ៣០០០០រៀល ។

- ធ្យូង ការផលិតធ្យូងត្រូវបានប្រជាពលរដ្ឋយកមកពីព្រៃ ដោយធ្វើឡសំរាប់ដុតនៅក្នុងព្រៃតែម្តង ហើយដឹកជញ្ជូនយកមកទុកដាក់រៀបចំជាការ៉ុងសំរាប់លក់អោយទៅឈ្មួញកណ្តាល ឬ ដំណើរមួយចំនួន។ ចំពោះតំលៃធ្យូងលក់ចេញ ១ការ៉ុង តំលៃចាប់ពី ១៥០០០-២០០០០រៀល ។

### ១.៤.៣ ឱកាស ឧបសគ្គ

ចំពោះធនធានធម្មជាតិ ជាមួយដែលមានសក្តានុពលយ៉ាងខ្ពស់ផ្នែកកសិកម្ម និងផ្តល់អាកាសធាតុអោយភាពត្រជាក់ត្រជុំគឺជា ប្រភពចំណូលផ្នែកទេសចរណ៏មួយយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ចជាតិតែបច្ចុប្បន្នការប្រើធនធាន

ធម្មជាតិមានការប៉ះពាល់ខ្លាំង ធ្វើអោយធនធានធម្មជាតិទទួលរងនូវគ្រោះថ្នាក់ដូចជា ការកាប់ឈើធ្វើអុសកាប់ឈើធ្វើអាជីវកម្មកាប់ព្រៃវាតយកដីលក់ និងធ្វើស្រែពីសំណាក់ប្រជាពលរដ្ឋ និងអ្នកមានអំណាចមួយចំនួនកក្តាទាំងអស់នេះហើយដែលបណ្តាលអោយធនធានធម្មជាតិក្នុងឃុំព្រងិលមានការថយចុះជាលំដាប់។ កាបង្កើតសហគមន៍គឺ ទុកអោយមានឱកាសដល់ប្រជាពលរដ្ឋក្នុងការការពារធនធានធម្មជាតិ និង បង្កើនប្រាក់ចំណូលសំរាប់សហគមន៏វិញ។

# ជំពូក ២
# ការវិភាគពីតម្រូវការសំរាប់អនាគត ឧបសគ្គ និង សក្តានុពល

## ២.១ តំបន់សើម

តំបន់ព្រៃធម្មជាតិ និងវាលស្មៅក្នុងជួរភ្នំខ្ពង់រាបជាតំបន់ ដីសំបូរទៅដោយជីជាតិ ហើយសើមដែលអាចប្រើប្រាស់បានច្រើនយ៉ាង មានជីវៈចំរុះរស់នៅ។ ដែនព្រៃធម្មជាតិនេះត្រូវរក្សាទុកអោយនៅដដែល មិនអាចមានការពង្រីកដីកសិកម្មនៅក្នុងដែននេះបានទេ ហើយសកម្មភាពរបស់មនុស្សដូចជា ការឈូសឆាយ កាប់ព្រៃយកធ្វើជាចំការ ទន្ទ្រានយកដីព្រៃលក់ រឺសង់លំនៅដ្ឋានត្រូវមានដែន កំណត់មិនអាចធ្វើការ អភិវឌ្ឍក្នុងរូបភាពទ្រុងទ្រាយធំបានឡើយ ។

ទម្រង់នៃការប្រើប្រាស់ដី បច្ចុប្បន្នដែលគួរតែរក្សាទុកដោយឥតមានការកែប្រែរួមមាន :

- តំបន់ដីសម្បទានសេដ្ឋកិច្ចភាភីម៉ិច ៧៥.៤១២,១១ ហត
- តំបន់ជំរកសត្វព្រៃភ្នំឱរ៉ាល់ ៥២.២២១,៧៦ ហត
- តំបន់រមនីយដ្ឋានទេសចរណ៍ច្រកល្បៀង ១៤៩,២២ ហត
- សហគមន៍ព្រៃឈើកំពែង ១៨៨,៤៣ ហត
- សហគមន៍ព្រៃឈើអូរបាក់ត្រា ៨៤៨,៧៧ ហត
- សហគមន៍ព្រៃឈើអូរស្រាវ ២០៦,៦២ ហត
- សហគមន៍ព្រៃឈើព្រងិល ២៤៩,២០ ហត
- សហគមន៍ព្រៃឈើសំរោងយា១ ៣,៤៦ ហត
- សហគមន៍ព្រៃឈើស្វាយប៉ាក ១៧២,៣២ ហត

## ២.២ ការប្រឈម/ឧបសគ្គ :

ក្នុងឃុំព្រងិលមានបញ្ហាប្រឈមជាច្រើន ដែលមានការពាក់ព័ន្ធដល់ធនធានធម្មជាតិ ក៏ដូចជាការប្រើប្រាស់ដីមានដូចខាងក្រោម:

- ការបាត់បង់ដីព្រៃឈើ ដោយសារ ប្រជាពលរដ្ឋនៅក្នុងឃុំ និងមកពីក្រៅឃុំកាប់ព្រៃរុករានយកដីធ្វើជាកម្មសិទ្ធិមាននៅ (ភូមិព្រងិល អូរបាក់ត្រា ស្វាយប៉ាក អូរស្រាវ និងភូមិសាយ) ការកាប់បំផ្លាញព្រៃឈើប៉ះពាល់ដល់ផលប្រយោជន៍រួមជាច្រើនដូចជា បាត់បង់ជំរកសត្វព្រៃ វាលស្មៅ សំរាប់សត្វពាហនៈគ្រោះរាំងស្ងួត បរិស្ថានមិនល្អ។ ដូច្នេះឃុំត្រូវរក្សាទុកនូវសម្បត្តិព្រៃឈើអោយបានគង់វង្សពីព្រោះព្រៃឈើមានសារៈប្រយោជន៍សំខាន់ណាស់ ទន្ទឹមនឹងនេះឃុំត្រូវមានកម្មវិធីផ្សព្វផ្សាយពន្យល់អោយប្រជាពលរដ្ឋយល់ដឹងពីបញ្ហាព្រៃឈើ ។

- ដីស្រែចំការខ្សោះជីវជាតិ ដែលមានមូលហេតុមកពីការបាត់បង់ព្រៃឈើការធ្វើស្រែ និង កសិកម្មពុំសូវមានបច្ចេកទេសគ្រប់គ្រាន់ដូចជា ដាំដំណាំដដែលៗលើផ្ទៃដីតែមួយ ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវ នាំអោយខូចជីជាតិ ដី និងរចនាសម្ព័ន្ធដី។

- ទិន្នផលស្រូវចុះទាប មកពីកត្តាខ្វះប្រពន្ធ័ស្រោចស្រព ប្រើប្រាស់ពូជមិនត្រឹមត្រូវ មានជម្ងឺ និងសត្វល្អិតបំផ្លាញថ្នាំពល់ពុំសូវមានប្រសិទ្ធិភាព ។

- តម្រូវការដីបន្ថែមដើម្បីបង្កបង្កើនផលស្រូវ ដោយធ្វើការពង្រីកទៅពោះប្រឡាយ រឺស្រះធម្មជាតិ មាត់បឹង និង មាត់អូរ ។

- ផ្ទៃដីព្រៃមួយចំនួនត្រូវបានកាប់ឈូសឆាយហើយដុតបំផ្លាញ ដើម្បីទាញយកផលប្រយោជន៏ផ្សេងៗ ដូចជា សត្វ អណ្តើក. ពង្រូល. ពស់ ។ល។

បញ្ហាប្រឈមខាងលើនេះនឹងនាំមកនូវតម្រូវការដីកាន់កាប់កាន់តែច្រើន ក្នុងនោះមានទាំងដីសំរាប់បង្កបង្កើនផល ដីសំរាប់តែកម្មសិទ្ធិ ជាលទ្ធផលចុងក្រោយគឺបាត់បង់ដីព្រៃ វាលស្មៅ និង បឹងបួរធម្មជាតិ ឈានទៅដល់ការខូចប្រយោជន៏ធន់ធានព្រៃឈើ ជីវមណ្ឌលចំរុះ ជាបច្ច័យចុងក្រោយគឺធនធានដីកាន់តែរេចរិលបន្តបន្ទាប់។

## ២.៣ កំណត់តម្រូវការ នៃការអភិវឌ្ឍ និងគោលដៅយុទ្ធសាស្ត្រឃុំព្រាំងិល

- ចង់បានពូជស្រូវមានទិន្នផលខ្ពស់ឆ្នាំ ២០០៩- ២០២២ ប្រជាពលរដ្ឋទូទាំងឃុំមានស្រូវ និងអង្ករហូបចុកគ្រប់គ្រាន់ជំហានដំបូងកែរសំរួលប្រពន្ធ័ស្រោចស្រពជីកប្រឡាយ រឺស្តារប្រឡាយប្តូរពូជស្រូវអោយបានញឹកញាប់រាល់ពីរឆ្នាំម្តងរកពូជដែលមានរយៈពេលដាំដុះខ្លី និងបង្កើនធ្វើជីកំប៉ុស៏។

- មានផ្លូវងាយស្រួលធ្វើដំណើរឆ្នាំ២០០៩-២០២២ បង្កើត និងចងក្រងសហគមន៏ជុសជុលផ្លូវ ជំរុញកែលំអរអោយមានប្រពន្ធ័ផ្លូវតាមជនបទ លើកផ្លូវលំដីសរួចក្រាលគ្រួសក្រហម សង់ស្ពានមានការជួសជុល ជាប្រចាំដាក់លូកាត់ថ្នល់ ។

- បណ្តុះបណ្តាលការប្រើប្រាស់ជីគីមីទៅលើដំណាំកសិកម្ម ឆ្នាំ២០០៩-២០២២ សង្ឃឹមថាប្រជាពលរដ្ឋគ្រប់គ្នាចេះពីរបៀបប្រើប្រាស់ជីគីមី រួចទទួលបាននូវការដាំដុះមានទិន្នផលខ្ពស់ បង្រៀនអោយចេះធ្វើប្រភេទជីអ៊ុ អឹម និងមានធ្វើស្រែបង្ហាញដល់កសិករគំរូ ។

- សំបូរព្រៃឈើឡើងវិញចាប់ពីឆ្នាំ២០០៩-២០២២ ប្រជាពរដ្ឋមានការយល់ដឹង និង ចូលរួម ដាំដុះដើមឈើឡើងវិញហើយខិតខំប្រឹងប្រែងបង្កើតសហគមន៏ព្រៃឈើ ព្រមទាំងបង្កើនការការពាររក្សាផលអនុផលព្រៃឈើផ្សារភ្ជាប់ និងច្បាប់រដ្ឋបាលព្រៃឈើរួចប្រកាសបិទផ្សព្វផ្សាយ។

- សង្ឃឹមថាក្នុងឆ្នាំ២០០៩-២០២២ និងមានប្រជាពលរដ្ឋចូលរួមជួយថែរក្សាសម្បត្តិមច្ឆាជាតិ និងបរិស្ថាននោះ ធនធានជលផលមានការកើនឡើងគួបផ្សំពីសំណាក់រាជរដ្ឋាភិបាល ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់

លែងពូជត្រីក្នុងបឹងធម្មជាតិ និង ផ្តល់ពូជដល់សហគមន៍តូចធំនៅតាមជនបទដាច់ស្រយាល រួចពង្រឹងមន្ត្រីផ្នែកអភិរក្ស ហើយធ្វើការទប់ស្កាត់នៅរាល់ឧបករណ៍ខុសច្បាប់ពិសេសជំរុញអោយប្រជាពលរដ្ឋចេះចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ ។

- ចង់បានសត្វព្រៃសម្បូរឡើងវិញចាប់ពីឆ្នាំ២០០៩-២០២២ ដោយមានការរិតបន្តឹងបន្ថែមទៀត តាមផ្លូវច្បាប់រដ្ឋ បាលព្រៃឈើ ពង្រឹងការគ្រប់គ្រង និងការការពារបរិស្ថាន ហើយបិទប្រកាសផ្សព្វផ្សាយច្បាប់បរិស្ថាន និងច្បាប់ការពារសត្វព្រៃត្រូវហាមឃាត់រាល់ការប្រម៉ាញ់ខុសច្បាប់ ហើយកុំអោយមានការរុករានព្រៃឈើពីសំណាក់ប្រជាពលរដ្ឋ និងអ្នកមានអំណាច ។

- សង្ឃឹមថា ឆ្នាំ២០០៩ រហូតដល់ឆ្នាំ ២០២២ ប្រជាពលរដ្ឋក្នុងឃុំ និងមានប្រភពទឹកស្អាតប្រើប្រាស់ប្រកបដោយអនាម័យខ្ពស់ត្រូវរៀបចំនូវប្រព័ន្ធចំរុះទឹកដូចជា ជីកអណ្តូងស្នប់ ដាក់អណ្តូងលូ ធ្វើអាងតម្កល់ទឹក ។

- ពង្រីកនូវប្រព័ន្ធអប់រំសិក្សាធិការពីឆ្នាំ ២០០៩- ២០២២ សំរាប់កុមារាកុមារីដែលគ្រប់អាយុអោយបានចូលរៀនគ្រប់ៗគ្នាដើម្បីទទួលបានធនធានមនុស្សទាំងក្មេងទាំងចាស់ និង ឈានទៅរកការអភិវឌ្ឍន៍សង្គមជាតិជាវិជ្ជមាន ។

- ប្រជពលរដ្ឋ និង មានមុខរបរគ្រប់ៗគ្នាក្នុងឆ្នាំ ២០០៩-២០២២ នៅលើផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់ឃុំ ដែលមានមូលដ្ឋានច្បាស់លាស់ផ្អែកទៅលើកិរិតជំនាញ និង រកប្រាក់ចំណូលតាមរយៈនៃការបណ្តុះបណ្តាលវិជ្ជាជីវៈបង្កើតសមាគមន៍សន្សំប្រាក់បង្កើនការចិញ្ចឹម សត្វមាន់ ទា ជ្រូក រួចចងក្រងជាធានាគារ គោ ក្របីមេ ធ្វើយ៉ាងណាអោយស្រប តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋនៅក្នុងប្រទេសបានបន្តិចម្តងៗក្នុងមួយឆ្នាំ ។

## ២.៤ តម្រូវការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

អត្រាកំណើននៃប្រជាពលរដ្ឋនៅក្នុងឃុំព្រងិល បើពិនិត្យទៅតាមបណ្តាឆ្នាំនីមួយៗឃើញថា មានការកើនឡើងជាលំដាប់គួរអោយកត់សំគាល់តែបើពិនិត្យមើលទៅលើចំនួនគ្រួសារពុំសូវមានការកើនឡើងខ្លាំងនោះទេ ។

ដោយឡែកក្នុងឆ្នាំ ២០០២ ចំនួនគ្រួសារកើនឡើង តែថយចុះវិញនៅឆ្នាំ២០០៣ លុះចូលដល់ឆ្នាំ២០០៤ រហូតដល់ ២០០៨ គឺ មានការកើនឡើងវិញ។ ចំពោះប្រជាពលរដ្ឋដែលធ្វើចំណាកស្រុកទៅរកមុខរបរខាងក្រៅដូចជា កម្មកររោងចក្រកាត់ដេរនៅភ្នំពេញ រឺនៅតាមព្រំដែននៃប្រទេសថៃមានតិចតួចបំផុត។ ដោយការកើនឡើងចំនួនគ្រួសារ និងកុមារពីឆ្នាំ ២០០៤-២០០៨ ជាហេតុអោយមានផលប៉ះពាល់កង្វះខាតទីលំនៅដ្ឋាន និងកន្លែងសិក្សាពោលគឺ ឃុំត្រូវតែរកយុទ្ធសាស្ត្រដោះស្រាយពង្រីកដីក្នុងឃុំសំរាប់ផ្តល់ជូនប្រជាពលរដ្ឋសង់លំនៅដ្ឋានក៏ដូចជា

លើវិស័យកសិកម្មដែរ ដូច្នេះពីមួយឆ្នាំទៅមួយឆ្នាំប្រជាពលរដ្ឋ និងកុមារកើនឡើងជាលំដាប់ បង្ករអោយមានតម្រូវការនូវសក្តានុពលមួយចំនួនដូចជា លទ្ធភាពពង្រីកអគារសិក្សា ការធ្វើស្រែបង្កើនរដូវ រៀបចំប្រព័ន្ធស្រោចស្រព រក្សានូវធនធានធម្មជាតិ និងការផ្តល់អោយប្រើប្រាស់ធនធានអោយបានសមស្របនោះ ទើបអាចធានាបាននូវអត្រាកំណើនសេដ្ឋកិច្ច ។

**<u>តារាង គណនាអត្រាកំណើនប្រជាជនគិតជាមធ្យមប្រចាំឆ្នាំ</u> :**

| ចំនួនគ្រួសារ/ប្រជាជន | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើន/ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ១៧៣៣ | ១៧២០ | ១៧៦១ | ១៧៨៦ | ១៨៤៥ | ១៨៧០ | ១៩១៣ | - | - |
| អត្រាកំណើនគ្រួសារ | | -១% | ២% | ១% | ៣% | ១% | ២% | ២% | ៣៨គ្រួសារ |
| ចំនួនប្រជាជនសរុប | ៨២៧៤ | ៨២៥៩ | ៨៨១៤ | ៨៨៨១ | ៩៥១២ | ៩២៨៨ | ៩២៩៨ | - | - |
| អត្រាកំណើនប្រជាជន | | 0% | ៧% | ១% | ៧% | -២% | 0% | ២% | ១៨៦នាក់ |

នៅក្នុងអត្រានៃការបម្រែបម្រួលចំនួនគ្រួសារនៃប្រជាពលរដ្ឋក្នុងអំឡុងឆ្នាំ ២០០២ ដល់ ២០០៣ ឃើញថាមានការថយចុះ -១% ប៉ុន្តែពីឆ្នាំ២០០៣ ដល់ ២០០៤ អត្រាកំណើនមានការកើនឡើងវិញត្រឹម ២% កត្តាទាំងនេះប្រែប្រួលអាស្រ័យទៅប្រជាពលរដ្ឋមានការយល់ដឹងពីកម្មវិធីពន្យាកំណើត ពិសេសការធ្វើចំណាក ស្រុកទៅធ្វើកម្មករ រឺ ចំការនៅព្រំដែន និងមួយចំនួនទៀតទៅធ្វើជាកម្មករសំណង់ ក្រុមហ៊ុនរោងចក្រកាត់ដេរនានានៅភ្នំពេញ ក្នុងនោះដែរបើតាមគណនាអត្រាកំណើនចំនួនគ្រួសារ ពីឆ្នាំ ២០០២ ដល់ ២០០៨ ឃើញថាអត្រាកំណើនមានជាមធ្យម ២% ស្មើនឹង ៣៨គ្រួសារ ក្នុងមួយឆ្នាំ។

ផ្អែកតាមទិន្នន័យព័ត៌មាន នៃផែនការអភិវឌ្ឍន៍ឃុំ និងតាមការគណនារកអត្រាកំណើនរបស់ប្រជាពលរដ្ឋ ឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំមានការប្រែប្រួលកើនឡើង និងឆ្នាំខ្លះមានការថយចុះកត្តាទាំងនេះគឺអាស្រ័យដោយមូលហេតុដូចករណីខាងលើ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏អត្រាកំណើនជាមធ្យម ២% ដែលក្នុងនោះ មានការកើនឡើងក្នុងមួយឆ្នាំ ១៨៦ នាក់។

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

**តារាងការធ្វើចំណោលប្រជាសាស្ត្រ :**

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម០៥ឆ្នាំ | ១១៣០ | ៦៣៤ | ១២៣៤ | ៦៩៣ | ១៣៣៩ | ៧៥១ |
| អាយុ ០៥ឆ្នាំ | ៣៩៩ | ១៩៤ | ៤៣៥ | ២១២ | ៤៧២ | ២៣០ |
| អាយុពី ៦-១១ឆ្នាំ | ១៣៧៦ | ៧១២ | ១៥០៣ | ៧៧៨ | ១៦៣១ | ៨៤៤ |
| អាយុពី ១២-១៤ឆ្នាំ | ៧៤៥ | ៣៨៧ | ៨១៤ | ៤២២ | ៨៨៣ | ៤៥៨ |
| អាយុពី ១៥-១៧ឆ្នាំ | ៨៧២ | ៤៣៥ | ៩៥២ | ៤៧៦ | ១០៣៣ | ៥១៦ |
| អាយុពី ១៨-២៤ឆ្នាំ | ១០៨៩ | ៦១៦ | ១១៨៩ | ៦៧៣ | ១២៩០ | ៧៣០ |
| អាយុពី ២៥-៦០ឆ្នាំ | ៣៧២១ | ១៩១៤ | ៤០៦៥ | ២០៩១ | ៤៤១០ | ២២៦៨ |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៧១២ | ៣៩៤ | ៧៧៨ | ៤៣១ | ៨៤៤ | ៤៦៧ |
| ចំនួនប្រជាជនសរុប | ១០០៤២ | ៥២៨៦ | ១០៩៧២ | ៥៧៧៥ | ១១៩០២ | ៦២៦៥ |
| **ចំនួនគ្រួសារសរុប** | **២០៦៦** | | **២២៥៧** | | **២៤៤៩** | |

កំណើនប្រជាពលរដ្ឋនៅក្នុងឃុំព្រងិលមានអត្រាកើន ក្នុងរយៈពេល ០៥ឆ្នាំម្តងសំរាប់១៥ឆ្នាំខាងមុខឃើញថា មានការកើនជាមធ្យម ២% ស្មើនឹង ១៨៦នាក់ ក្នុងមួយឆ្នាំ ហើយនិង ២% ស្មើនឹង ៣៨គ្រួសារក្នុងមួយឆ្នាំនោះ បើពិនិត្យទៅលើផ្ទៃដីដែលអាចប្រើប្រាស់បានឃើញថា នៅមានក៏រិតប៉ុន្តែទោះជាយ៉ាងណាក៏យើងត្រូវចាប់អារម្មណ៍ដល់ការអភិវឌ្ឍន៍ដែរ ព្រោះកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំពាក់ពន្ធ័ទៅការធានានូវសន្តិសុខស្បៀងក្នុងតំបន់។

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន :

ចំពោះដីលំនៅដ្ឋាននៅជនបទគឺ សំដៅទៅដល់ ដីដែល ប្រើប្រាស់សំរាប់សង់ផ្ទះ និងសំរាប់សួនដាំដំណាំ នៅជុំវិញផ្ទះ (លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល ២០០៨ ដីលំនៅដ្ឋានមានទំហំ ៥៣០.៩៧ ហិកតា ដែលមានប្រជាជនសរុបប្រមាណជា ១៩១៣គ្រួសារ ក្នុងនោះគ្រួសារដែលមិនមានដីសង់លំនៅដ្ឋានចំនួន ១៧២ គ្រួសារដែលគ្រួសារខ្លះរស់នៅជាមួយ ឪពុក ម្តាយ និងគ្រួសារខ្លះទៀតសង់ផ្ទះលើដីសាធារណៈ។ ដូច្នេះគ្រួសារ ដែលមានដីសង់លំនៅដ្ឋានពិតប្រាកដមានចំនួន ១៧៤១គ្រួសារ ប៉ុណ្ណោះ បើគិតទៅលើដីលំនៅដ្ឋានបច្ចុប្បន្នដែលមាននៅក្នុងឃុំ ឃើញថា មួយគ្រួសារមានដីលំនៅដ្ឋានរហូតដល់ទៅចំនួន ០.៣០ ហិកតា ដែលទំហំដីសមស្របសំរាប់សង់លំនៅដ្ឋានក្នុងមួយគ្រួសារគិតជាមធ្យមត្រឹមតែគឺមាន ០,២៥ ហិកតា ប៉ុណ្ណោះ ។ ដូច្នេះបើគិតទៅលើអត្រា

កំណើនប្រជាសាស្ត្រដល់ឆ្នាំ២០២២ ឃើញថា ឃុំត្រូវការដីសំរាប់សង់លំនៅដ្ឋានមួយចំនួនទៀត ដែលត្រូវបាន គណនាដូចខាងក្រោម៖

តម្រូវការដីសំរាប់លំនៅដ្ឋានគិតដល់ឆ្នាំ ២០២២ គឺមាន :

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន ១៧២ គ្រួ. x 0,២៥ = ៤៣ ហត.
- ចំនួនគ្រួសារដែលមិនមានដីលំនៅដ្ឋាននៅឆ្នាំ ២០២២ ៥៣៦ គ្រួ. x 0,២៥ = ១៣៤ ហត.

**តំរូវការដីលំនៅដ្ឋានសំរាប់ឆ្នាំ២០២២សរុបចំនួន៖ ១៧៧ ហត.**

## ២.៤.៣ តម្រូវការដីកសិកម្ម :

នៅក្នុងឃុំព្រងិលមានដីសំរាប់ធ្វើកសិកម្មសរុបចំនួន ៦៤៣៣,៧១ ហិកតា (ឆ្នាំគោល ២០០៨) និងមានប្រជាជនសរុបចំនួន ១៩១៣គ្រួសារ ដែលក្នុងនោះគ្រួសារដែលមិនមានដីកសិកម្មផ្ទាល់ខ្លួនចំនួន ២២៥គ្រួសារ និងគ្រួសារដែលមានដីកសិកម្មតិចជាង ១ហិកតាចំនួន ៦៣១គ្រួសារ។ ដូច្នេះចំនួនគ្រួសារ ដែលមានដីសំរាប់ធ្វើកសិកម្មគ្រប់គ្រាន់ចំនួន ១០៥៧គ្រួសា ប៉ុណ្ណោះ។ ទំហំដីជាមធ្យមសមស្របសំរាប់ធ្វើកសិកម្មមួយគ្រួសារមានចំនួន ២,៥0 ហិកតា ដូច្នេះបើពិនិត្យលើតំរូវការដីកសិកម្មនៅពេលអនាគតឃើញថានៅក្នុងឃុំព្រងិល នៅមានតំរូវការដីសំរាប់ធ្វើកសិកម្មមួយចំនួនទៀត ដែលត្រូវបានគណនាដូចខាងក្រោម៖

តម្រូវការដីកសិកម្មសំរាប់ឆ្នាំ ២០២២ មាន :

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនមានដីកសិកម្ម : ២២៥គ្រួសារ x ២,៥ = ៥៦២,៥ ហ.ត
- ចំនួនគ្រួសារមានដីតិចជាង ១ហិកតា : ៦៣១គ្រួសារ x ២ = ១២៦២ ហ.ត
- កំណើនគ្រួសារដែលមិនមានដីនៅឆ្នាំ ២០២២ : ៥៣៦គ្រួសារ x ២,៥ = ១៣៤0 ហ.ត

**តំរូវការដីកសិកម្មសរុបសំរាប់ ឆ្នាំ២០២២ : ៣.១៦៤,៥ ហត**

## ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ

ឃុំព្រងិលមានដីព្រៃឈើសរុបមានចំនួន ១០៣៣៤៣.១ហិកតា បឹងធនធានធម្មជាតិមាន ដូចជា កំពែងបឹងស្លា និង បឹងមួយចំនួនទៀត ដែលមានផ្ទៃដីសរុប ៨៨,៥ ហិកតា។ ជាក់ស្តែង ដីព្រៃឈើ និងធនធាធម្មជាតិបច្ចុប្បន្នទទួលរងនូវការ កាប់បំផ្លាញ រុករានទន្ទ្រានដីព្រៃយកធ្វើជាកម្មសិទ្ធិពីសំណាក់អ្នកមានអំណាច និង ជនខិលខូចមួយចំនួនតូច។ ប្រជាពលរដ្ឋភាគច្រើននៅក្នុងឃុំព្រងិលបាន ពឹងផ្អែកទៅលើធនធានធម្មជាតិធ្វើជា មុខរបរសំរាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ និងរកប្រាក់ចំណូលដើម្បីបង្កើនជីវភាពរស់នៅទៀតផង។ ហេតុដូចនេះ ហើយទៅថ្ងៃអនាគត ប្រសិនបើព្រៃឈើត្រូវបាត់បង់, បាត់បងអនុផលព្រៃឈើ, សត្វព្រៃគ្មានទីជំរក ធនធានជលផលថយចុះ ពិសេសមានគ្រោះធម្មជាតិ កើតមានឡើង ជារៀងរាល់ឆ្នាំ (គ្រោះរាំងស្ងួត ខ្យល់ព្យុះ និង គ្រោះ ទឹកជំនន់)

ប្រជាពលរដ្ឋពិតជាជួបបញ្ហាលំបាកក្នុងការរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត។ ដើម្បីឆ្លើយតបទៅនឹងតំរូវការ និង កិច្ចការពារបរិស្ថាន ឃុំមានផែនការមួយចំនួនដូចជា ពង្រឹងសហគមន៍ព្រៃឈើដែលមានស្រាប់ចំនួន ០៥សហគមន៍, បង្កើតសហគមន៍ព្រៃឈើថ្មីចំនួន ០១ សហគមន៍នៅក្នុងភូមិសាយ ដែលមានទំហំ ៥០០ ហិកតា, សហគមនេសាទ បឹងកំពែងចំនួន ០១ សហគមន៍ ទំហំ ២១ ហិកតា និង កែប្រែអោយទៅជាសហគមន៍ទេសចរណ៍បរិស្ថាន។

## ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងរូបភាពតូចតាចបានគិតបញ្ចូលក្នុងដីលំនៅដ្ឋាន រឺ ដីទីប្រជុំជនដោយ មិនបានចែកចេញដាច់ឡែកនោះទេ តែក្នុងនោះក៏មានគិតគូរជារួមនូវហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយ ធំនោះទើបគិតដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់ជារួម និង ដីត្រៀម បំរុងសំរាប់ពង្រីកជាមួយដីទីប្រជុំជន ចំពោះផ្លូវ ទំនប់តូចៗ គឺមិនមានគិតជាផ្ទៃដីទេ តែមានប្រវែងហើយ និង បង្ហាញនៅក្នុងផែនទី ប្រើប្រាស់ពេលអនាគតមួយដោយឡែក។

**<u>តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ</u> :**

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ០ | ០២ | ០២ |
| សាលាបឋមសិក្សា | ០៥ | ០៧ | ០២ |
| សាលាអនុវិទ្យាល័យ | ០១ | ០៣ | ០២ |
| សាលាវិទ្យាល័យ | ០ | ០៥ | ០៥ |
| មណ្ឌលសុខភាព | ០១ | ០១ | ០ |
| ប៉ុស្តិសុខភាព | ០ | ០៧ | ០៧ |
| ស្រះទឹកស្អាត | ៤៣ | ៥៣ | ១០ |
| អណ្តូងទឹកស្អាត | ១១៣ | ១៥០ | ៣៧ |
| កន្លែងចាក់សំរាម | ០ | ០២ | ០២ |
| ផ្សេងៗ | ០ | ០ | ០ |
| ទីតាំងផ្សារ | ០ | ០១ | ០១ |
| ប៉ុស្តិនគរបាល | ០១ | ០ | ០ |

ប្រភព : ការប្រជុំពិភាក្សានៅថ្នាក់ឃុំ

### ២.៤.៥.១ តម្រូវការដីសាលារៀន

ចំពោះផ្ទៃដីសំរាប់កសាងសាលារៀននៅក្នុងព្រងិល មិនមានការកំណត់ផ្ទៃដីអោយបានច្បាស់លាស់នោះទេ ដោយកន្លងមកដីសាលាត្រូវបានគិតបញ្ចូលទៅក្នុងដីភូមិ បើតម្រូវអោយមានសាងសង់បន្ទប់ថ្មីគឺ អាចធ្វើបានលើទ្រង់ទ្រាយបរិវេណសាលាចាស់ លើកលែងតែមានមានការសាងសង់ជាសាលាថ្មី ។

ដោយឡែកចំពោះការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធសង្គម និងប្រើប្រាស់តាមមូលដ្ឋានក្នុងឃុំព្រងិលបច្ចុប្បន្ននៅមានកំរិត។ ប៉ុន្តែទោះជាយ៉ាងណាក៏ការអភិវឌ្ឍន៍លើវិស័យអប់រំ នៅក្នុងឃុំពុំទាន់បានបំពេញនូវតម្រូវការសិក្សារបស់សិស្សានុសិស្សនៅឡើយ ជាអាទិ៍ដូចជាក្នុងគំរាងផែនការ១៥ឆ្នាំ ខាងមុខតម្រូវការអគារសិក្សាផ្អែកតាមបរិមាណសិស្សមាន សាលាមត្តេយ្យ សាលាបឋសិក្សា អនុវិទ្យាល័យ វិទ្យាល័យ បន្ថែមទៀតនោះ បើតាមការគណនាកំណើនប្រជាពលរដ្ឋឃើញថា តម្រូវការទាំងនេះអាចផ្តល់ឱកាសអោយឃុំអភិវឌ្ឍន៍ធនធានមនុស្សបានតាមលទ្ធភាពដែលអាចធ្វើទៅបាន។

**<u>តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២</u> :**

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយសិក្សា | ៣៩៩ | ១ | ៤ | ៤៣៥ | ០ | ០ | ៤៧២ | ១ | ៤ |
| ថ្នាក់បឋមសិក្សា | ១៣៧៦ | -៤ | -២០ | ១៥០៣ | -១ | -៥ | ១៦៣១ | ២ | ១១ |
| ថ្នាក់អនុវិទ្យាល័យ | ៧៤៥ | ០ | ១ | ៨១៤ | ១ | ៧ | ៨៨៣ | ០ | ២ |
| ថ្នាក់វិទ្យាល័យ | ៨៧២ | ២ | ៩ | ៩៥២ | ០ | ១ | ១០៣៣ | ២ | ១០ |

### ២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

#### ក. សេវាកម្មសុខភាព

ស្ថិតក្នុងបរិយាកាសបែបនេះឃុំព្រងិលនៅពុំទាន់មានប៉ុស្តិ៍សុខភាពតាមភូមិនៅឡើយទេ សំរាប់ជួយសំរួលដល់ការទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋនេះ ជាការបន្ថែមលើមណ្ឌលសុខភាព។

- ចំងាយជាមធ្យមពីភូមិចំនួន០៣មានភូមិ សំរោងយា អូរស្រាវ អូរបាក់ត្រា ទៅមណ្ឌលសុខភាពឃុំប្រមាណ ជា ០៤ ទៅ ០៥ គីឡូម៉ែត្រដោយឡែកភូមិ០៣ទៀត គឺ ភូមិស្វាយប៉ាក កំពែង និងព្រងិល មានផ្ទៃដីជាប់និង មណ្ឌលសុខភាព និង ភូមិសាយ ជាភូមិដាច់ស្រយាលមានចំងាយប្រមាណ ១៥-១៦ គីឡូម៉ែត្រ ពីមណ្ឌលសុខភាពឃុំ។

- បើផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនៃឃុំព្រងិល ដែលមានប្រជាពលរដ្ឋរស់នៅដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំ បណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់នៅឡើយ ។

ចំពោះសន្តិសុខ និងការការពារសុខមាលភាពប្រជាពលរដ្ឋនៅក្នុងឃុំនៅជាបញ្ហាចោទដដែល ក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ក៏នៅតែជួបប្រទះនូវវិបត្តិផ្នែកជម្ងឺ និងសុខភាពព្រោះថា ស្ថានភាពប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដាច់ឆ្ងាយពីគ្នាដែលគ្មានលទ្ធភាពមកព្យាបាលនៅមណ្ឌលសុខភាពឃុំបានឡើយ ។ ដូច្នេះកង្វះខាតផ្នែកមណ្ឌលសុខភាពគឺជា កត្តាសំខាន់បំផុត ហើយអ្វីជាអទិភាពចំបងនោះ ឃុំត្រូវធ្វើផែនការសាងសង់ប៉ុស្តិ៍សុខភាពនៅតាមភូមិនីមួយៗទើបអាចសំរាលដល់ការលំបាកលើសេវាកម្មថែទាំសុខភាពក្នុងមូលដ្ឋានបាន ។

## ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំព្រងិល បច្ចុប្បន្ននៅតែជាឧបសគ្គចំបងនៅឡើយ ព្រោះថាចំពោះ អណ្តូងទឹក និងស្រះទឹកដែលមានពីមុនមកដល់បច្ចុប្បន្ននេះ មួយចំនួនត្រូវបានខូចខាតស្ទើទាំងស្រុងដូច្នេះ ជាជំហ៊ានដំបូងនៃការអភិវឌ្ឍន៍ត្រូវស្តារ និងជួសជុលនូវប្រភពទឹកស្អាតទាំងនេះសិន ហើយជាផែនការនៅពេលខាងមុខ ឃុំត្រូវបន្ថែមនូវគម្រោងស្តារជីស្រះ សង់អាងស្តុកទឹកស្អាត និង អណ្តូងទឹកស្អាត ។ដើម្បីធានាបាននូវការប្រើប្រាស់ទឹកស្អាត សំរាប់ប្រជាជន នៅក្នុងឃុំព្រងិល ទាំងមូលនោះឃុំមានគម្រោង ផែនការកសាងនូវបរិក្ខារទឹកស្អាត ដែលរួមមាន អណ្តូងស្នប់ចំនួន១២អណ្តូង អណ្តូងលូចំនួន១៥អណ្តូង និងជីកស្រះទឹកស្អាតចំនួន២៦ស្រះ និងផ្តល់ធុងចម្រោះទឹកស្អាតក្នុង១គ្រួសារ ១ ធុង សំរាប់ភូមិសាយ ។

## ២.៤.៥.៣ ផ្នែកវប្បធ៌ម និងសាសនា

នៅក្នុងការអភិវឌ្ឍន៍ទៅលើផ្នែកវប្បធម៌ និងសាសនាវាជាកត្តាមួយចូលរួមចំណែក ជំរុញអោយមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា ។ រាល់ទីតាំងសក្ការៈបូជានីមួយៗ តាមបណ្តាភូមិត្រូវបានផ្តល់លទ្ធភាពគ្រប់គ្រាន់ និងជួយសំរួលដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន អោយមានឪកាសចូលរួមពង្រីកលើការផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលសរសរទ្រូងនៃប្រទេសជាតិ អោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់ជាអាទិភាពសំរាប់ឃុំព្រងិលបច្ចុប្បន្នសំរាប់កន្លែងគោរពប្រពៃណីសាសនា នាថ្ងៃអនាគតពុំទាន់មានតម្រូវការបន្ថែមឡើយ ។

**តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា :**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| ប្រាសាទ | ០ | ០ | ០ |
| ទីកន្លែងសាការៈបូជា | ០២ | ០២ | ០ |
| វត្តព្រះអារាម | ០៥ | ០៧ | ០២ |
| សាលាឆទាន | ០១ | ០៣ | ០២ |
| ផ្សេងៗ | ០ | ០ | ០ |

## ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រពន្ធ័ស្រោចស្រព្វដែលមាននៅក្នុងឃុំព្រងិលឃើញថា ផ្លូវមួយចំនួនត្រូវធ្វើការកែរលំអរដូចជា ផ្លូវគ្រួសក្រហមដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវខូចខាតមួយចំនួនធំ ហើយនៅឆ្នាំ ២០០៩នេះ ឃុំបានរៀបចំជួសជុលឡើងវិញបានមួយចំនួនដូចមានខាងក្រោមៈ

**- ផ្លូវលំជីសៈ** ជាផ្លូវដែលបានលើកដីសរួចជាស្ថាពរមានចំនួន ០៨ ខ្សែ សរុបប្រវែង ១៤.២០០ម៉ែត្រហើយ និង បានជួសជុលចំនួន ៨.៥០០ ម៉ែត្រ ហើយត្រូវបានលើកថ្មីចំនួន ១៦.០០០ម៉ែត្រ បន្ថែមទៀត។

**- ស្ពានឈើៈ** នៅឃុំព្រងិលមានស្ពានឈើ ចំនួន០៨កន្លែង ប្រវែងសរុប ២២៥ ម៉ែត្រ។ ស្ពានឈើនេះ ត្រូវបានជួសជុល ០២កន្លែង ដែលមានប្រវែង ៥៦ម៉ែត្រ សំណង់ស្ពានឈើថ្មីត្រូវការចាំបាច់ចំនួន ០៣កន្លែង ដែលមានប្រវែងសរុប ១០៥ ម៉ែត្រ ។

**- សំណង់ស្ពានដែកៈ** តំរូវការជាចាំបាច់របស់សហគមន៍កំពែងចំនួន ០១កន្លែង ប្រវែង ៦៥ម៉ែត្រ ឆ្លងកាត់បឹងកំពែង ដែលស្ថិតនៅក្នុងភូមិកំពែង ។

**- ប្រឡាយមេៈ**នៅក្នុងឃុំព្រងិលមានប្រឡាយចំនួន ០៣ខ្សែ ប្រវែង៥.០០០ម៉ែត្រ ស្ថិតនៅភូមិស្វាយប៉ាក កំពែង អូរស្រាវ និងភូមិព្រងិល ប៉ុន្តែបច្ចុប្បន្នកសិករយើងធ្វើស្រែពឹងទៅលើទឹកភ្លៀងតែមួយមុខគត់ មានប្រឡាយតែខ្វះប្រភពទឹក និងខ្វះទំនប់ស្ទាក់ទឹកដើម្បីនាំទឹកហូរចូលប្រឡាយ សព្វថ្ងៃនេះកសិករធ្វើស្រែជួបប្រទះភាពរាំងស្ងួតខ្វះខាតទឹកធ្វើស្រែដើម្បីអោយទាន់រដូវកាល។ ប្រឡាយគ្រោងស្តារមានប្រវែង **២៤០០ម** ដែលស្ថិត នៅក្នុងភូមិព្រងិល ស្វាយប៉ាក និង ភូមិសំរោងយា គំរោងស្តារប្រឡាយនេះអាចជួយដល់កសិករ ដែលមានស្រែឆ្ងាយពីប្រពភទឹក ប្រឡាយដែលត្រូវស្តារជាប្រឡាយមេដែលមានស្រាប់ហើយរាក់មិនអាចនាំទឹកចូលទៅក្នុងស្រែបាន។

**- ប្រឡាយរង :** នៅក្នុងឃុំព្រងិល មានប្រឡាយរងប្រវែង ៥ គ.ម មានសភាពរាក់មិនមានលទ្ធភាពចែកចាយទឹកទៅស្រោចស្រព្វដីស្រែនៅកន្លែងផ្សេងទៀតទេ។ ប្រសិនបើឃុំមានលទ្ធភាពស្តារប្រឡាយមេ នោះចាំបាច់

ត្រូវធ្វើការស្តារ និងជីកប្រឡាយរងដើម្បីនាំទឹកទៅស្រោចស្រព្វដីស្រែ និងដីស្រែបង្កើនរដូវបានមួយចំនួនធំទៀត។ ដូច្នេះឃុំ មានផែនការស្តារលើប្រឡងដែលមានស្រាប់ប្រវែង ៥ គ.ម និងជីកប្រឡាយរងបន្ថែមប្រវែង ១៧ គ.ម។

- **ទំនប់បង្វែរទឹក:** នៅក្នុងឃុំព្រងិលមាន ០២កន្លែង ប្រវែង ០៥ម៉ែត្រ ស្ថិតនៅចុងបឹងកំពែង ក្នុងភូមិកំពែង ក្នុងនោះដែរក៏តម្រូវអោយមានការជួសជុលទំនប់បង្វែរទឹក ០១កន្លែងទៀតប្រវែង ២.៥ម៉ែត្រ ចំណែកទំនប់បង្វែរទឹកដែលត្រូវការជួសជុលចំនួន ០១កន្លែងទៀត ប្រវែង ២៥ម៉ែត្រ ស្ថិតក្នុង ភូមិព្រងិល ត្រង់ចំណុចទួលល្មៀងដែលទំនប់នេះមានអានុភាពស្រោចស្រព្វទឹកបានចំនួន ០៣ភូមិ គឺភូមិព្រងិល អូរស្រាវ និងភូមិកំពែង ទំនប់នេះជាទំនប់ចាស់បន្សល់ពីរបបប៉ុលពតរហូតមកដល់សម័យបច្ចុប្បន្នយើងនេះត្រូវបានខូចខាតអស់ទៅហើយ។

- **ទ្វារទឹក:** ស្ថិតនៅចុងបឹងកំពែងហើយអាចបើកបិទបានតាមតម្រូវការ របស់សហគមន៍អ្នកប្រើប្រាស់ទឹកនៅទីនោះ។ បឹងកំពែង ជាបឹងមានទឹកពេញមួយឆ្នាំលាតសន្ធឹងពីជើងទៅត្បូងមានប្រវែង ០៣ គីឡូម៉ែត្រអាចជួយបំរើនូវសេចក្តីត្រូវការទឹកសំរាប់បង្កបង្កើនផលស្រូវស្រែ ចំការនៅពេលជួបគ្រោះរាំងស្ងួតបានមួយចំនួនធំ។ បើសិនមិនមានទ្វារទឹកនេះទេ ទឹកបឹងនឹងហូរចេញយ៉ាងគំហុកនៅរដូវវស្សាបណ្តាលអោយបាត់បង់គុណភាពដី និង ខូចប្រយោជន៍ចំការដំណាំរបស់ប្រជាកសិករ ម្យ៉ាងទ្វាទឹកនេះមានតួនាទីយ៉ាងសំខាន់ក្នុងការស្តុបទឹកនៅពេលកសិករខ្វះខាតទឹកនៅរដូវវស្សា និងរដូវប្រាំងសំរាប់បង្កើនផលស្រូវចំការ ហើយមួយផ្នែកទៀតមានតួនាទីចូលរួមចំណែកកាត់បន្ថយការចំណាយថវិកាមួយចំនួនធំក្នុងការប្រើប្រាស់ធន់ធានទឹក។

- **លូរទឹកកាត់ផ្លូវ:** ជាផ្នែកមួយមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តោះទឹកចេញដើម្បីបន្ថយនូវសំពាធទឹកខាងលើ ផ្លូវថ្នល់ពុំមានការដាក់លូសំរាប់អោយទឹកហូរចេញ ចូលទេនោះ ទឹក និងអាចហូរច្រោះដាច់ផ្លូវបណ្តាលអោយមានការខូចខាត និងបាត់បង់ថវិកា ពេលវេលា។ មានលូកាត់ផ្លូវគឺមិនធ្វើអោយលិចលង់នូវផលដំណាំ របស់ប្រជាកសិករដែលនៅពីលើផ្លូវ ហើយម្យ៉ាងលូកាត់ផ្លូវអាចចែកចាយទឹកទៅដល់ដីស្រែចំការអ្នកនៅខាងក្រោមអាចប្រើប្រាស់បានតាមតម្រូវការ និងអាចជួយកាត់បន្ថយបានខ្លះៗនូវជំនន់ទឹកភ្លៀងពីផ្នែកខាងលើមិនអោយស្ទះចរន្តទឹក។

- **ប្រភេទអណ្តូង :** មានអណ្តូងស្នប់ អណ្តូងលូ និងអណ្តូងដៃ នៅក្នុងឃុំមានអណ្តូងសរុបចំនួន ២២៤ :

- អណ្តូងស្នប់ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំមាន ៥៣អណ្តូង និងអណ្តូងស្នប់មិនអាចប្រើប្រាស់បាននៅរដូវប្រាំងមាន ៦០អណ្តូង ហើយអណ្តូងដែលត្រូវបានជួសជុលមាន ៤២ អណ្តូង។
- អណ្តូងលូនៅក្នុងឃុំមាន ៩១អណ្តូង ហើយក្នុងនោះអណ្តូងលូដែលអាចប្រើប្រាស់បាន ពេញមួយឆ្នាំមាន ៤២អណ្តូង ចំណែកអណ្តូងលូដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំងមានចំនួន ៤៩អណ្តូង និងអណ្តូងលូដែលត្រូវជួសជុលមានចំនួន ៥៤អណ្តូង ។

- អណ្តូងដៃនៅមិនទាន់ដាក់លូនៅក្នុងឃុំមាន ២០អណ្តូង ហើយក្នុងនោះអណ្តូងដៃ ដែលអាចប្រើប្រាស់បានពេញ ១ឆ្នាំមានចំនួន ១៤អណ្តូង និង អណ្តូងដៃ ដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំង មានចំនួន ០៦អណ្តូង។

- **ស្រះទឹកៈ** នៅក្នុងឃុំមានចំនួន ៤៣ស្រះ ហើយស្រះដែលអាចប្រើប្រាស់បានពេញមួយឆ្នាំមានចំនួន ១០ស្រះ និង ស្រះដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំងមានចំនួន ៣៣ស្រះ ដែលត្រូវស្តារឡើងវិញទាំងអស់។

**<u>តារាងការអភិវឌ្ឍន៍ហេដ្ឋាផ្នែករចនាសម្ព័ន្ធរូបវ័ន្ត</u>** :

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | | | |
| ផ្លូវក្រាលគ្រួសក្រហម | ១៦ | ២០,៦ | ៤,៦ |
| ប្រវែងផ្លូវក្រាលដីស | ១៤ | ៨៣,៥ | ៦៩,៥ |
| ផ្លូវរទេះ/ថ្មើជើង | ១៨ | ១៨ | ០ |
| ស្ពានប្រឡាយមេ | ៣ខ្សែ (៥ គ.ម) | ២,៦១ គ.ម | ស្ពានប្រឡាយមេ |
| ស្ពានប្រឡាយរង | ០៥ | ៨,៧ | ៣,៧ |
| ចំនួន ស្ពានដែក | ០ | ៦៥ម | ៦៥ម |
| ចំនួនស្ពានឈើ | ២២៥ ម | ៣៣០ ម | ១០៥ ម |
| ចំនួន ទ្វារទឹក | ០៥ ម | ៣៣ ម | ២៨ ម |

# ជំពូក ៣
# ផែនការប្រើប្រាស់ដីអនាគត

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

សក្តានុពលដីធម្មជាតិដែលមានស្រាប់នៅក្នុងឃុំព្រងិលអាចផ្តល់នូវអត្ថប្រយោជន៍ ជាច្រើនដល់ការប្រើប្រាស់ដី និងសំរាប់ការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ពន្ធ័សង្គម ដើម្បីអោយមាននិរន្តភាព តម្លាភាពអោយសមស្របទៅនឹងស្ថានភាពដីជាក់ស្តែងក្នុងតំបន់នោះ។ អ្វីដែលជាកត្តាសំខាន់គឺសក្តានុពលព្រៃឈើ និងបរិស្ថានធម្មជាតិហើយក៏ជាបណ្តាញនៃប្រពន្ធ័អេកូឡូស៊ីចំរុះសំរាប់ធ្វើសំយោគអោយគ្នាទៅវិញទៅមក ពោលគឺផ្តល់នូវអាហារ និង ទីជំរកដល់ពពួកសត្វ. ភាវរស់ដែលមានជីវិតនៅលើភពផែនដី ម្យ៉ាងទាក់ទាញភ្ញៀវទេសចរណ៏ បង្កើនការស្រាវជ្រាវ និងអភិវឌ្ឍន៏ធនធានមនុស្ស។ ក្រៅពីនេះព្រៃឈើ និងបរិស្ថាន មានតួនាទីដ៏ល្អប្រសើរមួយទៀត សំរាប់ទ្រទ្រង់ដល់ប្រជាពលរដ្ឋ ក្នុងការទាញយកផលអនុផលព្រៃឈើ ការពារបរិយាកាសអោយមានលំនឹង កាត់បន្ថយកំដៅទប់ស្កាត់រាល់អំណាចខ្យល់ គ្រោះធម្មជាតិទឹកជំនន់ រឺគ្រោះរាំងស្ងួត។

### ៣.១.២ តម្រូវការដីតាមប្រភេទ

អត្រាកំណើនប្រជាពលរដ្ឋគឺ មានឥទ្ធិពលខ្លាំងដល់ការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ដី និងធនធានធម្មជាតិ។ ដូច្នេះឃុំត្រូវធ្វើផែនការអនាគត ដោយពិចារណាទៅលើធនធានដែលមានស្រាប់នៅក្នុងឃុំ បើយោងតាមអត្រាកំណើនប្រជាពលរដ្ឋខាងលើ ឃុំបានរៀបចំនូវគម្រោងផែនការពង្រីកដីលំនៅដ្ឋាន ក្នុងភូមិមួយចំនួនអោយមានវិសមភាពទៅនឹងអត្រាកំណើនរបស់ប្រជាពលរដ្ឋទៅថ្ងៃអនាគត។ រួចធ្វើការវិភាគពីតម្រូវការដីតាមប្រភេទនីមួយៗ អោយសមស្របទៅ និងគោលការណ៏អភិវឌ្ឍន៏របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ទៅលើវិសយ័កសិកម្ម និងកសិឧស្សាហកម្មក្នុងតំបន់ដើម្បីផ្សារភ្ជាប់កិច្ចអភិវឌ្ឍន៏ក្នុងមូលដ្ឋាន។ ទន្ទឹមឹងនេះដែរ មុននឹងធ្វើការអភិវឌ្ឍន៏វិស័យកសិកម្មសមស្រប ឃុំស្នើរឱ្យមានគោលការណ៏សិក្សា និងបែងចែកដីអោយបានច្បាស់លាស់នូវប្រភេទដីណាត្រូវអភិវឌ្ឍន៏ទៅលើដំណាំអ្វីខ្លះ ដីប្រភេទណាត្រូវដំណាំស្រូវ និង ដីប្រភេទណាត្រូវនឹងដំណាំកសិឧស្សាហកម្មបន្ទាប់ មកឃុំត្រូវគិត ដល់ ដីវាលកប់ខ្មោច ដីវាលស្រែ ដីចំការរួមផ្សំដីសម្បទានសេដ្ឋកិច្ច ដីសហគមន៏ព្រៃឈើ និងដីតំបន់អភិរក្ស ចំណែកដីសំរាប់អភិវឌ្ឍន៏រាល់ហេដ្ឋារចនាសម្ពន្ធ័ ឃុំត្រូវមានផែនទីគូរព្រៀងដោយដៃទុកសំរាប់ឃុំ។

- ចំពោះដីសំរាប់សំរាប់សង់លំនៅដ្ឋាន ឃុំមានផែនការពង្រីកចំនួន ០៣កន្លែង ផ្សេងគ្នាដែលមានទំហំសរុបចំនួន ៨៩ ហិកតា នៅក្នុងភុមិចំនួន ៣គឺភូមិ សំរោងយា ស្វាយប៉ាក និងភូមិព្រងិល ។

- វាលកប់ខ្មោចជាកត្តាមួយដែលធ្វើអោយមានការប៉ះពាល់ទៅលើការរស់នៅរបស់ប្រជាពលរដ្ឋ ហើយម្យ៉ាងទៀត អាស្រ័យដោយដីឃុំពុំមានលទ្ធភាពក្នុងការពង្រីកដីសំរាប់កប់ខ្មោចទេ តែជាគោលការណ៏ឃុំមានគម្រោងរៀបចំជាឈាបនដ្ឋានតាមវត្តអារាមសំរាប់បូជាវិញ ។

- នៅក្នុងការពង្រីកដីវាលស្រែរបស់ឃុំព្រងិល បើពិនត្យលើផ្ទៃដីដាំដុះ ទិន្នផលស្រូវដែលទទួលបាន និងអត្រាកំណើននៅថ្ងៃអនាគតឃើញថា ឃុំនូវពុំទាន់មានតំរូវការចាំបាច់ក្នុងការពង្រីកដីកសិកម្មនៅឡើយទេ។ ប៉ុន្តែមានប្រជាជនមួយចំនួនតូចដែលបានផ្លាស់ទីលំនៅ ឬក៏ទៅតាំងទីលំនៅលើដីទំនេរ ឬជាដីព្រៃចិលរិលនោះ ហើយរានដីដើម្បីធ្វើស្រែនៅជុំវិញផ្ទះ ឃុំមានគម្រោងនឹងពង្រីកដីលំនៅដ្ឋានភូមិលាយស្រែដែលមានទំហំ ៧៨៦ ហិកតានៅភូមិសាយ ។

**<u>តារាងតម្រូវការនៃការប្រើប្រាស់ដីអនាគត</u> :**

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ(ហិកតា) | ក្រឡាផ្ទៃ១៥ឆ្នាំ(ហិកតា) | បំរែបំរួល (ហិកតា) |
|---|---|---|---|
| ដីលំនៅដ្ឋានភូមិ | ៥៣០,៩៧ | ៦១៩,៩៧ | ៨៩ |
| ដីស្រែជាមួយភូមិ | ១១៣១២,០២ | ១២០៩៨,០២ | ៧៨៦ |
| ដីកប់ខ្មោច | ០១ | ០២ | ០១ |
| សហគមន៏ព្រៃឈើ | ០៥សហគមន៏ | ០៦សហគមន៏ | ០១សហគមន៏ |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរះអំពើ

នៅក្នុងឃុំព្រងិលបើនិយាយរួមក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងផ្នែកបរិស្ថានតែងតែផ្តល់នូវអន្តរះអំពើ អោយគ្នាទៅវិញទៅមកដោយក្រុមសហគមន៏ រឺប្រជាពលរដ្ឋដើម្បីជាការដោះដូររកផលចំណេញពីធនធានធម្មជាតិ។ តែបើបណ្តោយអោយមានការរុករានកាប់បំផ្លាញព្រៃឈើបែបអនាធិតេយ្យដូច បច្ចុប្បន្ននេះសង្ឃឹមថាទៅថ្ងៃអនាគតនឹងលិចចេញផលប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចសង្គមជាតិ ធ្វើអោយមានការខ្វះខាតនូវហេដ្ឋារចនាសម្ពន្ធ័សង្គមកិច្ច ដូចជាខ្វះឈើសាងសង់លំនៅដ្ឋានជាលក្ខណ:គ្រួសារ ក៏ដូចជាសិប្បកម្មកែច្នៃគ្រឿង សង្ហារឹមផ្សេងៗទៀត។ បើយ៉ាងដូច្នេះតទៅមុខបរិស្ថានធម្មជាតិ និងបាត់បង់សោភ័ណ្ឌភាពយ៉ាងគំហុកដោយសារស្នាដៃរបស់មនុស្ស ខ្វះភាពយល់ដឹងពីបរិស្ថាននៅជុំវិញខ្លួនទង្វើទាំងអស់នេះនាំ អោយមានកត្តាខូចខាតបាត់បង់ផលប្រយោជន៏រួមជាច្រើនដូចជា ការថយចុះនូវភ្ញៀវទេសចរណ៏ជាតិ និងអន្តរជាតិ ហើយអ្វីដែលជាលក្ខណ:ពិសេសគឺលំហូរសេដ្ឋកិច្ចជាតិធ្លាក់ចុះបើសិនយើងទាំងអស់គ្នាគ្មានវិធានការណ៏ទប់ស្កាត់អោយទាន់ពេលវេលាទេនោះ។

ការគ្រប់គ្រង និងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវផលប្រយោជន៍ និង មាននិរន្តរភាពហើយនឹង មានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និង បរិស្ថាន ដែលក្នុងនោះមានដូចជា :

▪ ការប្រែប្រួលពីដីស្រែក្លាយជាដីលំនៅដ្ឋានៈ កំណើនប្រជាពលរដ្ឋពីមួយឆ្នាំទៅមួយឆ្នាំទាមទារអោយនូវអោយមានការពង្រីកលំនៅដ្ឋានថ្មីជាចាំបាច់ ប៉ុន្តែការបែកចេញ ក៏ដូចជាការរៀបចំនូវលំនៅដ្ឋានថ្មី ត្រូវតែអនុវត្តន៏ទៅតាមគោលការណ៏ និងច្បាប់កំណត់។ ថ្វីត្បិតតែការរីកដីលំនៅដ្ឋាន ត្រូវបានកាត់បន្ថយនូវប្រភេទដីស្រែដែលធ្វើអោយការមានប៉ះពាល់ដល់ផលិតផលកសិកម្មដូច្នេះយើងត្រូវតែមានវិធានការ ឬគោលការណ៏ដើម្បីបំពេញបន្ថែមទៅលើកង្វះខាតនេះវិញ ដើម្បីធានានូវសុវត្ថិភាពស្បៀងក្នុងតំបន់ក្នុងនោះគឺ បញ្ចូលបច្ចេកទេសកសិកម្ម ពង្រីកប្រពន្ធ័ស្រោចស្រព ធ្វើស្រែបង្កើនរដូវ កែប្រែគុណភាពដី បង្កើនទិន្នផល ។ល។

▪ ការប្រែប្រួលពី ដីវាលស្រែដែលគេបោះបង់ចោល ឬដីទំនេរអោយទៅជាដីភូមិលាយដីស្រែសំរាប់ការបង្កបង្កើនផលនេះជាការពង្រឹង និងជំរុញលើវិស័យកសិកម្ម វាជាកត្តាអំណោយផលដល់ការបង្កើននូវទិន្នផលកសិកម្ម ក៏ដូចជា ផលិតផលផ្សេងៗ សំរាប់លើកកំពស់សេដ្ឋកិច្ច ក្នុងមូលដ្ឋានឃុំទាំងមូល។

ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងមូលដ្ឋានឃុំព្រងិលគឺជា កត្តាផ្តល់នូវផលប្រយោជន៏យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា :

▪ ការសាងសង់ផ្លូវ គឺជាការសំរួលដល់ការ ធ្វើដំណើរ និង ចរាចរគ្រប់ប្រភេទ ហើយនិងចូលរួមក្នុងការកាត់បន្ថយការចំណាយទៅលើការងារដឹកជញ្ជូន។ ការអភិវឌ្ឍន៏នេះ ថ្វីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ខ្លះៗក៏ដោយ ប៉ុន្តែវាផ្តល់នូវផលប្រយោជន៏ច្រើនដល់ប្រជាជនប្រើប្រាស់ ។

▪ ការសាងសង់ប្រឡាយដើម្បីធានាដល់ការស្រោចស្រពក៏ជាកត្តាផ្តល់នូវសារៈប្រយោជន៏ ក្នុងការបង្កើននូវប្រាក់ចំណូល តាមរយៈការបង្កបង្កើនផល និង ដំណាំរួមផ្សំ។ នៅក្នុងឃុំព្រងិលតម្រូវការប្រើប្រាស់ទឹកសំរាប់ស្រោចស្រពគឺជា កត្តាសំខាន់ ថ្វីត្បិតតែការពង្រីកប្រពន្ធ័ស្រោចស្រពនេះជួបការលំបាកយ៉ាងណាក៏ដោយក៏ឃុំនៅតែព្យាយាមរកវិធីសាស្រ្តដោះស្រាយ និង ជំរុញអោយមាននិរន្តរភាពលើការងារនេះ ។

▪ ដោយឡែកចំពោះការពង្រីកវិស័យអប់រំ ដោយផ្តោតទៅលើ ការពង្រីកអាគារសិក្សា និង សាលាគឺជាការ ចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន។ បច្ចុប្បន្នទោះបីឃុំមានការខ្វះខាត ដីសំរាប់បង្កើតសាលាថ្មីសំរាប់ថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ។ ប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់នៅមានដីទូលាយដែលអាចសាងសង់អគារសិក្សាបន្ថែមបាន។ រីឯសាលាមតេយ្យវិញ ដោយមើលឃើញការលំបាកសំរាប់កុមារដែលគ្មានលទ្ធភាពក្នុងសិក្សានៅទីកន្លែងឆ្ងាយគឺ ជាអាទិភាពឃុំត្រូវព្យាយាមរកដំណោះស្រាយអោយខានតែបាននៅ

តាមបណ្តុភូមិគោលដៅ ព្រោះវាមានសារៈសំខាន់ និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល និងការបំពាក់បំប៉ន ចំណេះដឹង ដល់អនក្ខរៈជន ក្នុងមូលដ្ឋាន ។

### ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត




### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ក្បាលដីនៅក្នុងឃុំព្រងិល ត្រូវបានបែងចែកទៅតាមគោលការណ៍ចាប់តាំងពី ឆ្នាំ១៩៧៩ ដែលមានជាលក្ខណសត្យានុម័ត ចំពោះក្បាលដីថ្មី និងសំណង់រឹងមាំថ្មីត្រូវបានអនុវត្តតាមច្បាប់ភូមិបាលៈ ដូចជាការប្រើប្រាស់ដីសំរាប់លំនៅដ្ឋានរឺដីភូមិ។ ដីភូមិគឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋានដោយមានការដាំដំណាំរួមផ្សំ ដូចជា ដូង ស្វាយ ខ្នុរ ទាប ល្មុត ល្ហុង ចេក ។ល។ ស្របជាមួយគ្នានេះដែរប្រភេទ ដីលំនៅដ្ឋានអាចជាដីស្រែដែលមានលក្ខណៈទីសំណាប រឺ ដីសំរាប់ដាំដំណាំរយៈពេលខ្លី រួមមាន ដំណាំពោត សណ្តែក ត្រឡាច ននោង ល្ពៅ ដំឡូង ស្ពៃគ្រប់ប្រភេទ ។ល។

នៅក្នុងការបម្រែបម្រួលនូវក្បាលដីពីស្រែ មកជាដីលំនៅដ្ឋាន តាមរយៈរីករាលដាល នៃចំនួនគ្រួសាររបស់

ប្រជាពលរដ្ឋដោយមានការបែងចែកអោយកូនតាមក្បាលដីធំ រឺ តូច រីឯស្ថានភាពជាក់ស្តែង នៃការរីករាលដាលប្រភេទដីសង់លំនៅដ្ឋានភាគច្រើនតាមបណ្តោយផ្លូវ រឺ ជិតប្រភពទឹក ។

ការប្រើប្រាស់ដីស្រែនៅក្នុងឃុំព្រងិលចាត់ជាចំណាត់ថ្នាក់ពីប្រភេទគឺដីស្រែវស្សា ដីសំរាប់ស្រែប្រាំង ចំពោះដីស្រែវស្សាតម្រូវអោយដាំស្រូវសន្ទូងដូចជា ស្រូវស្រាល ស្រូវកណ្តាល ធ្ងន់ ហើយដីស្រែប្រាំងជួនធ្វើនៅលើផ្ទៃដីស្រែវស្សា និង តម្រូវអោយដាំពូជស្រូវទំនើបមានរយៈកាលលូតលាស់ខ្លីទទួលបានទិន្នផលខ្ពស់ ។

ការកើនឡើងនូវប្រភពដីស្រែ រឺដីចំការចាស់ៗដែលបានបោះបង់ចោលពីជំនន់មុន (សម័យសង្គ្រាមរហូតមកដល់របបប៉ុលពត) បានបន្សល់គ្រប់មីនជាច្រើនក្នុងដីដល់សព្វថ្ងៃ តែដោយសាអាជ្ញាធរភូមិឃុំខិតខំប្រឹងប្រែងទំនាក់ទំនងដល់អាជ្ញាធរជាតិ (CMAC )ជួយធ្វើអន្តរាគមន៍បោសសំអាត និងកំទេចចោលជាការងាយស្រួលពង្រីកដីស្រែចំការហើយត្រូវបានរៀបចំកែលំអរឡើងវិញតាមគុណភាពដីសមស្របសំរាប់ដំណាំកសិកម្ម ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋចូលរួមចំណែកបង្ករបង្កើនផលក្នុងមូលដ្ឋាន ។

ផ្អែកទៅតាមស្ថានភាពដីដែលនៅសល់បច្ចុប្បន្នមានសណ្ឋានដីជាប់ធនធានព្រៃឈើ ប៉ុន្តែដីប្រភេទនេះយើងត្រូវការផ្ទៀងផ្ទាត់អោយបានច្បាស់លាស់ទៅនឹងផែនទីគំរបព្រៃឈើជៀសវាងបង្កើតបញ្ហាអារវាងស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ម្យ៉ាងដែនព្រៃឈើពុំទាន់មានព្រំប្រទល់ច្បាស់លាស់នៅឡើយ ។

ការប្រើប្រាស់ដីព្រៃសហគមន៍ (ដីសាធារណៈរបស់រដ្ឋ) គឺត្រូវការពារថែរក្សាអោយបានគង់វង្ស ដូច្នេះឃុំត្រូវមានផែនការអភិរក្សលើធនធានទាំងនេះដើម្បីផ្តល់ជាផលប្រយោជន៍ បង្កើនប្រាក់ចំណូលប្រជាពលរដ្ឋ ពីការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព ។

នៅក្នុងឃុំព្រងិលមានការប្រើបាស់ដីផ្ទៃទឹកនានា (ស្ទឹងបឹង) ជាកត្តាចំបងសំរាប់ប្រជាពលរដ្ឋតាមមូលដ្ឋានដើម្បីបំរើផលប្រយោជន៍ដល់វិស័យកសិកម្ម និងការប្រើប្រាស់ជាលក្ខណៈទូទៅផ្អែកតាមធនធានទឹកដែលមានក្នុងឃុំ និង មានលទ្ធភាពទាញយកមកប្រើប្រាស់បានតែផ្ទៃទឹកបឹងតែប៉ុណ្ណោះ ដោយឡែកផ្ទៃទឹកស្ទឹងពុំមានលទ្ធភាពប្រើប្រាស់បានឡើយ លើកលែងតែប្រជាពលរដ្ឋមានលំនៅដ្ឋានជិតប្រភពផ្ទៃទឹកស្ទឹង ។

ការប្រែប្រួលដីពីប្រព័ន្ធប្រឡាយមកជាដីស្រែ រឺដីប្រឡាយចាស់មកប្រឡាយថ្មីនេះជាបញ្ហាចោទ ព្រោះថាមានករណីរំលោភយកដីប្រឡាយរាក់ធ្វើស្រែបើសិនឃុំត្រូវការអភិវឌ្ឍស្តារ និងជីកប្រឡាយឡើងវិញ បញ្ហាទំនាស់នឹងកើតមានឡើងហើយពិបាកដោះស្រាយ ដោយប្រជាពលរដ្ឋខ្វះការយល់ដឹងពីសារប្រយោជន៍ប្រព័ន្ធប្រឡាយ ។

ការប្រើប្រាស់ដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក៏មានបញ្ហាចោទខ្លះដែរ ប៉ុន្តែអាចដោះស្រាយបានព្រោះផ្លូវដែលកើតឡើងគឺ ការផ្តើមចេញពីប្រជាពលរដ្ឋផ្ទាល់ធ្វើអោយកើតនមានផ្លូវមុន បន្ទាប់មកឃុំសិក្សាលើគម្រោងអភិវឌ្ឍទៅតាមការស្នើឡើងពីប្រជាពលរដ្ឋទាំងផ្លូវចាស់ និង ផ្លូវថ្មី ។

លក្ខខណ្ឌ នៃបទបញ្ញត្តិ និង គោលការណ៍មួយចំនួន ក្នុងការប្រើប្រាស់ ដីធ្លីក្នុងពេលអនាគតត្រូវបានគិតគូរទៅតាមស្ថានភាពដូចខាងក្រោម :

### ៣.២.៣.១ ដីលំនៅដ្ឋាន (គោលការណ៍ និង បញ្ញត្តិ នៃការប្រើប្រាស់ដី)

តាមស្ថានភាពជាក់ស្តែងដែលបានគ្រោងទៅលើ ក្នុងអត្រាកំណើនរបស់ប្រជាពលរដ្ឋចំនួន ៥៣៦គ្រួសារក្នុងរយៈពេល ១៥ឆ្នាំខាងមុខ។ តាមគោលការណ៍សម្បទានដីសង្គមកិច្ចការផ្តល់ដីសំរាប់សង់លំនៅដ្ឋានក្នុងមួយគ្រួសារចំនួន ០,២៥ ហិកតា ប៉ុន្តែឃុំពុំមានលទ្ធភាពក្នុងរកដីដើម្បីផ្តល់អោយគ្រួសារ ដែលខ្វះដីតាមការគណនាខាងលើនោះទេ ដូច្នេះឃុំត្រូវគិតគូរទៅលើការកំណត់ផ្ទៃដីភូមិ ហើយត្រូវបានកំណត់លើការបែងចែក និងទៅតាមលទ្ធភាពក្នុងតំបន់គោលដៅមួយចំនួនដូចខាងក្រោមៈ

➢ **ទីតាំងដីលេខកូដៈ ១២០០១**

នៅក្នុងភូមិព្រងិលដែលមានកូដអភិវឌ្ឍន៍លេខ ១២០០១ ត្រូវបានកំណត់លើការពង្រីកដីលំនៅដ្ឋានដែលមានទំហំ ៤៣ ហិកតាសំរាប់ប្រជាពលរដ្ឋចំនួន ១៧២គ្រួសារ សំរាប់៥ឆ្នាំទី១ បានគិតគូរផ្អែកតាមបណ្តោយផ្លូវដែលបានគ្រោង និងធ្វើការសាងសង់ដែលប្រភេទ នៃការបែងចែកត្រូវបានកំណត់ ក្បាលដី ២៥ម x ១០០ម ។

➢ **ទីតាំងដីលេខកូដៈ ១២០០២**

នៅក្នុងភូមិស្វាយប៉ាកដែលមានកូដអភិវឌ្ឍន៍ ១២០០២ ត្រូវបានកំណត់លើការពង្រីកដីលំនៅដ្ឋាន ដែលមានទំហំ ៣៦ ហិកតាសំរាប់ប្រជាពលរដ្ឋចំនួន ១៤៤គ្រួសារ សំរាប់៥ឆ្នាំទី២ តាមការកំណត់នេះគឺ ត្រូវបានគិតគូរផ្អែកតាមបណ្តោយផ្លូវដែលបានគ្រោង និង ធ្វើការសាងសង់ដែលប្រភេទ នៃការបែងចែកត្រូវបានកំណត់ក្បាលដី ២៥ម x ១០០ម ។

➢ **ទីតាំងដីលេខកូដៈ ១២០០៣**

នៅក្នុងភូមិសំរោងយាដែលមានកូដអភិវឌ្ឍន៍ ១២០០៣ ត្រូវបានកំណត់លើការពង្រីកដីលំនៅដ្ឋាន ដែលមានទំហំ ១០ ហិកតា សំរាប់ប្រជាពលរដ្ឋចំនួន ៤០គ្រួសារ សំរាប់៥ឆ្នាំទី៣ តាមការកំណត់នេះគឺត្រូវបានគិតគូរផ្អែកតាមបណ្តោយផ្លូវដែលបានគ្រោង និង ធ្វើការសាងសង់ដែលប្រភេទ នៃការបែងចែកត្រូវបានកំណត់ក្បាលដី ២៥ម x ១០០ម ។

### ៣.២.៣.២ ដីស្រែជាមួយភូមិ (គោលការណ៍ និង បញ្ញត្តិ នៃការប្រើប្រាស់ដី )

➢ **ទីតាំងដីលេខកូដៈ ២១១១១**

ការគ្រោងពង្រីកដីស្រែលាយលំនៅដ្ឋានដែលស្ថិតនៅក្នុងភូមិព្រងិលមានទំហំ ៧៨៣ ហិកតា ដីនេះសំរាប់ផ្តល់អោយគ្រួសារដែលធ្វើចំណូលស្រុកមកពីកន្លែងផ្សេងៗ ក្នុងគោលបំណងបញ្ចៀសការលបលួចកាប់រានដីព្រៃសំរាប់តាំងលំនៅដ្ឋាន និងធ្វើកសិកម្ម សំរាប់ធ្វើសម្បទានដល់គ្រួសារដែលគ្មានដីធ្លីពិតប្រាកដ ហើយដែលបានសង់

លំនៅដ្ឋានលើដីសាធារណៈផងដែរ ។ តាមការគ្រោងទុក ឃុំមានផែនការក្នុងការផ្តល់ដីសំរាប់សំរាប់សង់លំនៅដ្ឋានផង និងធ្វើកសិកម្មផង ដែលតាមគោលការណ៍សម្បទានសង្គមកិច្ចត្រូវផ្តល់ដីទំហំ ០,២៥ ហិកតា សំរាប់សង់លំនៅដ្ឋានក្នុងមួយគ្រួសារ និងសំរាប់កសិកម្មទំហំ ២,៥០ ហិកតាក្នុងមួយគ្រួសារ។ ដូច្នេះ ទីតាំងដីលេខកូដ ២១១១១ ដែលមានទំហំ ៧៨៣ ហិកតា អាចធើការផ្តល់ជូនដល់គ្រួសារដែលគ្មានដីបានចំនួន ២៨៥ គ្រួសារដែលក្នុងមួយគ្រួសារអាច ទទួលបានដីសរុបទំហំ ២,៧៥ហិកតា ។ សំរាប់ឆ្នាំទី១ ចំនួន ២៧៥ ហិកតា សំរាប់ប្រជាពលរដ្ឋ ចំនួន ១០០គ្រួសារ និងឆ្នាំទី២ ចំនួន ២៧៥ ហិកតា សំរាប់ប្រជាពលរដ្ឋ ចំនួន១០០គ្រួសារ និងឆ្នាំទី៣ ចំនួន ២៣៣ ហិកតា សំរាប់ប្រជាពលរដ្ឋ ចំនួន ៨៥ គ្រួសារ ។

## ✄ **បញ្ញត្តិ នៃការប្រើប្រាស់ដី សំរាប់សង់លំនៅដ្ឋានថ្មី :**

នៅក្នុងការពង្រីកដីលំនៅដ្ឋាន ឃុំមានគោលការណ៍រៀបចំ ដីភូមិ ដែលមានការកំណត់ និង ជំរុញអោយមានដីភូមិដែលមានសណ្តាប់ធ្នាប់សាធារណៈល្អ ហើយក្នុងនោះត្រូវបានអនុវត្តន៏ :

- រាល់ដីភូមិ ដែលត្រូវរៀបចំថ្មី ត្រូវបានកំណត់ទុកដីចំណីផ្លូវស្របតាមច្បាប់កំណត់
- ចំពោះដីភូមិដែលរៀបចំថ្មីនៅ តាមប្រឡាយ ឬប្រភពទឹកនានាត្រូវអនុវត្ត ដោយទុកចំណីប្រឡាយស្ទឹង ឬ អូរ តាមការកំណត់នៃច្បាប់ ។
- ការសាងសង់លំនៅដ្ឋានក្នុងភូមិ ត្រូវអនុវត្តទៅតាមច្បាប់អនុញ្ញាត
- ជំរៅដីសំរាប់លំនៅដ្ឋានមិនអាចលើសពី ១០០ ម. គិតពីអក្ស័ផ្លូវ
- រាល់ដីភូមិដែលកើតថ្មី ត្រូវមានការកំណត់ព្រំប្រទល់ដោយមានការឯកភាពរវាងភាគីពាក់ពន្ធ័ដែលមានព្រំជាប់គ្នា និងត្រូវបោះបង្គោលរបងកំណត់ព្រំច្បាស់លាស់ ។
- ជំរុញ និងផ្សព្វផ្សាយអោយមានការចូលរួមបង្កើនទូវផលិតផលតាមរយៈការរៀបចំជាសួនដំណាំ ក្នុងដីភូមិ ដូចជា សួនបន្លែ និង ដំណាំរួមផ្សំ រយៈពេលខ្លី និង វែង ដែលជាកត្តាជួយអោយក្នុងភូមិមានសភាពបៃតង ធានានូវការផ្គត់ផ្គង់ម្ហូបអាហារ និងមានលទ្ធភាពអាចបង្កើនប្រាក់ចំណូលក្នុងគ្រួសារលើសកម្មភាពទាំងនេះផងដែរ ។
- ចំពោះប្រជាពលរដ្ឋដែលរស់នៅ លើដីសាធារណៈរបស់រដ្ឋ ( ដីមាត់ស្ទឹង ) បច្ចុប្បន្នអ្នកដែលរស់នៅចាស់ មានការលំបាកក្នុងការផ្លាស់ប្តូរ ហើយជាបណ្តើរៗឃុំ នឹងព្យាយាមធ្វើការដោះដូរ និងរៀបចំអោយបានត្រឹមត្រូវ ប៉ុន្តែជាគោលការណ៍ ឃុំធ្វើការហាមឃាត់ដាច់ខាតការសាងសង់លំនៅដ្ឋានថ្មីលើដីសាធារណៈ ។

### ៣.២.៣.៣ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន

➢ ការប្រើប្រាស់ដីក្នុងតំបន់ដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ គឺជាដីសាធារណៈរបស់រដ្ឋ ដែលទាមទារអោយមានការថែរក្សា ដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការប្រើប្រាស់ដី ក្នុងតំបន់នេះត្រូវធ្វើការគិតគូរទៅលើសកម្មភាពនៃការ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍន៏ទៅ លើធនធានធម្មជាតិគ្រប់ប្រភេទ។

➢ នៅក្នុងឃុំព្រងិល មានសហគមន៍ព្រៃឈើចំនួន៥ ដែលបានរៀបចំបង្កើតឡើងដើម្បី ថែរក្សា ការពារធនធានព្រៃឈើទាំងនោះនៅនៅគង់វង្ស ក្នុងគោលបំណង នៃការបង្កើតសហគមន៍ទាមទារអោយក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋមានឆន្ទៈជាម្ចាស់ទើបអាចមានប្រសិទ្ធិភាពក្នុងការថែរក្សា និងការពារធនធាន ជាពិសេសចាំបាច់ត្រូវគោរពតាមលក្ខន្តិកៈសហគមន៏ដែលបានចែង និង ត្រូវរៀបចំផែនការដាំកូនឈើបន្ថែមក្នុងសហគមន៏ ដើម្បីធានានូវការប្រើប្រាស់ក្នុងពេលអនាគត។

➢ ស្របជាមួយនឹងផែនការ នៃការគ្រប់គ្រង និងថែរក្សាធនធានដែលមាននៅក្នុងសហគមន៏ ដែលបានបង្កើតពីមុនមក ឃុំនៅមានផែនការបង្កើតសហគមន៍ព្រៃឈើចំនួន ០១សហគមន៍ទៀត ស្ថិតនៅក្នុងភូមិសាយ ដែលមានទំហំ ១២៣០ ហិកតា ដែលគ្រោងនឹងរៀបចំនៅក្នុង ៥ឆ្នាំទី១ ។

#### ✄ គោលការណ៏ និង បញ្ញត្តិ នៃការប្រើប្រាស់ធនធានធម្មជាតិ

នៅក្នុងក្របខណ្ឌ័នៃការគ្រប់គ្រង និងប្រើប្រាស់ធនធានរបស់សហគមន៏ព្រៃឈើ ត្រូវបានរៀបចំគ្រប់គ្រង និង ប្រើប្រាស់ទៅលើព្រៃឈើ អនុផលព្រៃឈើ ដែលក្នុងនោះត្រូវបានបែងចែកដូចខាងក្រោម:

- កំណត់ការដកយកផល និង អនុផលព្រៃឈើ ត្រូវបានដាក់បញ្ចូលទៅក្នុង ផែនការគ្រប់គ្រងសហគមន៏ព្រៃឈើ ។
- ហាមការ ចាប់សត្វព្រៃគ្រប់ប្រភេទ នៅក្នុងកន្លែងព្រៃអភិរក្ស និងក្នុងសហគមន៏ព្រៃឈើ
- ការកាប់ព្រៃធ្វើអុសត្រូវគោរពតាមលក្ខន្តិកៈសហគមន៏
- ហាមការកាប់រាន ដីព្រៃឈើក្នុងតំបន់អភិរក្ស និងក្នុងសហគមន៏ព្រៃឈើ

### ៣.២.៣.៤ ការប្រើប្រាស់ប្រពន្ធ័ស្រោចស្រព

ការប្រើប្រាស់ប្រពន្ធ័ស្រោចស្រព នៅក្នុងឃុំ គឺ ជាកត្តាចំបង សំរាប់ប្រជាជន ក្នុងមូលដ្ឋាន ដើម្បី បំរើផលប្រយោជន៏អោយវិស័យកសិកម្ម ឃុំអាច មានលទ្ធភាពក្នុងការដកយកមកប្រើប្រាស់បានតែ ប្រភេទទឹកស្ទឹង និងបឹង តែប៉ុណ្ណោះ ដោយឡែកចំពោះប្រពន្ធ័ប្រឡាយបច្ចុប្បន្ន ពុំអាចមានលទ្ធភាពក្នុងការប្រើប្រាស់បានឡើយ

ទាមទាអោយឃុំមានផែនការស្តារនូវប្រឡាយចាស់ ( ប្រឡាយដែលបានរីងរាក់ ) និងជីកប្រឡាយថ្មី ដើម្បីទាញយកទឹកមកស្រោចស្រព្វដីកសិកម្ម ។

ការប្រែប្រួល ពីដីស្រែមកជាដីប្រពន្ធ័ប្រឡាយ ឬដីប្រឡាយ មេចាស់ មកជាប្រឡាយថ្មី ជាបញ្ហាចោទព្រោះថាមានការលំបាកសំរាប់ការ ដោះស្រាយ នូវបញ្ហាប្រឈមដោយបច្ចុប្បន្នមាន បញ្ហាមួយចំនួន នឹង ត្រូវកើតមានឡើងក្នុងពេលប្រឡាយចាប់ផ្តើមដំណើរការសាងសង់ និង ស្តារដូចជា ការរំលោភយកដីប្រឡាយធ្វើស្រែហើយបញ្ហាមួយផ្សេងទៀត ក្នុងករណីមានការសាងសង់ប្រឡាយថ្មី បញ្ហា នឹង កើតឡើងដោយសារការមិនយល់ពីសារៈប្រយោជន៏ក្នុងការប្រើប្រាស់ប្រឡាយ ។ ដូច្នេះបញ្ហានៃការប៉ះពាល់ដីស្រែ ធ្វើអោយឃុំមានការប្រឈមមុខក្នុងការដោះស្រាយជាមួយប្រជាជនយ៉ាងខ្លាំង ត្រូវការការគាំទ្រពីស្ថាប័នជំនាញ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ។

### ➯ ទីតាំងដីប្រឡាយមេលេខកូដ: ៥៦០១

ក្នុងការរៀបចំស្តារប្រឡាយមេ ដែលមានកូដ ក្នុងផែនទីលេខ ៥៦០១ មានប្រវែង ២,២៦១ ម៉ែត្រ ស្ថិតនៅក្នុងភូមិអូរស្រាវ ហើយដែលត្រូវបានអនុវត្ត ក្នុងការរៀបចំស្តារជាប្រឡាយមេឡើងវិញដែលមាន ភ្លឺទំនប់ដែលអាចមានលទ្ធភាពក្នុងការប្រើប្រាស់ជាផ្លូវអាចធ្វើដំណើរបាន ដែលត្រូវស្តារនៅក្នុង ៥ឆ្នាំទី១ ។

### ➯ ទីតាំងដីប្រឡាយមេលេខកូដ: ៥៦១១

ក្នុងការរៀបចំស្តារប្រឡាយរង ដែលមានកូដ ក្នុងផែនទីលេខ ៥៦១១ មានប្រវែង ៣,៦៥៦ ម៉ែត្រស្ថិតនៅក្នុងភូមិស្វាយប៉ាក ហើយដែលត្រូវបានអនុវត្ត ក្នុងការរៀបចំស្តារជាប្រឡាយមេឡើងវិញដែលមាន ភ្លឺទំនប់ដែលអាចមានលទ្ធភាពក្នុងការប្រើប្រាស់ជាផ្លូវអាចធ្វើដំណើរបាន ដែលត្រូវស្តារនៅក្នុង ៥ឆ្នាំទី២ ។

### ✄ <u>គោលការណ៍ និង បញ្ញត្តិ នៃការស្តារប្រឡាយ</u> :

- នៅក្នុងលក្ខខណ្ឌ៍នៃការស្តារប្រឡាយ ត្រូវមានការកំណត់អោយបានច្បាស់ទៅលើការដោះស្រាយ បញ្ហា ទើបដំណើរការប្រព្រិត្តទៅទទួលជោគជ័យ ។
- រៀបចំគណៈកម្មការ ចុះដោះស្រាយ អនុវត្ត និងថែទាំ
- ការស្តារ ត្រូវអនុវត្តទៅតាមផែនការដែលបានគ្រោងទុក ( ទំហំប្រឡាយ ៤ម . ជំរៅ ២,៥ម ) ដោយមានភ្លឺប្រឡាយសងខាង ០២ម ដោយចោលពីមាត់ប្រឡាយ ១,៥ម ។
- ការស្តារប្រឡាយចាស់ ត្រូវអនុវត្ត សមស្របទៅតាមទំហំប្រឡាយចាស់
- ត្រូវធ្វើការដោះស្រាយ អោយបានរួចរាល់នូវការ រំលោភយកដីប្រឡាយ ចាស់ និងកែសំរួលទៅតាមស្ថានភាពជាក់ស្តែង និង សមស្របតាមគោលការណ៏ច្បាប់ ។

### ៣.២.៣.៥ ការសាងសង់ និងការប្រើប្រាស់ផ្លូវថ្នល់ :

ចំពោះកាប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ថ្មី ក៏អាចមានបញ្ហាខ្លះដែរ ព្រោះថា ត្រូវធ្វើលើដីថ្មីដែលមានកម្មសិទ្ធិរួចហើយ ឬកំពុងប្រើប្រាស់ដោយប្រជាពលរដ្ឋ ដូច្នេះចាំបាច់ត្រូវធ្វើលទ្ធកម្មដីធ្លីជាមុនសិន។ ប៉ុន្តែបើសិនជាមិនមានការកើតផ្លូវថ្មីទេនោះយើងនឹងមិនជួបបញ្ហាដូចខាងលើទេ នៅក្នុងការគ្រោងទុករបស់ឃុំឃើញថាពុំមានផ្លូវណាដែលត្រូវកើតលើដីថ្មីនោះទេ គឺជាផ្លូវដែលមានស្រាប់គ្រាន់តែលើកបន្ថែម ជួសជុល កែលំអរ ដូច្នេះឃុំអាចដោះស្រាយបាន ដោយលើកផែនការរយៈពេល១៥ ឆ្នាំដែលមានសកម្មភាពមួយចំនួនដូចខាងក្រោមៈ

#### ➢ ទីតាំងផ្លូវគ្រួសក្រហមមានលេខកូដៈ ២២០១

នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំគ្រោងក្រាលគ្រួសក្រហមលើផ្លូវដីសរ ដែលមានប្រវែង ១ គ.ម ស្ថិតនៅក្នុង ភូមិព្រងិល ផ្លូវនេះគ្រោងអនុវត្តន៍ នៅ៥ឆ្នាំទី១។

#### ➢ ទីតាំងផ្លូវគ្រួសក្រហមមានលេខកូដៈ ២២០២

នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំគ្រោងក្រាលគ្រួសក្រហមលើផ្លូវដីសរ ដែលមានប្រវែង ២ គ.ម ស្ថិតនៅក្នុងភូមិកំពែងទៅមាត់ស្ទឹង ផ្លូវនេះគ្រោងអនុវត្តន៍ នៅ៥ឆ្នាំទី២។

#### ➢ ទីតាំងផ្លូវគ្រួសក្រហមមានលេខកូដៈ ២២០៣

នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំគ្រោងក្រាលគ្រួសក្រហមលើផ្លូវដីសរ ដែលមានប្រវែង ១៦០០ ម៉ែត្រ ស្ថិតនៅក្នុងភូមិកំពែង ទៅភូមិស្វាយប៉ាក ផ្លូវនេះគ្រោងអនុវត្តន៍ នៅ៥ឆ្នាំទី៣។

#### ➢ ទីតាំងផ្លូវចាក់ដីសលេខកូដ : ៣៣០១, ៣៣០២, ៣៣០៣ ៣៣០៤, ៣៣០៥, ៣៣០៦ និង ៣៣០៧

នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំគ្រោងលើកផ្លូវដីសលើផ្លូវរទេះដែលមានប្រវែងសរុប ២៥.៤៧០ ម៉ែត្រ ផ្លូវនេះគ្រោងអនុវត្តន៍ នៅ៥ឆ្នាំទី១។

#### ➢ ទីតាំងផ្លូវចាក់ដីសលេខកូដ : ៣៣០៨, ៣៣០៩, ៣៣១០ ៣៣១១, ៣៣១២, ៣៣១៣ និង ៣៣១៤

នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំគ្រោងលើកផ្លូវដីសលើផ្លូវរទេះដែលមានប្រវែងសរុប ៣២.១៥០ម៉ែត្រ ផ្លូវនេះគ្រោងអនុវត្តន៍ នៅ៥ឆ្នាំទី២។

### ➪ ទីតាំងផ្លូវចាក់ដីសលេខកូដ : ៣៣១៥, ៣៣១៦, ៣៣១៧ ៣៣១៨, ៣៣១៩, ៣៣២០ និង ៣៣២១

នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំគ្រោងលើកផ្លូវដីសលើផ្លូវរទេះដែលមានប្រវែងសរុប ១១.៨៨០ម៉ែត្រ ផ្លូវនេះគ្រោងអនុវត្តន៍ នៅ៥ឆ្នាំទី៣។

### ✄ <u>គោលការណ៍ និង បញ្ញត្តិ នៃការប្រើប្រាស់ផ្លូវថ្នល់</u> :

ក្នុងលក្ខណៈបច្ចេកទេស នៃការសាងសង់ ផ្លូវ ត្រូវបានកំណត់សំរាប់ផ្លូវ ដូចខាងក្រោម :

- ផ្លូវក្រាលគ្រួសក្រហម ក្នុងក្រខណ្ឌមូលដ្ឋានឃុំ ត្រូវទុកដីចំណីផ្លូវ ១៥ ម សងខាង
- ផ្លូវលំចាក់ដីស ទំហំ ៤ ម ក្នុងក្របខណ្ឌមូលដ្ឋានឃុំ ត្រូវទុកដីចំណីផ្លូវ ១៥ ម សងខាង
- ការកំណត់លើការប្រើប្រាស់ផ្លូវថ្នល់ត្រូវ អនុលោមទៅតាម ច្បាប់
- បង្កើតគណៈកម្មការ ថែទាំ ផ្លូវលំ ដោយមានការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ហាមការដឹកជញ្ជូន លើសទំងន់
- ហាមការយក គោ ក្របី ជ្រូក ចងលើផ្លូវ
- រៀបចំ ស្លាកសញ្ញាចរាចរ តាមបណ្តោយផ្លូវ

ព្រងិល, ថ្ងៃទី ៤ ខែ [illegible] ឆ្នាំ ២០០៩

**មេឃុំ**

ឃុំ ព្រងិល

អ៊ុក រី

## បានឃើញ និង ពិនិត្យត្រឹមត្រូវ

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត
និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋ ខេត្តពោធិ៍សាត់

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

ភ្នំក្រវាញ, ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០០៩

**អភិបាល នៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារជីវរដ្ឋ ស្រុកភ្នំក្រវាញ**

ទូច_សំបូរ

***អនុសាសន៍:***

១. [illegible]

២. [illegible]

## បានឃើញ និង ឯកភាព

ពោធិ៍សាត់, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០

**អភិបាល នៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋ ខេត្តពោធិ៍សាត់**

ខូយ_សុខា

# ឧបសម្ព័ន្ធ ១

## ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១. ដីលំនៅដ្ឋានភូមិ

#### - ដីភូមិលាយសួនដំណាំ

(ដីភូមិមានចំនួន៥៣០ហ.ត) ជាដីស្របច្បាប់របស់ប្រជាពលរដ្ឋនៅក្នុងឃុំព្រងិលហើយច្រើនរស់នៅតាមដងផ្លូវ និង ជាភូមិជាពិសេសនៅតាមដងស្ទឹងពោធិ៍សាត់ដែលមានប្រភពទឹកច្រើន ដីមានជីវជាតិអាចប្រកបមុខរបរបង្កបង្កើនផលកសិកម្មបានប្រជាពលរដ្ឋមួយចំនួនប្រមូលផ្តុំនៅជាក្រុមៗក្នុងតំបន់ខ្ពង់រាប ហើយភាគច្រើនប្រជាពលរដ្ឋរស់នៅទៅតាមធម្មជាតិ និងយដ្ឋាផល ។

ដីភូមិលាយសួនដំណាំនៅក្នុងឃុំព្រងិលភាគច្រើនជាដីទីទួលស្ថិតតាមដងផ្លូវខ្លះ និងដីភូមិដែលមានសណ្ឋានដីខ្ពង់រាប ខ្លះទៀតដីទួលខ្ពស់ដោយសារចាក់បំពេញធ្វើជាភូមិដ្ឋាន។ ជាមួយនេះផងដែរដីភូមិទាំងនេះត្រូវបានដាំដំណាំរួមផ្សំជាច្រើនមុខដូចជាៈ ដូង ស្វាយ ល្មុត ទាប ខ្នុរ ចេក ដំឡូង ស្លែ ម្ទេស ត្រឡាច ននោង ល្ពៅ ស្លឹកគ្រៃ ស្ពំ.... ។ល។ ដំណាំរួមផ្សំប្រភេទនេះច្រើនដាំនៅលើដីទំនេរជិតប្រពភទឹក ហើយជាមធ្យមផ្ទៃដីភូមិលាយសួនដំណាំមានទំហំ 0.៧0 ហិកតាក្នុងមួយគ្រួសារ។

បើតាមការសិក្សាជាក់ស្តែងឃើញថា លទ្ធភាពសំរាប់ដីភូមិលាយសួនដំណាំក្នុងឃុំព្រងិលគឺមានប្រភពទឹកពីបឹងកំពែងដែលអាចផ្តល់សេវាស្រោចស្រព្វដល់ដំណាំរួមផ្សំនៅរដូវប្រាំងបានមួយចំនួនដែលនៅជិតប្រភពទឹក តែមួយចំនួនទៀតដែលនៅឆ្ងាយពីប្រភពទឹកពុំអាចមានលទ្ធភាពទទួលបាននូវសេវាស្រោចស្រព្វពេញលេញបានឡើយ។ ជាក់ស្តែនៅរដូវប្រាំងពុំសូវឃើញមានប្រជាពលរដ្ឋចូលរួមលើកស្ទួយក្នុងការដាំដុះដំណាំឡើយ បើតាមការទទួលព័ត៌មានពីក្រុមប្រឹក្សាឃុំ អោយដឹងថាបណ្តាលមកពីកត្តាខ្វះប្រពន្ធ័ទឹកស្រោចស្រព្វនៅរដូវប្រាំង។ ដូច្នេះឃុំត្រូវធ្វើការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធធារាសាស្រ្តអោយបានល្អប្រសើរឡើងវិញ។

### ២. ដីស្រែវស្សាៈ

**- ដីស្រែវស្សាសំរាប់ស្រូវសន្ទូងៈ** (មានចំនួន៣.00១ហ.ត) ប្រជាពលរដ្ឋនៅក្នុងឃុំទាំងមូលធ្វើស្រែពឹងផ្អែកទៅលើទឹកភ្លៀង ហេតុនេះហើយកសិករមិនអាចធ្វើស្រែអោយអស់ផ្ទៃដីបានទេ ព្រោះមានការលំបាកជួបនឹងភាពរាំងស្ងួតធ្វើស្រែគឺ ពឹងទៅលើកត្តាធម្មជាតិតែមួយមុខប៉ុណ្ណោះ។ ហេតុដូច្នេះហើយទើបប្រជាពលរដ្ឋពុំសូវមានជីវភាពធូរធា ភាគច្រើនជួបការលំបាកក្នុងជីវិតគ្រួសារ ដោយគ្មានលទ្ធភាពនាំយកប្រភពពីទីឆ្ងាយមកប្រើប្រាស់ ស្រោចស្រព្វលើដំណាំស្រូវវស្សា។ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនដែលមានស្រែជិតប្រភពទឹកមានលក្ខណៈងាយ ស្រួលល្អប្រសើរអាចប្រកបរបរកសិកម្មលើដំណាំស្រូវវស្សាបានទាន់ពេលវេលា ទោះបីជួបប្រទះ

និងភាពរាំងស្ងួត ក៏នៅមានលទ្ធភាពថែទាំផលដំណាំបានដែរ ចំពោះពូជស្រូវវស្សាភាគច្រើនប្រជាពលរដ្ឋនិយមដាំអោយមានលក្ខណៈ សមស្របតាមសណ្ឋានដីស្រែវស្សាគឺពូជស្រូវ សុម៉ាលី ផ្កាម្លិះ ផ្ការំដួលសុទ្ធតែស្រូវលេខ ០១ ចំណែកស្រូវ លេខ០២ មានដូចជា ផ្កាដូង ផ្កាខ្ញី នាងមិញ ប្រភេទពូជស្រូវទាំងអស់នេះ ជាតម្រូវការទីផ្សារលក់បានថ្លៃ និង ពូជធ្ងន់មួយរយមុខក៏អាចដាំលើផ្ទៃដីស្រែវស្សាបានដែរ ។

**៣. ដីស្រែលាយភូមិ :**

(មានចំនួន១.១៣១ហត) ភាគច្រើនដីមានភូមិមានស្រែនៅជុំវិញដែលមិន អាចដាំដំណាបាននៅរដូវវស្សា កសិករភាគច្រើនចេះតែយកដីនៅក្បែរៗភូមិធ្វើជាស្រែប្រសើរជាងទុកនៅទំនេរចោលភាគច្រើនយកធ្វើជាទីសំណាប ម្យ៉ាងវិញទៀតកសិករអាចយកដីស្រែមកប្រើប្រាស់សំរាប់ដាំដំណាំផ្សេងៗនៅរដូវប្រាំងដូចជា ពោត សណ្តែក ត្រសក់ ននោង ត្រឡាច ល្ពៅ ស្ពៃឆៃថាវ សាឡាត់..។ល។ ស្រែនៅក្នុងដីភូមិ ច្រើន មានទំហំតូចៗ ប្រហែល ១៥០ ម៉ែត្រក្រឡាតាមផ្ទះនីមួយៗហើយភាគច្រើនស្ថិតនៅខាងក្រោយផ្ទះ រឺមុខផ្ទះដីប្រភេទនេះទៅថ្ងៃអនាគត នឹងក្លាយជាដីភូមិដែលត្រូវឪពុកម្តាយចែកអោយកូន ដូច្នេះសក្តានុពលនៃការប្រើប្រាស់ដីឃើញថា គ្មានតុល្យភាព និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឡើយ ។

**៤. ចំការស្រូវ:**

ចំការស្រូវជាទូទៅច្រើតែរានដីព្រៃធ្វើជាចំការស្រូវ ចំការ ប្រភេទនេះមិនត្រូវការទឹកជោគជាំនោះទេ កសិករនៅតំបន់ខ្ពង់រាបចូលចិត្តធ្វើចំការស្រូវនេះណាស់ ព្រោះមិនចាំបាច់ដកស្ទូង។ នៅពេលដើមឆ្នាំប្រជាពលរដ្ឋចាប់ផ្តើមកាប់ព្រៃហើយដុតអោយឆេះសុះអស់ រួចបុកដាំស្រូវតែម្តងនៅក្នុងចន្លោះស្រូវកសិករអាចយកគ្រាប់ពោតមកបុកដាំនូវចន្លោះគុម្ពស្រូវពីព្រោះ ពោត អាចទទួលផលមុនផលស្រូវ។ ដីចំការដំណាំស្រោចស្រព្វដីចំការដំណាំនៅក្នុងឃុំព្រងិលមានចំនួន១៨៤.២១ហ.តចែកជាពីផ្នែកមួយផ្នែក តំបន់វាលទំនាប និងមួយផ្នែកនៅតំបន់ខ្ពង់រាបជារៀងរាល់ឆ្នាំ កសិករតែងតែប្រើប្រាស់ក្នុងការដាំដំណាំនានា ដូចជា ពោត សណ្តែក ល្ង ត្រឡាច ល្ពៅ ត្រប់ និង ឈើហូបផ្លែ ការដាំដំណាំទាំងនះមិនបានទិន្នផលខ្ពស់ទេមូលហេតុ ដោយសត្វល្អិតបំផ្លាញគ្មានប្រភបទឹកគ្រប់គ្រាន់ម្យ៉ាងទៀតខ្វះបច្ចេកទេសក្នុងការដាំដុះ។

**៥. ដីចំការដំណាំ:** ( មានចំនួន១៨៤ហ.ត ) កសិករភាគច្រើនដាំដំណាំអាហាររួមផ្សំច្រើនប្រភេទដូចជា ដំណាំឪឡឹក ដំណាំល្ង ដំណាំពោត ដំណាំសណ្តែកបាយ ដំណាំសណ្តែកដី ក្នុងនោះក៏មានដំណាំរយៈពេលវែងដូចជាក្រូចពោធិ៍សាត់ ក្រូចខ្វិច ដូង ស្វាយ ខ្នុរ ទាប ល្មុត ល្ហុង ស្វាយចាន់ទី ជាដើម។ ហើយប្រភេទដីចំការដំណាំជាប្រភេទដីល្បាយខ្សាច់មានជីវជាតិក៏រិតមធ្យម និងមានសំណើមក្នុងដីខ្ពស់ ។

**៦. ចំការដំណាំក្បែរប្រភពទឹក:** (៤៩៦.៩៦ហ.ត) ប្រជាពរដ្ឋមួយភាគធំនៅក្នុងឃុំព្រងិលច្រើនប្រកបមុខរបរកសិកម្មជាលក្ខណៈគ្រួសារទៅតាមរដូវកាល ជាពិសេសនៅរដូវរំហើយ និង ក្រោយពីការច្រូតកាត់ និងប្រមូលផលស្រូវរួច និងមានផ្ទៃដីទំនេ។ភាគច្រើនការប្រមូលផ្តុំបង្ករបង្កើនផលកសិកម្មតែងតែនៅជិតប្រភពទឹក ដើម្បីបង្កនូវភាពងាយស្រួលសំរាប់ធ្វើការស្រោចស្រព្វ និងទាញយកផលដំណាំពីកសិកម្ម។ ម្យ៉ាងវិញទៀតដីចំការដំណាំដែលនៅក្បែរប្រភពទឹកច្រើនតែដីសំបូរទៅដោយជីជាតិល្អ បានបទ្សល់ពីល្បាប់ភក់ក្រោយពីទឹកជំនន់នៅរដូវវស្សាដែលបាននាំមកនូវកំទេចកំទីស្លឹកឈើពុកផុយកប់ទៅក្នុងដីយូរខែ យូរឆ្នាំបង្កើតជាជីមមោគមាត់បឹង រីស្ទឹង។

**៧. ដីកសិកម្មពនេចរៈ** (មានចំនួន២០.៦១ ហ.ត )ដីកសិកម្មប្រភេទនេះប្រជាពលរដ្ឋដែលជាម្ចាស់កម្ម សិទ្ធិមិនសូវយក ចិត្តទុកដាក់ប៉ុន្មានទេច្រើនតែធ្វើតាមការនឹកឃើញតែប៉ុណ្ណោះ ម្យ៉ាងដីនៅឆ្ងាយពីលំនៅ ដ្ឋានភូមិ ផ្លូវពិបាកធ្វើដំណើរទៅមក។

**៨. ដីកសិកម្មពនេចរបោះបង់ចោលៈ** (មានចំនួន៩៤៥.៩៩ ហ.ត ) ដីប្រភេទនេះច្រើនតែមាននៅតំបន់ដាច់ឆ្ងាយពីភូមិ និងឃុំ ហើយភាគច្រើនម្ចាស់កម្មសិទ្ធិបានមកពីការទិញ ពីអាជ្ញាធ័រ ឬប្រជពលរដ្ឋក្នុងតំបន់ម្យ៉ាងដីកសិកម្មប្រភេទនេះច្រើនតែធ្វើមួយឆ្នាំ ឬពីឆ្នាំរួចទុកចោលយូរឆ្នាំតែម្តង។

**៩. ព្រៃស្រោងសើមៈ** (មានចំនួន៣៣៦៤៦.៩៩ ហត) ដីព្រៃប្រភេទនេះច្រើនមាននៅតាមជើងភ្នំ និង ជួរភ្នំដែលមានព្រៃក្រាស់ៗហើយជាតំបន់គំរបព្រៃដែលត្រូវអភិរក្ស និងដែនជំរកសត្វព្រៃដែលត្រូវការពារដោយច្បាប់។

**១០. ព្រៃរបោះៈ** (មានចំនួន ៥៩៧៧០.១៣ហ.ត ) ដីព្រៃប្រភេទនេះសឹងតែមានស្ថានភាពទូរទាំងឃុំក្នុងប្រទេសកម្ពុជា ភាគច្រើនជាដីព្រៃហើយទទួលរងឥទ្ធិពលពីមនុស្សដែលបានកាប់បំផ្លិចបំផ្លាញមួយចំនួនធំ និងមួយចំនួនទៀតជាតំបន់ព្រៃរិចរិលមិនអាចដុះព្រៃឡើងវិញបានទៅថ្ងៃអនាគត។

**១១. ព្រៃរបោះស្តើងស្ងួតៈ** (មានចំនួន៣១៧.៩៤ហ.ត ) ជាប្រភេទព្រៃរិចរិលពីធម្មជាតិពុំសូវសំបូរប្រភេទឈើមានតំលៃប៉ុន្មាននោះទេ ហើយវាមានប្រភពជិតលំនៅដ្ឋានភូមិរបស់ប្រជាពលរដ្ឋ ជាហេតុបង្កអោយមានលក្ខណៈងាយស្រួលក្នុងការប្រកបរបរអាជីវកម្មចិញ្ចឹមជីវិត ដោយវិធីកាប់អុសលក់ដើម្បីទ្រទ្រង់ជីវភាពរស់នៅក្នុងសង្គមគ្រួសារទៅថ្ងៃអនាគត។

**១២. ព្រៃចំរុះ**( មានចំនួន៥៨៨៩.៤៧ហ.ត ) ព្រៃប្រភេទនេះនៅជាមួយព្រៃស្រោងសើមលាយចំរុះគ្នា គ្រប់ប្រភេទមានដូចជាៈ ឈើខ្លុង ផ្ចឹក កកោះ ត្រាច ពពែល ធ្នុង ក្រញូង បេង ឈើទាល គគី នាងនួន.. ។ល ។ ច្រើនសំបូរនៅតាមគំរបព្រៃក្រាស់ៗតាមដងភ្នំនិងជួរភ្នំក្រវាញដែលជាប់ព្រំប្រទល់និងខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ។

**១៣. ព្រៃដុះតាមមាត់ទឹក : (ស្ទឹង អូរ...)**មានចំនួន៣៥៩៨.៦៧ហ.ត ព្រៃប្រភេទនេះច្រើន តែព្រៃឈើ តូចៗដូចជាដើម ត្រស់ដើមល្បៀង ដើមរាំងទឹក ដុះនៅលាយឡំគ្នាភាគច្រើននៅតាមមាត់ទឹក ស្ទឹង និងអូរហើយពុំមានសភាពព្រៃក្រាស់នោះទេ តែជាព្រៃដែលផ្តល់ផលប្រយោជន៍បានដូចជាអុសសំរាប់ដុតបន្តិចបន្តួចជាលក្ខលៈគ្រួសារ ។

**១៤. ព្រៃដុះឡើងវិញ :** មានចំនួន១២០.៨១ហ.ត ព្រៃប្រភេទនេះច្រើនតែកើតមានឡើងនៅតំបន់ដែលទទួលរងការកាប់បំផ្លាញពីសំណាក់ប្រជាពលរដ្ឋ រួចទុកចោលដោយពួកគាត់ខ្វះលទ្ធភាពកសាងផែនការកសិកម្មបន្តជាហេតុនាំអោយមានព្រៃដុះឡើងវិញតែការដុះនោះពុំមានលក្ខណៈគ្រប់គ្រាន់ដូចដើមវិញទេ ធ្វើអោយគំរបដីព្រៃមានសភាពស្តើង ។

**១៥. ចំការបោះបង់ចោលដុះស្មៅ :** មានចំនួន៧១៨.៧៧ ហ.ត ចំការប្រភេទនេះភាគច្រើនជា ដីខ្សោះជីវជាតិឆ្ងាយពីប្រភពទឹក គ្មានផ្លូវធ្វើដំណើរសមស្របប្រជាពលរដ្ឋមានការលំបាកក្នុងការរស់នៅហេតុនេះហើយបានជាដី ទាំងនោះដុះស្មៅឡើងវិញដោយគ្មានអ្នកធ្វើអាជីវកម្ម កសិកម្មនៅលើដីនោះ ។

**១៦. វាលស្មៅលិចទឹកៈ** មានចំនួន៩៣.៣៣ ហ.ត ជាដីវាលទំនាបភាគច្រើនមាននៅតាមមាត់ស្ទឹង ឬបឹងតែងតែលិចនៅរដូវវស្សាជាប្រចាំ នៅពេលដែលមានទឹកភ្លៀងធ្លាក់ញឹកញាប់ព្រមទាំងទទួលរងឥទ្ធិពលទឹកពីជំរាលភ្នំផ្នែកខាងលើ បើពុំសូវសម្បូរទឹកភ្លៀងទីវាលនោះអាចក្លាយជាវាលស្មៅសំរាប់សត្វពាហនៈគ្រប់រដូវកាល ។

**១៧. ព្រៃគុម្ពោតៈ** មានចំនួន ៣៧០.៥៦ ហ.ត ដីនៅក្នុងឃុំលាតសន្ធឹងយ៉ាងធំធេងគ្របដណ្តប់ទៅដោយព្រៃឈើ និងភ្នំតែតំបន់ខ្លះមានព្រៃឈើដុះតិចតូចជាគុម្ពោតៗដែលជាព្រៃឈើមិនអាចយកប្រើការបាន ។

**១៨. ចំការបោះបង់ចោលដុះព្រៃគុម្ពោតៈ** ដីប្រភេទនេះច្រើនតែគ្មានជីជាតិសំរាប់ធ្វើកសិកម្ម មិនបានផល ម្យ៉ាងឆ្ងាយពីប្រភពទឹកពិបាកក្នុងការរស់នៅគ្មានផ្លូវធ្វើដំណើរ ដីប្រភេទនេះត្រូវបានគេបោះបង់ចោលយូរឆ្នាំរួច ដុះព្រៃគុម្ពោតឡើងវិញ ។

**១៩. ដីព្រៃគុម្ពោធលាយដើមឈើធំៗ:** ដីព្រៃគុម្ពោធប្រភេទនេះច្រើនដុះនៅតាមភ្លឺស្រែ និងក្បាលដីស្រែ ព្រៃគុម្ពោធលាយដើមឈើធំៗមានសារៈសំខាន់ ដល់កសិករក្នុងការធ្វើស្រែចំការហើយនៅ រដូវ ប្រាំងស្លឹកឈើជ្រុះយូរៗក៏កកើត បានជា ជីធម្មជាតិធ្វើអោយដីផុសហើយម្យ៉ាងមានប្រយោជន៏ជាម្លប់សំរាប់មនុស្ស ឈប់សំរាកក្រោយពីពេលបង្កបង្កើនផលរួច និងផ្តល់ជាជំរកដល់សត្វពាហនៈទៀតផង។ ព្រៃគុម្ពោធរបៀបនេះត្រូវជួយការពារកុំកាប់បំផ្លាញចោល ទុកគ្រាន់ ជួយលំអរបរិស្ថាននិងកាត់បន្ថយកំដៅក្នុងបរិយាកាសបានមួយក៏រិត ។

**២០. ទឹកបឹងធម្មជាតិ:** នៅក្នុងឃុំព្រងិលមានបឹងធម្មជាតិចំនួនពីរគឺ បឹងកំពែង និងបឹងស្លាដែលអាចផ្តល់នូវលក្ខណ:ងាយស្រួលក្នុងការប្រើប្រាស់ធន់ធានទឹកជាប្រយោជន៏សំរាប់មនុស្ស និងសត្វពាហនៈ ហើយអាចស្រោចស្រព្វដល់ផលដំណាំកសិកម្មគ្រប់ប្រភេទ ពិសេសទទួលបានប្រភពមច្ឆាជាតិ សំរាប់ប្រជាកសិករនេសាទ ជាលក្ខណ:គ្រួសារគ្រាន់ទ្រទ្រង់ជីវភាពរស់នៅអោយមានភាពល្អប្រសើរឡើង។

ផ្ទៃក្រឡាបឹងកំពែងក្នុងមូលដ្ឋានឃុំមាន ២១.០៥ហិកតា ជាបឹងមានទឹកជាប្រចាំ ដោយឡែកបឹងស្លាមានការរីងរាក់ថែមទាំងមានការរំលោភយកដីបឹងដីប្រឡាយធ្វើស្រែនឹងកម្មសិទ្ធពីសំណាក់ប្រជាពលរដ្ឋដែលខ្វះការយល់ដឹងមួយចំនួននាសម័យបច្ចុប្បន្នយើងនេះជាហេតុនាំអោយមានការព្រួយបារម្មណ៏ទៅថ្ងៃអនាគត។ ផ្អែកតាមកត្តាខាងលើយើងត្រូវមានវិធានការដកហូតយកដីបឹង និងដីប្រឡាយកមវិញទុកជាសម្បត្តិសាធារណ: ហើយធ្វើការស្តារបឹងប្រឡាយអោយបានជ្រៅដើម្បីទុកជាទុនសំរាប់នាំទឹកស្រោចស្រព្វ និងជាកន្លែងផ្តល់ពូជមច្ឆាជាតិទៀតផង។

**២១. បឹងមានទឹកជាប្រចាំ:** បឹងប្រភេទនេះច្រើនតែកើតមកពីបឹងធម្មជាតិហើយមានទំហំដីធំ និងពោរពេញទៅដោយផ្ទៃទឹកគ្រប់រដូវកាលជាទីជំរកពួកមច្ឆាជាតិរស់នៅ និងបន្តពូជ។ ម្យ៉ាងវិញទៀតបឹងមួយចំនួនក៏កកើតឡើងដោយទង្វើរបស់មនុស្សជីកដោយផ្ទាល់ ឬគ្រឿងចក្រក៏អាចក្លាយទៅជាបឹងដែលមានទឹកជាប្រចាំបានដែរ នៅពេលមានទឹកភ្លៀងហូរចូលពេញមួយរដូវវស្សា អាចប្រែប្រួលទៅជាប្រភពស្រោចស្រព្វទៅថ្ងៃអនាគត។

**២២. បឹងមានទឹកនៅរដូវវស្សា:** បឹងប្រភេទនេះបណ្តាលមកពីបាត់បង់ព្រៃជុំវិញបឹង ហើយនៅរដូវវស្សាមានភ្លៀងធ្លាក់ទឹកហូរនាំទាំងកំទេចកំទីឈើពុកព្រៃតូចៗ និង ទឹកហូរដាច់ដីដែលគ្មានអ្វីទប់ស្កាត់ និងអាចហូរចូលទៅក្នុងបឹងយូៗទៅនឹង រីងរាក់ខ្វះទឹកប្រើប្រាស់នៅរដូវប្រាំងជាពិសេសទៅទៀតគោ ក្របីរបស់ប្រជាពលរដ្ឋខ្វះទឹកផឹក។ កសិករឃើញដី បឹងរីងរាក់នាំគ្នាចាប់យកដីធ្វើស្រែក្នុងបឹងធ្វើអោយមានការជំលោះទាស់ទែងដណ្តើមដីធ្វើស្រែប្រកាន់នូវចំណែករៀងៗខ្លួន តែដីមាត់បឹងជាទ្រព្យសាធារណ:របស់រដ្ឋពុំមានជនណាម្នាក់ហួងហែងយកដីបឹងបានឡើយបើថ្ងៃក្រោយរដ្ឋ ឬ ឃុំមានថវិការអាច និងស្តារបឹងឡើងវិញជាការល្អ ។

**២៣. ទឹកស្ទឹង អូរ :** ប្រភពទឹកស្ទឹងបានកកើតមានឡើងរវាងក្បាលស្ទឹងទាំងបីនៅតំបន់ខាងលើនៃភ្នំក្រវាញរួមមាន:

- ក្បាលស្ទឹងទីមួយមានឈ្មោះស្ទឹពោធិ៍សាត់ដែលមានប្រភពទឹកហូរធ្លាក់មកពីជួរភ្នំក្រវាញស្រុកវាលវែង
- ក្បាលស្ទឹងទីពីមានឈ្មោះស្ទឹងក្រែតបូរីដែលមានទឹកហូរធ្លាក់ចូលស្ទឹងព្រៃខ្លុង
- ក្បាលស្ទឹងទីបីមានឈ្មោះស្ទឹងអារ៉ៃ ដែលមានប្រភពទឹកពីជួរភ្នំខាងលើ

ក្បាលស្ទឹងទាំងបីខាងលើបានហូរមកប្រសព្វគ្នាបង្កើតបានជាចំណុចមួយដែលមានឈ្មោះថា កំពង់លួងក្នុងភូមិសាស្ត្រ ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ចំពោះអូរវិញ គឺជាផ្នែកមួយនៃស្ទឹងដែលមានលក្ខណៈតូច ជ្រៅកាត់តាមជ្រលងភ្នំ និងកើតចេញពីធម្មជាតិពិត១ហើយអូរភាគខ្លះមានទឹកជាប្រចាំ និងខ្លះទៀតមានទឹកនៅរដូវភ្លៀងធ្លាក់តែប៉ុណ្ណោះ ។

**២៤. វាលខ្សាច់:** ជាប្រភេទដីដែលករកើតឡើងពីធម្មជាតិ តាមរយៈការហូរច្រោះកាត់ថ្មភ្នំរឹកអ៊ែផុះភ្នំភ្លើងខាងលើ ហើយបានរាយប៉ាយពាសពេញដីពិសេសមាននៅតាមបាតស្ទឹង ទន្លេ ខ្សាច់ ជាប្រភពផ្តល់នូវគុណប្រយោជន៍ជាច្រើនសំរាប់ធ្វើជាសំណង់ និងប្រើប្រាស់តាមតម្រូវផ្សេង១ទៀតរបស់មនុស្ស។ ម្យ៉ាងទៀតដីខ្សាច់មានការហូរច្រោះបាក់ច្រាំងស្ទឹងកាត់ផ្ទៃដីខាងលើដោយសារទឹកជំនន់លិចវាល ក្រោយពីទឹកស្រកបានបន្សល់នូវវាលខ្សាច់តាមតំបន់វាលទំនាបមួយចំនួនធំ ខ្លះទៀតទឹកហូរនាំយកទៅចាក់នៅមាត់ស្ទឹងមាត់ទន្លេ ដោយល្បាយដីខ្សាច់មានទំងន់ធ្ងន់ក៏បានកកកុញពូនផ្តុំគ្នានៅកន្លែងដែលមានទឹកវល់មិនសូវហូរខ្លាំងនូវរដូវវស្សា ហើយវាលខ្សាច់ទាំងនោះត្រូវបានលិចឡើងវិញដោយសារទឹកជំនន់ម្តង១ ។

**តារាងចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិតក្នុងឃុំព្រងិល :**

| ល.រ | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| ១ | Code : 1200<br>ដីលំនៅដ្ឋានភូមិ |  |
| ២ | Code :2110<br>ស្រូវវស្សា |  |
| ៣ | Code : 2111<br>ដីស្រែជាមួយភូមិ |  |
| ៤ | Code : 2140<br>ចំការស្រូវ |  |

| | | |
|---|---|---|
| ៥ | Code : 2200<br>ចំការដំណាំ : ឈើហូបផ្លែ<br>ដំណាំរយៈពេលខ្លី |  |
| ៦ | Code : 2210<br>ចំការដំណាំ :ក្បែរប្រភពទឹក |  |
| ៧ | Code : 2400<br>ដីកសិកម្មពនេចរៈ |  |
| ៨ | Code : 2410<br>ដីកសិកម្មពនេចរបោះបង់ចោលៈ |  |

| | | |
|---|---|---|
| ៩ | Code : 3110<br>ព្រៃស្រោងសើម : |  |
| ១០ | Code : 3210<br>ព្រៃរបោះ |  |
| ១១ | Code : 3220<br>ព្រៃរបោះ (ស្តើងស្ងួត) |  |
| ១២ | Code :3300<br>ព្រៃចំរុះ |  |

| | | |
|---|---|---|
| ១៣ | Code : 3310<br>ព្រៃដុះតាមមាត់ទឹក: ( ស្ទឹង អូរ...) |  |
| ១៤ | Code : 4110<br>វាលស្មៅលិចទឹក |  |
| ១៥ | Code : 4500<br>ព្រៃគុម្ពោធ |  |
| ១៦ | Code : 4510<br>ចំការបោះបង់ចោលដុះព្រៃគុម្ពោធ |  |

| | | |
|---|---|---|
| ១៧ | Code : 4600<br>ព្រៃគុម្ពោធលាយដើមឈើធំមួយៗ |  |
| ១៨ | Code : 5110<br>បឹង |  |
| ១៩ | Code : 5111<br>បឹងមានទឹកជាប្រចាំ |  |
| ២០ | Code : 5112<br>បឹងមានទឹកនៅរដូវវស្សា |  |

| | | |
|---|---|---|
| ២១ | Code : 5210<br>ស្ទឹង អូរ |  |
| ២២ | Code : 6200<br>ខ្សាច់ |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្តិ និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ដីសង្ស័យមានមីន និងគ្រាប់មិនទាន់ផ្ទុះ | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | ៨,៧៩ |
| | ចំការបោះបង់ចោលដុះស្មៅ | ដីសាធារណៈ/ឯកជនរបស់រដ្ឋ | ៥,៦៧ |
| | ព្រៃស្រោងសើម | ដីសាធារណៈរបស់រដ្ឋ | ១,៤៣ |
| | ព្រៃរបោះ | ដីសាធារណៈរបស់រដ្ឋ | ១,៦៩ |
| **២** | **តំបន់រមនីយដ្ឋានទេសចរណ៍ច្រកល្បៀង** | **ដីសាធារណៈរបស់រដ្ឋ** | **១៤៩,២២** |
| | ព្រៃស្រោងសើម | ដីសាធារណៈរបស់រដ្ឋ | ៦៨,៥៨ |
| | ព្រៃដុះតាមទឹក (ស្មឹង អូរ...) | ដីសាធារណៈរបស់រដ្ឋ | ១៦,៦៨ |
| | ព្រៃរបោះ | ដីសាធារណៈរបស់រដ្ឋ | ៦៣,៩៦ |
| ៣ | **ដីសម្បទានសេដ្ឋកិច** (Pheapimex Fuchan) | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | ៥៧៤១២.១១ |
| | ដីលំនៅដ្ឋានភូមិ | ដីឯកជន | ៥៣០.៩៧ |
| | ដីស្រែលាយភូមិ | ដីឯកជន | ១១៣១.០២ |
| | ដីស្រែវស្សា | ដីឯកជន | ៣០០១.៦២ |
| | ដីចំការដំណាំ | ដីឯកជន | ១៨៤.២១ |
| | កសិកម្មពនេចរ | ដីសាធារណៈរបស់រដ្ឋ | ២០,១៥ |
| | កសិកម្មពនេចរបោះបង់ចោល | ដីសាធារណៈរបស់រដ្ឋ | ៩៤៥,៩៥ |
| | ព្រៃស្រោងសើម | ដីសាធារណៈរបស់រដ្ឋ | ៥៥៣៨,៩៧ |
| | ព្រៃរបោះ | ដីសាធារណៈរបស់រដ្ឋ | ៣៩៤២០,២៥ |
| | ព្រៃរបោះស្តើងស្ងួត | ដីសាធារណៈរបស់រដ្ឋ | ១៧៥,០៥ |
| | ព្រៃចំរុះ (ស្រោង និងរបោះ) | ដីសាធារណៈរបស់រដ្ឋ | ២៣៧៦,៣១ |
| | ព្រៃដុះតាមមាត់ទឹក | ដីសាធារណៈរបស់រដ្ឋ | ១០០៩,៧៦ |
| | ព្រៃដុះឡើងវិញ | ដីសាធារណៈរបស់រដ្ឋ | ១១៣,៤១ |
| | ចំការបោះបង់ដុះស្មៅ | ដីសាធារណៈរបស់រដ្ឋ | ៥៧៤,៨៧ |
| | ព្រៃគុម្ពោធ | ដីសាធារណៈរបស់រដ្ឋ | ៣៦៤,៩៧ |
| | ចំការបោះបង់ដុះព្រៃគុម្ពោធ | ដីសាធារណៈរបស់រដ្ឋ | ២២៣៨,៧២ |

| | | | |
|---|---|---|---|
| | ព្រៃគម្លោចលាយដើមឈើធំមួយៗ | ដីសាធារណៈរបស់រដ្ឋ | ៩៨៣.២៣ |
| | បឹង | ដីសាធារណៈរបស់រដ្ឋ | ០.៣៣ |
| | បឹងមានទឹកជាប្រចាំ | ដីសាធារណៈរបស់រដ្ឋ | ០.៦៩ |
| | បឹងមានទឹកនៅរដូវវស្សា | ដីសាធារណៈរបស់រដ្ឋ | ២.៤១ |
| | ស្ទឹង អូរ | ដីសាធារណៈរបស់រដ្ឋ | ១១.៩៧ |
| **៤** | **តំបន់ជំរកសត្វព្រៃភ្នំឱរ៉ាល់** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **៥០.៧៤** |
| | ស្រូវវស្សា | ដីសាធារណៈរបស់រដ្ឋ | ៥០.៧៤ |
| | កសិកម្មពនេចរ | ដីសាធារណៈរបស់រដ្ឋ | ២០.៦១ |
| | ព្រៃស្រោងសើម | ដីសាធារណៈរបស់រដ្ឋ | ២៨១០៥.៧៤ |
| | ព្រៃរបោះ | ដីសាធារណៈរបស់រដ្ឋ | ១៨១៩៤.៣២ |
| | ព្រៃរបោះស្ដើងស្ងួត | ដីសាធារណៈរបស់រដ្ឋ | ១៤២.៨៩ |
| | ព្រៃចំរុះ (ស្រោង និងរបោះ) | ដីសាធារណៈរបស់រដ្ឋ | ៣១៩៥.០៨ |
| | ព្រៃដុះតាមមាត់ទឹក | ដីសាធារណៈរបស់រដ្ឋ | ២១៥៨.៨៩ |
| | ព្រៃដុះឡើងវិញ | ដីសាធារណៈរបស់រដ្ឋ | ៦.៣៣ |
| | ចំការបោះបង់ដុះស្មៅ | ដីសាធារណៈរបស់រដ្ឋ | ១០៥.២៩ |
| | ព្រៃគុម្ពោច | ដីសាធារណៈរបស់រដ្ឋ | ៣៣.០៧ |
| | ចំការបោះបង់ដុះព្រៃគុម្ពោច | ដីសាធារណៈរបស់រដ្ឋ | ៩.៦៦ |
| | ព្រៃគម្លោចលាយដើមឈើធំមួយៗ | ដីសាធារណៈរបស់រដ្ឋ | ១៩៩.១៦ |
| **៥** | **ដីព្រៃសហគមន៍ (សំរោងយា)** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **៣.៤៦** |
| **៦** | **ដីព្រៃសហគមន៍ព្រៃឈើ ( កំពែង )** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **១៨៨.៤៣** |
| **៧** | **ដីព្រៃសហគមន៍ព្រៃឈើ ( អូរបាក់ត្រា)** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **៨៤៨.៣៤** |
| **៨** | **ដីព្រៃសហគមន៍ព្រៃឈើ (អូរស្រាវ)** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **២០៥.៤៦** |
| **៩** | **ដីព្រៃសហគមន៍ព្រៃឈើ (ព្រងិល)** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **៤៤៧.៧២** |
| **១០** | **ដីព្រៃសហគមន៍ព្រៃឈើ (ស្វាយប៉ាក)** | **ដីសាធារណៈ/ឯកជនរបស់រដ្ឋ** | **១៧១.៩០** |

ប្រភព: ទិន្នន័យ GIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តពោធិ៍សាត់

## ឧបសម្ព័ន្ធ ៣

## បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| **ទំនាស់ដីធ្លី** | ភូមិទាំង ០៧ | ក –ដីមិនទាន់មានបណ្ណ័កម្មសិទ្ធិ | ក.១ -ធ្វើបណ្ណ័ជូនជាលក្ខណៈប្រព័ន្ធ<br>ក.២ -ផ្សព្វផ្សាយអោយម្ចាស់ដីចូលរួមបង្ហាញក្បាលដី<br>ក.៣-អ្នកដឹងពីប្រវត្តិដី<br>ក.៤-កំណត់ព្រំនិងមានការឯកភាពពីអ្នកជាប់ព្រំ |
| | | ខ –មិនយល់ពីច្បាប់ភូមិបាល | ខ.១-ផ្សព្វច្បាប់ភូមិបាលដល់អ្នកភូមិ<br>ខ.២-ចែកឯកសារច្បាប់ភូមិបាលដល់អ្នកភូមិមើលនិងអាន<br>ខ.៣-មេភូមិជួយពន្យល់ណែនាំបន្ថែម<br>ខ.៤-អ្នកចេះច្បាប់ភូមិបាលច្រើនពន្យល់អ្នកចេះតិច |
| | | គ-ព្រំដីមិនច្បាស់លាស់ | គ.១- ពិគ្រោះយោបល់អ្នកជាប់និងព្រំដីគ្នា<br>គ.២- បោះបង្គោលថ្មឬបង្គោលក្រាក់រឹងមាំទៅលើព្រំដី<br>គ.៣-មានការចូលរួមធ្វើជាសាក្សី ពីអ្នកភូមិឬមេភូមិ<br>គ.៤- ធ្វើការវាស់វែងកំណត់ខ្សែម៉ែត្រអោយបានត្រឹមត្រូវ |
| **រុករានដីព្រៃ** | ភូមិបាក់ត្រា<br>ភូមិស្វាយប៉ាក<br>ភូមិព្រងិល<br>ភូមិសាយ | ក- ខ្វះដីកសិកម្ម | ក.១- ផ្តល់ដីសម្បទានសង្គមកិច្ច បើសិនជាមាន<br>ក.២- រៀបចំគណៈកម្មការបែងចែកដី<br>ក.៣- កំណត់មុខសញ្ញាអ្នកដែលខ្វះដីពិតប្រាកដ |

| | | | |
|---|---|---|---|
| | | ខ- កាប់ព្រៃយកដីលក់ | ខ.១- ផ្សព្វផ្សាយពីច្បាប់ព្រៃឈើ<br>ខ.២- បោះបង្គោលព្រំដីព្រៃដើម្បីសំគាល់ជាដីព្រៃរបស់រដ្ឋ<br>ខ.៣- បង្កើតសហគមន៏ព្រៃឈើសរាប់ការពារព្រៃឈើ |
| | | គ -<br>កាប់យកផលព្រៃឈើធ្វើអាជីវកម្ម | គ.១- ពង្រឹងច្បាប់ព្រៃឈើអោយបានតឹងរឹងបំផុត<br>គ.២- មានអាជីវកម្មព្រៃឈើត្រូវមានច្បាប់កំណត់<br>គ.៣- បង្កើតគណៈកម្មការដាក់ពិន័យដល់ជនល្មើសនិងច្បាប់ |
| **ព្រំប្រទល់ឃុំមិនទាន់ច្បាស់លាស់** | ឃុំព្រងិល | ក-ពុំមានឆន្ទះក្នុងការដោស្រាយព្រំប្រទល់ឃុំនឹងឃុំ | ក.១- បង្កើតគណៈកម្មការដោះស្រាយអោយបានឆាប់រហ័ស បំផុត<br>ក.២- រកពេលវេលានិងកំណត់ទីកន្លែងដើម្បីធ្វើការ ដោះស្រាយ<br>ក.៣- បើឃុំទាំងពីរក្នុងស្រុក តែមួយគួរយក អភិបាលស្រុក ធ្វើជាប្រធានគណៈកម្មការសំរបសំរួលព្រំប្រទល់ឃុំ<br>ក.៤- បើឃុំពីរស្រុកផ្សេងគ្នាត្រូវជ្រើសរើសយកអភិបាលស្រុកពីររូបធ្វើជាគណៈកម្មការសំរបសំរួលនិងក្រុមប្រឹក្សទាំងពីរឃុំ |
| **ដីស្រែ ចំការ ខ្សោះជីជាតិ** | ទូទាំងឃុំ | ក-ការហូរច្រោះដោយទឹកភ្លៀងនឹងទឹកជំនន់ | ក.១- ដាំដើមឈើដើម្បីកាត់បន្ថយការហូរច្រោះ<br>ក.២- ត្រូវលើកប្រព័ន្ធប្រឡាយអោយបានត្រឹមត្រូវជៀសវាងមានការហូរច្រោះ ។<br>ក.៣- លើកទំនប់ទប់ទឹកអោយបានរឹងមាំ ហើយខ្ពស់<br>ក.៤- ធ្វើទំនប់បង្ហៀរទឹក<br>ក.៥- ផ្សព្វផ្សាយការធ្វើជីកំប៉ុស្តិ៍អោយបានគ្រប់ភូមិ ងាយស្រួលក្នុងការកែប្រែដី ។ |

| | | | |
|---|---|---|---|
| | | ខ-ដាំដំណាំតែមួយមុខ | ខ.១- ត្រូវបំផុសប្រជាពលរដ្ឋអោយចេះដាំដំណាំច្រើនមុខ នៅលើផ្ទៃដីតែមួយ ( ដំដំណាំឆ្លាស់)<br>ខ.២- ណែនាំនិងផ្សព្វផ្សាយការធ្វើជីធម្មជាតិនិងជីកំប៉ុស្តិ៍តាមផ្ទះ<br>ខ.៣- បង្កើនគុណភាពដីតាមបច្ចេកទេសវិទ្យាសាស្ត្រកសិកម្ម |
| **ទិន្នផលស្រូវទាប** | ទូទាំងឃុំ | ក.-សត្វល្អិតបំផ្លាញ | ក.១- បំផុសប្រជាពលរដ្ឋអោយធ្វើតាមវិធានការណ៍ការពារ តាមបច្ចេកទេសកសិកម្ម ។<br>ក.២- ផ្សព្វផ្សាយបច្ចេកទេសសម្លាប់សត្វល្អិតដោយប្រើថ្នាំពុលបុរាណ<br>ក.៣- ជ្រើសរើសពូជស្រូវអោយធន់ និងជំម្ងឺ<br>ក.៤- ជ្រើសរើសពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ |
| | | ខ-ប្រើពូជស្រូវបុរាណ | ខ.១ -ត្រូវប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ហើយសុទ្ធ<br>ខ.២- ប្រើពូជស្រូវដែលមានរយៈពេលដាំដុះខ្លីហើយមានគុណភាពខ្ពស់<br>ខ.៣- ធ្វើស្រែមួយឆ្នាំអោយបានពីរដង បើអាចធ្វើបាន |
| | | គ-ខ្វះប្រព័ន្ធប្រឡាយស្រោចស្រព្វ | គ.១- ស្តារប្រឡាយឡើងវិញ<br>គ.២- ជីកប្រឡាយមេដើម្បីនាំទឹក<br>គ.៣- លើកទំនប់ទប់ទឹកទុកខែប្រាំង |
| **ផ្លូវខូចខាត (ពិបាកធ្វើដំណើរនិងដឹកជញ្ជូន)** | គ្រប់ភូមិទូទាំងឃុំ | ក- ឡានដឹកទំនិញហួសកំណត់ | ក.១- ត្រូវមានគណៈកម្មការថែទាំផ្លូវថ្នល់<br>ក.២- ផ្សព្វផ្សាយច្បាប់ចរាចរទៅលើរថយន្តធន់ធ្ងន់<br>ក.៣- ត្រូវកំណត់ប្រភេទរថយន្តដែលធ្វើចរាចរតាមដងផ្លូវក្នុង មូលដ្ឋានរបស់ឃុំ |

| | | | |
|---|---|---|---|
| | | ខ- ការលើកផ្លូវ ឬចាក់ដីពុំបានស្តូតល្អ | ខ.១- ត្រូវសិក្សាលំអិតពីរដូវកាល និងកំណត់ដោយច្បាប់<br>ខ.២- គណៈកម្មការធ្វើផ្លូវផ្តល់ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់<br>ខ.៣- គណៈកម្មការថែទាំផ្លូវផ្តល់ត្រូវពិនិត្យ និងមានការចូលរួម ពីប្រជាពលរដ្ឋ<br>ខ.៤- គណៈកម្មការថែទាំផ្លូវផ្តល់ត្រូវទទួលដឹងឮរាល់ពត៏មានជុំ វិញឃុំ |
| | | គ- ចងគោ ក្របីលើផ្លូវ | គ.១- ផ្សព្វផ្សាយអោយប្រជាពលរដ្ឋចេះថែទាំផ្លូវ<br>គ.២- ណែនាំប្រជាពលរដ្ឋអោយយល់ដឹងពីអត្ថប្រយោជន៏ផ្លូវ |
| **សត្វពាហនះកើតជំងឺ** | គ្រប់ភូមិទូទាំងឃុំ | ក- មិនបានចាក់វ៉ាក់សាំងការពារ ជំងឺសត្វ | ក.១- ចាក់ថ្នាំវ៉ាក់សាំងការពារជំងឺសត្វជាប្រចាំ<br>ក.២- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹម និងថែទាំសត្វ<br>ក.៣- បណ្តុះបណ្តាល, ពង្រឹងសមត្ថភាពពេទ្យសត្វភូមិ |
| | | ខ-ខ្វះការយល់ដឹងពីការថែទាំសត្វ | ខ.១- ផ្សព្វផ្សាយអំពីបច្ចេកទេសថែទាំសត្វ<br>ខ.២- បំផុសប្រជាពលរដ្ឋអោយចេះអនាម័យក្រោល និងធ្វើ ជំបូល<br>ខ.៣- បំផុសប្រជាពលរដ្ឋដេរស្បៃធ្វើជាមុង<br>ខ.៤- ជីករណ្តៅដាក់លាមកសត្វអោយបានល្អ |
| **ខ្វះទឹកស្អាតប្រើប្រាស់** | គ្រប់ភូមិទូទាំងឃុំ | ក-ខ្វះសំភារៈបរិក្ខាផ្តល់ទឹកស្អាត | ក.១- ត្រូវធ្វើអណ្តូងមានស្នប់<br>ក.២- ធ្វើអណ្តូងលូមានគំរប<br>ក.៣- ចាក់សាបជុំវិញបរិវេណអណ្តូង |
| | | ខ-រាំងស្ងួត និងទឹកជំនន់ | ខ.១- ជីកស្រះនិងរៀបចំជុំវិញស្រះអោយមានអនាម័យ<br>ខ.២- ផ្តល់ធុងចំរុះដល់ប្រជាពរដ្ឋ<br>ខ.៣- រៀបចំនូវប្រព័ន្ធទឹកស្អាត |

| | | | |
|---|---|---|---|
| **ប្រជាពលរដ្ឋមានជំងឺច្រើន** | គ្រប់ភូមិទូទាំងឃុំ | ក-ខ្វះបង្គន់អនាម័យ | ក.១- អប់រំសុខភាព និងអនាម័យ<br>ក.២- អប់រំអោយចេះប្រើបង្គន់អនាម័យ<br>ក.៣- ផ្តល់បង្គន់អនាម័យ<br>ក.៤- ផ្សព្វផ្សាយពីការងារបរិស្ថាន |
| | | ខ-ខ្វះមុងចងដេក | ខ.១- អប់រំប្រជាពលរដ្ឋអោយដេកក្នុងមុង<br>ខ.២- អប់រំអោយប្រជាពលរដ្ឋចេះបរិភោគទឹកឆ្អិន<br>ខ.៣- ផ្តល់មុងជ្រលក់ថ្នាំ<br>ខ.៤- ចាក់ថ្នាំការពារ |
| **សត្វព្រៃថយចុះ** | ភូមិសាយ<br>ភូមិស្វាយប៉ាក<br>ភូមិអូរស្រាវ<br>ភូមិព្រងិល<br>ភូមិអូរបាក់ត្រា | ក-រុមរានដីធ្វើស្រែចំការ | ក.១- ផ្សព្វផ្សាយច្បាប់រដ្ឋបាលព្រៃឈើ<br>ក.២- បង្កើតសហគមន៍ព្រៃឈើ<br>ក.៣- ផ្សព្វផ្សាយការអភិរក្សសត្វ និងទប់ស្កាត់រាល់បទល្មើសដែលកើតមានឡើង |
| | | ខ-ភ្លើងឆេះព្រៃ | ខ.១- ត្រូវមានវិធានការធ្វើផ្លូវភ្លើងតាមព្រៃសហគមន៍<br>ខ.២- ផ្សព្វផ្សាយ និងមានការចូលរួមទប់ស្កាត់ភ្លើងឆេះព្រៃ<br>ខ.៣- មុនចេញដំណើរត្រូវពន្លត់ភ្លើងជាមុន |
| | | គ-បរបាញ់សត្វព្រៃ | គ.១- ផ្សព្វផ្សាយពីអត្ថប្រយោជន៍សត្វព្រៃ<br>គ.២- ផ្សព្វផ្សាយ និងលុបបំបាត់រាល់ឧបករណ៍កែឆ្នៃសំរាប់ចាប់សត្វ<br>គ.៣- ត្រូវមានវិធានការណ៍ចំពោះជនល្មើស |
| **ខ្វះបណ្តាញពតិមាន** | គ្រប់ភូមិក្នុងឃុំ | ក-ខ្វះការផ្សព្វផ្សាយ | ក.១- ផ្តល់ពតិមានទាន់ហេតុការណ៍តាមរយៈភូមិ ឃុំ<br>ក.២- បង្កើតបណ្តាញផ្សព្វផ្សាយពតិមាន |

| | | | |
|---|---|---|---|
| | | | ក.៣- បណ្តុះបណ្តាលពីការផ្តល់ពតិមាន |
| | | ខ-ខ្វះធន់ធានមនុស្ស | ខ.១- បណ្តុះបណ្តាលធន់ធានមនុស្ស<br>ខ.២- ផល់ឧបករណ៍ផ្សព្វផ្សាយ<br>ខ.៣- ផ្តល់សេវាំសំរាប់ផ្សព្វផ្សាយ |
| **រំលោភដីបឹងធម្មជាតិធ្វើស្រែ** | គ្រប់ភូមិក្នុងឃុំ | ក-ខ្វះដីធ្វើស្រែ | ក.១- កំណត់ដីសប្បទានសង្គមកិច្ច<br>ក.២- ផ្សព្វផ្សាយច្បាប់ភូមិបាល<br>ក.៣- កំណត់ព្រំ និងចុះបញ្ជីជាទ្រព្យរដ្ឋ |
| | | ខ-ដីបឹងរាក់ | ខ.១- មានវិធានការស្តារបឹង<br>ខ.២- ទប់ស្កាត់រាល់ការធ្វើស្រែក្នុងបឹង<br>ខ.៣- ហាមឃាត់រាល់ការចេញលិខិតស្នាមកាន់កាប់ |
| **មច្ឆជាតិថយចុះ** | គ្រប់ភូមិទូទាំងឃុំ | ក-បឹងរាក់ | ក.១- ស្តារបឹងឡើងវិញ<br>ក.២- ផ្តល់ពូជត្រីចិញ្ចឹមជាលក្ខណៈគ្រួសារ<br>ក.៤- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី |
| | | ខ-នេសាទខុសច្បាប់ | ខ.១- លុបបំបាត់ឧបករណ៍ខុសច្បាប់<br>ខ.២- បង្កើតសហគមន៍នេសាទ<br>ខ.២- ផ្សព្វផ្សាយច្បាប់ជលផល |

## ឧបសម្ព័ន្ធ ៤

## ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត

## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ចង់បានពូជស្រូវទិន្នផលខ្ពស់** | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ | - ពីឆ្នាំ២០០៨ - ២០១២បុរសស្ត្រីទូទាំងឃុំមានស្រូវហូបគ្រប់គ្រាន់ | - កែរលំអរប្រពន្ធ័ស្រោចស្រព<br>- បង្កើនសហគមន៍កសិករប្រើប្រាស់ទឹក ។<br>- ប្តូរពូជស្រូវមានទិន្នផលខ្ពស់រយះពេលដាំដុះខ្លី ។ | - ជីកប្រឡាយ<br>- ស្តារប្រឡាយ<br>- ម៉ាស៊ីនបូមទឹក<br>- ធ្វើជីកំប៉ុស្ដិ៍<br>- ផ្តល់ពូជស្រូវដែលមានគុណភាពខ្ពស់ | |
| **មានផ្លូវងាយស្រួលធ្វើដំណើរ** | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ | - ពីឆ្នាំ២០០៨- ២០១២ចងក្រងសហគមន៍ជុសជុលផ្លូវ | - ជំរុញកែរលំអរអោយមានប្រពន្ធ័ផ្លូវលំជនបទ ។ | - សង់ផ្លូវលំដីសរ<br>-ក្រាលគ្រួសក្រហម<br>- សាងសង់ស្ពាន<br>- ជុសជុលជាប្រចាំ<br>- ដាក់លូកាត់ផ្លូវ | |

| | | | | | |
|---|---|---|---|---|---|
| **បណ្តុះបណ្តាលការប្រើប្រាស់ជីគីមីដំណាំកសិកម្ម** | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ | - ឆ្នាំ២០០៨-២០១២ប្រជាពលរដ្ឋចេះប្រើប្រាស់ជីគីមី | - បង្កើនការដាំដុះអោយមានទិន្នផលខ្ពស់ | - ផ្សព្វផ្សាយអោយចេះប្រើជីគីមី និងថ្នាំសំលាប់សត្វល្អិត<br>- ផ្សព្វផ្សាយធ្វើជីកំប៉ុស្តិ៍<br>- ផ្សព្វផ្សាយធ្វើជីIM<br>- ផ្សព្វផ្សាយធ្វើស្រែបង្ហាញ | |
| **មានឈើប្រើប្រាស់ឡើងវិញ** | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ | - ឆ្នាំ២០០៨ដល់២០១២ប្រជាពលរដ្ឋយល់ដឹងនិងដាំដុះដើមឈើឡើងវិញ | -បង្កើនការការពារនិងថែរក្សាផលអនុផលព្រៃឈើ<br>-ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ | - ផ្សព្វផ្សាយច្បាប់ស្តីអំពីព្រៃឈើ<br>- បង្កើតសហគមន៍ព្រៃឈើ<br>-ដាំកូនឈើឡើងវិញ | |
| **ថែរក្សាមច្ឆាជាតិ** | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ | - ឆ្នាំ២០០៨-២០១២ប្រជាពលរដ្ឋយល់ដឹងអំពីការថែរក្សាមច្ឆាជាតិនិងបរិស្ថាន | - បង្កើនធនធានជលផល<br>- ផ្តល់ពូជត្រី<br>- ចិញ្ចឹមត្រីក្នុងស្រះ | -បង្កើនការចិញ្ចឹមត្រី<br>- អភិរក្សមច្ឆាជាតិ | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍ខុសច្បាប់ | |
| **ចង់បានសត្វព្រៃសម្បូរឡើងវិញ** | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ២០០៨-២០១២ | - ឆ្នាំ២០០៨-២០១២ធ្វើអោយសត្វព្រៃសម្បូរ | - ពង្រឹងការគ្រប់គ្រង និងការការពារបរិស្ថាន | - ផ្សព្វផ្សាយច្បាប់បរិស្ថាន និងការការពារសត្វព្រៃ<br>- ទប់ស្កាត់ការប្រមាញ់ខុសច្បាប់<br>- ទប់ស្កាត់ការរុករានព្រៃឈើ | |

## ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឫសកម្មភាពសំខាន់ៗរបស់ឃុំ ក្នុងរយៈពេល១៥ឆ្នាំ

| ល.រ | គំរោង ឫសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ | ៥ឆ្នាំទី២ | ៥ឆ្នាំទី៣ | |
| ២.៦.១ | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | ២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត | | | | | | |
| | ១.១. ផ្លូវថ្នល់ | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ | ០ | គីឡូម៉ែត្រ | ០ | ០ | ០ | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហម | ៤,៦ | គីឡូម៉ែត្រ | ១ | ២ | ១,៦ | |
| | ១.១.៣. ប្រវែងផ្លូវក្រាលដីស | ៦៩,៥ | គីឡូម៉ែត្រ | ២៥,៤៧ | ៣២,១៥ | ១១,៨៨ | |
| | ១.១.៤. ផ្លូវរទេះ/ថ្មើជើង | ០ | គីឡូម៉ែត្រ | ០ | ០ | ០ | |
| | ១.២. ប្រព័ន្ធស្រោចស្រព | | | | | | |
| | ១.២.១. ស្តារប្រឡាយមេ | ២,៦១ | គីឡូម៉ែត្រ | ២,៦១ | ០ | ០ | |
| | ១.២.២. ស្តារប្រឡាយរង | ៣,៧ | គីឡូម៉ែត្រ | ០ | ៣,៧ | ០ | |
| | ១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | | | ០ | | | |
| | ១.៣.២. ចំនួនស្ពានឈើ | ៣៩ | កន្លែង | ២៣ | ០៨ | ០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.៣.៣. ចំនួន ទ្វាទឹក | ២៤ | កន្លែង | ១៤ | ០៥ | ០៥ | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ | ១២២ | កន្លែង | ៩២ | ១៥ | ១៥ | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ២ | អគារ | ១ | ០ | ១ | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ២ | អគារ | ០ | ០ | ២ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ២ | អគារ | ១ | ១ | ០ | |
| | ២.៦.១.២.៥. សាលាវិទ្យាល័យ | ៥ | អគារ | ២ | ១ | ២ | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. មណ្ឌលសុខភាព | ០១ | កន្លែង | ០ | ០ | ០ | |
| | ២.៦.១.៥. ប៉ុស្តិសុខភាព | ៧ | កន្លែង | ០ | ៣ | ៤ | |
| | ២.៦.១.៦. ស្រះទឹកស្អាត | ១០ | ស្រះ | ៥ | ៣ | ២ | |
| | ២.៦.១.៧. អណ្តូងទឹកស្អាត | ៥៣ | អណ្តូង | ១៧ | ៧១ | ១៥ | |
| | ២.៦.១.៨. អណ្តូងលូ | ៦០ | កន្លែង | ២០ | ២០ | ២០ | |
| | ២.៦.១.៩. កន្លែងចាក់សំរាម | ០២ | កន្លែង | ០ | ១ | ១ | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិនគរបាល | ០១ | កន្លែង | ០១ | ០ | ០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៤.២. ទីតាំងផ្សារ | ០១ | កន្លែង | ០ | ១ | ០ | |
| | **២.៦.១.៥. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៥.១. ប្រាសាទ | ០ | ០ | ០ | ០ | ០ | |
| | ២.៦.១.៥.២. សាលាឆទាន | ០២ | កន្លែង | ០២ | ០ | ០ | |
| | ២.៦.១.៥.៣. វត្តព្រះអារាម | ០២ | កន្លែង | ០ | ០១ | ០១ | |
| **២.៦.២** | **គំរោងផ្នែកប្រើប្រាស់ដីធ្លី** | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ដីសហគមន៍ព្រៃឈើ | ០១ | កន្លែង | ០១ | ០ | ០ | |
| | ២.៦.២.១.២. តំបន់ទេសចរបរិស្ថាន | ២ | កន្លែង | ០ | ១ | ១ | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ៨៩ | ហ.ត | ៤៣ | ៣៦ | ១០ | |
| | ២.៦.២.២.២. ដីស្រែលាយភូមិ | ៧៨៣ | ហ.ត | ២៧៥ | ២៧៥ | ២៣៣ | |
| | ២.៦.២.២.៣. ដីវាលកប់ខ្មោច | ០១ | ហ.ត | ០ | ០១ | ០ | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីច្បាប់ដី និងច្បាប់ព្រៃឈើ | ៩០ | វគ្គ | ៣០ | ៣០ | ៣០ | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ដី | ១១០ | វគ្គ | ៧០ | ២០ | ២០ | |
| | ២.៦.២.៣.៣. វគ្គបណ្តុះបណ្តាលច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ | ៩០ | វគ្គ | ៣០ | ៣០ | ៣០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.៣.៤. បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ | ១០០ | វគ្គ | ៧០ | ៣០ | ២០ | |
| | ២.៦.២.៣.៥. បណ្តុះបណ្តាលបច្ចេកទេសដំណាំឈើហូបផ្លែ | ៦៥ | វគ្គ | ៣៥ | ១៥ | ១៥ | |
| | ២.៦.២.៣.៦. បណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ | ១០០ | វគ្គ | ៧០ | ៣០ | ២០ | |
| | ២.៦.២.៣.៧. បណ្តុះបណ្តាលបច្ចេកទេសធ្វើ អាយ អ៊ឹម | ១០០ | វគ្គ | ៧០ | ៣០ | ២០ | |
| | ២.៦.២.៣.៨. បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត | ១០០ | វគ្គ | ៧០ | ៣០ | ២០ | |
| | ២.៦.២.៣.៩. បណ្តុះបណ្តាលធ្វើស្រែបង្ហាញ | ១៥ | វគ្គ | ៥ | ៥ | ៥ | |
| | ២.៦.២.៣.១០.បណ្តុះបណ្តាលបច្ចេកទេសដំណាំចំរុះតាមគ្រួសារ | ១០៥ | វគ្គ | ៣៥ | ៣៥ | ៣៥ | |
| | ២.៦.២.៣.១១. ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ | ១០៥ | វគ្គ | ៣៥ | ៣៥ | ៣៥ | |
| | ២.៦.២.៣.១២. ផ្សព្វផ្សាយច្បាប់បរិស្ថាន | ១០៥ | វគ្គ | ៣៥ | ៣៥ | ៣៥ | |
| | ២.៦.២.៣.១៣. ផ្សព្វផ្សាយច្បាប់ជលផល | ១៥ | វគ្គ | ៥ | ៥ | ៥ | |
| | ២.៦.២.៣.១៤. ផ្សព្វផ្សាយច្បាប់ភូមិបាល | ១០៥ | វគ្គ | ៣៥ | ៣៥ | ៣៥ | |

# ផែនទីប្រើប្រាស់ដីលំអិតក្នុង ឃុំព្រងិល

## Detail Land Use Map in Progil Commune (150404)



# ផែនទីប្រើប្រាស់ដីសាមញ្ញ នៅក្នុងឃុំព្រងិល

## Simplify Land Use Map in Progil Commune (150404)




| សញ្ញាសំគាល់ | LEGEND |
|---|---|
| សាលាស្រុក | District Office |
| សាលាឃុំ | Commune Office |
| ភូមិ | Village |
| វត្ត | Pagoda |
| សាលារៀន | School |
| មណ្ឌលសុខភាព | Health Center |
| ព្រំប្រទល់ប្រទេស | National Boundary |
| ព្រំប្រទល់ខេត្ត | Province Boundary |
| ព្រំប្រទល់ស្រុក | District Boundary |
| ព្រំប្រទល់ឃុំ | Commune Boundary |
| ព្រំប្រទល់ការស្នើសុំរបស់ឃុំ | Proposed Boundary |
| ផ្លូវ ចាក់កៅស៊ូ | Sealed Road |
| ផ្លូវ គ្រួសក្រហម ឬ ក្រាលថ្ម | Laterite Road |
| ផ្លូវលំ | Track |
| ស្ទឹង/អូរមានទឹកជាប្រចាំ | Permanent River |
| ស្ទឹង/អូរមានទឹកនៅរដូវវស្សា | Seasonal Stream |
| ប្រឡាយ | Canal |
| ទំនប់ | Levee |
| តំបន់ជំរកសត្វព្រៃ ឱរ៉ាល់ | Aural, Wildlife Sanctuary |
| តំបន់ជំរកសត្វព្រៃ ភ្នំសំកុះ | Phnom Samkos, Wildlife Sanctuary |
| តំបន់ប្រើប្រាស់ច្រើនយ៉ាង ទន្លេសាប | Tonle Sap, Multiple Use |
| ព្រៃការពារ ក្រវ៉ាញ | Cardamom Protected Forest |

**ប្រភេទការប្រើប្រាស់ដី**

| | |
|---|---|
| ដីលំនៅដ្ឋាន | Settlement, Infrastructure |
| កសិកម្ម | Agriculture |
| ព្រៃឈើ | Forest |
| វាលស្មៅ,វាលស្បូវ | Grass, Shrubland |
| ប្រភពទឹក | Water Bodies |
| ដីដែលគ្មានរុក្ខជាតិដុះគ្របដណ្តប់ | Rock, Soil |




Danida/DFID

**ប្រព័ន្ធកូអរដោនេ**

UTM(Universal Transver Macator)

48

(Reference Datum) Indian 1960

Everest

**មាត្រដ្ឋាន** 1:90,000

0 5,000 10,000

Meters

**ប្រភពទិន្នន័យ :**

(2003)

(2003) (D-LUP)

2004

**បញ្ជាក់ :**

# ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំព្រូខិល ឆ្នាំ ២០០៩ ~ ២០២២

Future Land Use Map of Progil Commune for Year 2009 - 2022 (150404)



# ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំព្រទិល ឆ្នាំ ២០០៩ - ២០២២

Future Land Use Map of Progil Commune for Year 2009 - 2022 (150404)

